អាថ៌កំបាំងរបស់ខ្មែរ

# ឫសគល់ ៧ មករា



**ហ៊ុន សែន លក់ជាតិ កាត់ទឹកដីអោយយួន**

# អារម្ភកថា (Preface)

សៀវភៅនេះសរសេរឡើងក្នុងគោលបំណងដើម្បីដាស់ស្មារតី កូនចៅខ្មែរជំនាន់ក្រោយ ប្រជាពលរដ្ឋខ្មែរទាំងអស់ពីគ្រប់ស្រទាប់ក្នុងសង្គម ទាំងក្នុង និងក្រៅប្រទេស ព្រមទាំងប្រជាជាតិទាំងអស់នៅក្នុងតំបន់ ដែលរងគ្រោះដោយសារការគៀបសង្កត់ជិះជាន់ពីយួនកុម្មុយនិស្ត អោយភ្ញាក់រលឹកមើលឃើញពីគ្រោះថ្នាក់ប្រទេស ជាតិ ជាពិសេសចង់បង្ហាញពី **ឫសគល់បញ្ហា** ដែលបាននិងកំពុងកើតមាននៅក្នុងប្រទេសខ្មែរបច្ចុប្បន្ន។ ក្នុងនាមយើងជាកូនខ្មែរមួយរូប ដែលកំពុងអានសៀវភៅនេះនៅក្នុងដៃ យើងត្រូវរួបរួមគ្នាគិតគូរពីអាយុជីវិតប្រទេសជាតិរបស់យើង ដោយមិនត្រូវបណ្តោយអោយ ជាតិ សាសនា ប្រជាជាតិខ្មែរ នៅរងទុក្ខវេទនា ធ្លាក់ចូលទៅក្នុងកណ្តាប់ដៃយួនកុម្មុយនិស្ត ដូចប្រទេសចម្ប៉ា និង កម្ពុជាក្រោមឡើយ។ យើងជាខ្មែរត្រូវពិចារណាថា តើយើងរស់នៅលើទឹកដីខ្មែរ សមជាពូជខ្មែរសាងអង្គរឬទេ? បើសិនជា យើងមិនបានសាងអ្វីជាប្រយោជន៏ជូនជាតិ ថែមទាំងយើងមិនអាចការពារផលប្រយោជន៏ជាតិ ការពារកេរ្តិ៍មតិករបស់ដូនតាយើងដែលបានសាងទុកសំរាប់កុលបុត្រខ្មែរអោយបានគង់វង្សនោះ? យើងមិនត្រូវបណ្តោយអោយជនពុករលួយ មួយក្តាប់តូច បំផ្លាញជាតិ លួចជាតិយកទៅធ្វើជាប្រយោជន៏ផ្ទាល់ខ្លួន ឬបំរើផលប្រយោជន៏នយោបាយអោយបរទេសបន្តទៀតឡើយ។ យើងទាំងអស់គ្នាមិនត្រូវបណ្តោយអោយប្រទេសខ្មែរ ជាតិខ្មែរក្លាយជាកម្ពុជាក្រោមទី២ តាមនយោបាយត្រជាក់របស់យួន ដែលមានរបបផ្តាច់ការ ហ៊ុន សែន ជួយបិទបាំងនោះឡើយ។ សៀវភៅនេះលាតត្រដាងបង្ហាញឬសគល់នៃបញ្ហានៅក្នុងប្រទេសខ្មែរ ដើម្បីអោយប្រជាជាតិខ្មែរទាំងអស់បានឃើញនូវអ្វីដែលជនផ្តាច់ការ ពួកកុម្មុយនិស្តខិតខំលាក់បាំងកប់ទុក មិនអោយប្រជាពលរដ្ឋខ្មែរយល់ដឹងពីផែនការនយោបាយដ៏ខ្មៅក្រខ្វក់របស់យួនកុម្មុយនិស្ត ដែលមានមហិច្ឆតាលេបយកទឹកដីខ្មែរ។ ដោយសារមហិច្ឆតានយោបាយយួនកុម្មុយនិស្តនេះហើយ ដែលបានធ្វើអោយប្រជាពលរដ្ឋខ្មែរ ខ្មែរក្រោម និងប្រជាពលរដ្ឋក្នុងតំបន់រងគ្រោះ ស្លាប់បាត់បង់ជីវិតរាប់លាននាក់កន្លងមក។ ជាក់ស្តែង បច្ចុប្បន្នយើងឃើញស្រាប់ហើយថា បញ្ហាជាច្រើនកំពុងតែកើតមាននៅក្នុងប្រទេសខ្មែរ ដូចជាការកាប់រុករានព្រៃឈើ ជីករ៉ែ កាយភ្នំ រឹបអូសដីធ្លីប្រជាពលរដ្ឋ ពុករលួយ បិទសិទ្ធិសេរីភាព ជនអន្តោប្រវេសន៏យួនខុសច្បាប់ កងទ័ពយួនទាំងឯកសណ្ឋាន ទាំងស៊ីវិលនៅក្នុងប្រទេសខ្មែរ តែរបបផ្តាច់ការ ហ៊ុន សែន នេះគ្មានឆន្ទៈពិតប្រាកដដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរ និងគ្មានការពារផលប្រយោជន៏ជាតិខ្មែរ យើងឡើយ។ ម្យ៉ាងវិញទៀត តាមរយៈសៀវភៅនេះដែរ អ្នកនិពន្ធចង់បង្ហាញអំពីអ្វីដែលប្រជាពលរដ្ឋខ្មែរចង់បានប្រជាពលរដ្ឋចង់ឃើញការផ្លាស់ប្តូរនយោបាយដឹកនាំប្រទេសនិងមេដឹកនាំ ពីរបបកុម្មុយនិស្តផ្តាច់ការក្រោមយួនត្រួតត្រា ទៅជាប្រទេសមួយមាន ឯករាជ្យ សន្តិភាព សិទ្ធិសេរីភាព និងប្រជាធិបតេយ្យពិតប្រាកដ។

ប្រជាពលរដ្ឋខ្មែរជាជនរងគ្រោះពីមួយជំនាន់ទៅមួយជំនាន់ ដោយសារតែមេដឹកនាំរបស់ខ្លួនលោភលន់អំណាច គិតប្រយោជន៍ផ្ទាល់ខ្លួនជាងផលប្រយោជន៍ជាតិ សុខលើគំនរទុក្ខប្រជាពលរដ្ឋ ជាពិសេសដូចពួកមេដឹកនាំកុម្មុយនិស្តផ្តាច់ការបច្ចុប្បន្ន ហ៊ុន សែន ហេង សំរិន ជា ស៊ីម បានលង់ក្នុងមនោគមន៍កុម្មុយនិស្តយួន។ យួនបានយកលិទ្ធិកុម្មុយនិស្តនេះជាមធ្យោបាយ មកសាបព្រោះលើខ្មែរ អោយខ្មែរបែកបាក់ ប្រៀបដូចទឹកខ្មៅមួយតំណក់ដែលស្រក់លើទឹកស្អាតល្អបរិសុទ្ធ ព្រោះតែចង់ដណ្តើមរឹបអូសយកផលប្រយោជន៍ពីខ្មែរ លេបទឹកដីខ្មែរ ។ យួនមានចេតនារំលើងឫសគល់ខ្មែរអោយធ្លាក់ខ្សោយ នៅក្នុងរបប ប៉ុល ពត ដើម្បីបំពេញមហិច្ឆតាលេបទឹកដីខ្មែរ ហើយត្រួតត្រាខ្មែរតាំងពីថ្ងៃ៧ មករា ១៩៧៩ មក។

ប្រទេសខ្មែរជាប្រទេសតូចមួយ ដែលសម្បូរដោយធនធានធម្មជាតិ ស្ទើរតែគ្រប់បែបយ៉ាង ប៉ុន្តែជាអកុសល ក្រោមការដឹកនាំរបស់ពួកត្រួតត្រាបច្ចុប្បន្ន ដែលសុខចិត្តឱនក្បាលក្រោមយួនត្រួតត្រា អោយមកបំផ្លាញធនធានធម្មជាតិខ្មែរ និងរឹបអូសយកទៅប្រទេសគេគ្មានសល់ មានជាអាទិ៍ ដី ព្រៃឈើ រ៉ែ ត្រី សត្វព្រៃ និងជាច្រើនទៀត។ យួនកុម្មុយនិស្តបានធ្វើអាណានិគមន៍បែបថ្មីលើប្រទេសខ្មែរ ដោយប្រើសិទ្ធិសញ្ញាខុសច្បាប់ ដែលបានធ្វើឡើងជាមួយ ហ៊ុន សែន ជា ស៊ីម ហេង សំរិន តាំងពីឆ្នាំ ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ ស្តីពីមិត្តភាព សន្តិភាព សហប្រតិបត្តិការ និងចុះហត្ថលេខាសិទ្ធិសញ្ញាបំពេញបន្ថែមថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៥។ យើងឃើញហើយ រដ្ឋាភិបាលបច្ចុប្បន្នផ្តល់ដីសម្បទានអោយក្រុមហ៊ុនយួន ដែលមានរយៈពេល ៩៩ ឆ្នាំ អស់ចំនួន ៤៥ ភាគរយ ក្រោមពាក្យថា **វិនិយោគ និងអភិវឌ្ឍន៍**។ ***ការរឹបអូសដីដែលធ្វើឡើងដោយក្រុមហ៊ុនយួននេះបានធ្វើអោយប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋខ្មែរក្រីក្រយ៉ាងខ្លាំង ព្រោះដីស្រែដីចំការនោះហើយជាឆ្អឹងខ្នងរបស់ពលរដ្ឋក្រីក្រ។***

ក្រោមការត្រួតត្រារបស់ជនផ្តាច់ការ ហ៊ុន សែន ជាជនលួចជាតិ លក់ជាតិ ដូចរបាយការណ៏ក្លបលវិធណែលបានផ្សព្វផ្សាយ យើងឃើញថា ពួកនេះមិនបានការពារផលប្រយោជន៍ជាតិខ្មែរ មិនបានបំរើផលប្រយោជន៍អោយប្រជាពលរដ្ឋខ្មែរទូទៅទេ ផ្ទុយទៅវិញ ពួកនេះប្រព្រឹត្តអំពើពុករលួយ លួចជាតិ លក់ជាតិ អោយយួន ដែលជនជំពូកនេះ បើតាមការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធថា *មន្ត្រីរាជការដែលអយុត្តិធម៌ ពុករលួយ គឺជាចោរដែល ធ្វើអោយប្រជាពលរដ្ឋវេទនា ពួកជនប្រភេទនេះ អាក្រក់ជាងចោរធម្មតាទៀត ពីព្រោះថាពួកនេះលួចទាំងទ្រព្យ សម្បត្តិជាតិ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយធ្វើអោយជាតិមានបញ្ហា មិនចេះចប់ ប្រជាពលរដ្ឋជាម្ចាស់អំណាច មានសិទ្ធិពេញលេញ ដើម្បីដកមន្ត្រីទាំងនោះ និងដាក់ទណ្ឌកម្មពួកគេ។*

បើសិនជាប្រជាពលរដ្ឋខ្មែរបានដឹងហើយ ឮហើយ ឃើញហើយ មិនរួបរួមគ្នាដោះស្រាយបញ្ហានេះ អោយចប់ទេ វាសនាខ្មែរនិងរងទុក្ខវេទនាដូចជាខ្មែរនៅកម្ពុជាក្រោម តកូន តចៅ ក្រោមការគ្រប់គ្រងរបស់ **យួនក្លែងភេទជាខ្មែរ** ជាមិនខានឡើយ ។

ចុងបញ្ចប់នេះ ខ្ញុំរីករាយទទួលនូវការរិះគន់កែលម្អគ្រប់បែបយ៉ាងពីអស់លោកអ្នកអាន នូវរាល់កំហុសឆ្គងទាំងឡាយណា ដែលមាននៅក្នុងសៀវភៅនេះ ។

សូមទំនាក់ទំនង តាមអ៊ីម៉ែល sar_dharmmarainsey@yahoo .com

# សេចក្តីផ្តើម (Introduction)

ប្រទេសខ្មែរ ជាប្រទេសមួយមានទីតាំងស្ថិតនៅអាស៊ីភាគអាគ្នេយ៍ មានផ្ទៃដីចំនួន ១៨១ ០៣៥ គីឡូម៉ែត្រការ៉េ ព្រំប្រទល់ខាងលិចជាប់ប្រទេសថៃ ខាងជើងជាប់ប្រទេសថៃនិងប្រទេសឡាវ និងខាងកើតជាប់ប្រទេសយួន។ ប្រជាពលរដ្ឋខ្មែរមានចំនួន ១៤ ៥ ០០ ០០០ នាក់ ក្នុងនោះមានជនជាតិយួនចំនួន ៤ ៥០០ ០០០ នាក់កំពុងរស់នៅក្នុងប្រទេសខ្មែរ និងមួយចំនួនទៀតជាចារកម្មយួនក្លែងភេទជាខ្មែរ កំពុងត្រួតត្រាខ្មែរនៅក្នុងក្រសួងសំខាន់ៗសព្វថ្ងៃ មានទាំងស៊ីវិល យោធា និងប៉ូលីសទៀតផង។ ខ្មែរភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា និងខ្មែរចំនួនតិចតួចកាន់សាសនា អ៊ីស្លាម និងគ្រីស្ត។ ប្រទេសខ្មែរបច្ចុប្បន្ននេះត្រួតត្រាដោយរបបផ្តាច់ការហ៊ុន សែន ដែលយួនលើកបន្តុបឡើងអោយធ្វើជាអាយ៉ង កាន់អំណាចតាំងពីទសវត្ស ១៩៨០។ នៅឆ្នាំ ១៩៩៩ ប្រទេសខ្មែរបានក្លាយជាសមាជិកពេញសិទ្ធិរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា (អាស៊ាន)។

ប្រទេសខ្មែរធ្លាប់បានយួនត្រួតត្រាម្តងមកហើយ នៅក្នុងរជ្ជកាលស្តេចអង្គម៉ី ចន្លោះឆ្នាំ ១៨៣៥-១៨៤១ តែត្រូវខ្មែររើបំរះរួចពីអាណានិគមន៍នេះ ដោយខ្មែររួបរួមសាមគ្គីគ្នា ងើបឡើងដេញយួនចេញ កាលនោះមេទ័ពយួនឡើង មិញយ៉ាង ជាអ្នកកាន់កាប់ប្រទេសខ្មែរ។ ក្រោយមកទៀត ខ្មែរបានធ្លាក់ក្នុងអាណានិគមន៍បារាំងនៅចន្លោះឆ្នាំ ១៨៦៣-១៩៥៤ ចាប់ពីស្តេច នរោត្តម រហូតមកដល់ស្តេច នរោត្តម សីហនុ។ ខ្មែរក៏ធ្លាប់នៅក្រោមការត្រួតត្រារបស់ជប៉ុនមួយរយៈពេលខ្លី នៅក្នុងសម័យសង្គ្រាមលោកលើកទី២ ដែរ។ ក្រោយពីខ្មែរបានរួចពីអាណានិគមន៍បារាំងមក ប្រទេសខ្មែរបានធ្លាក់ចូលនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២ ។ នៅក្នុងពេលនោះ ពិភពលោកស្ថិតនៅក្នុងដំណាក់កាលសង្គ្រាមត្រជាក់ រវាងកុម្មុយនិស្ត និងសេរី (សហភាព សូវៀត និង សហរដ្ឋអាមេរិក)។ ចំណែកឯប្រទេសខ្មែរបានងាកទៅរកប៉ូលថ្មីមួយទៀត ប្រកាន់នយោបាយអព្យាក្រិត (មិនចូលបក្សសម្ព័ន្ធ) គឺចិន។ ពេលនោះ សង្គ្រាមឥណ្ឌូចិនលើកទី ២ បានចាប់ផ្តើមឡើង ដែលមានយួនខាងជើង (យួនកុម្មុយនិស្ត) ដឹកនាំដោយ ហូ ជីមិញ គាំទ្រដោយ ចិន បានចាប់ផ្តើមធ្វើសង្គ្រាមជាមួយយៀកណាមខាងត្បូងដឹកនាំដោយ ង៉ោ ឌិញយិម ដែលគាំទ្រដោយសហរដ្ឋអាមេរិក នៅឆ្នាំ១៩៥៨ ដើម្បីបង្រួបបង្រួមយៀកណាមទាំងពីរ។ គោលបំណងពិតប្រាកដរបស់យួនកុម្មុយនិស្តមានមហិច្ឆតា វាតទីទឹកដីចូលមកក្នុងទឹកដីខ្មែរ ដើម្បីកាន់កាប់ឥណ្ឌូចិនទាំងមូល ។ កាលនោះ សីហនុ និង សា ឡុតសរ (ប៉ុល ពត) ជាអ្នកគាំទ្រ ជួយខាងកុម្មុយនិស្ត (យៀកកុង) ដើម្បីប្រឆាំងខ្មែរសាធារណរដ្ឋ លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ ពេលដែលយៀកកុងបានទទួលជ័យជំនះលើខ្មែរសាធារណរដ្ឋនៅលើទឹកដីខ្មែរ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យួនបានបំពាក់ជ័យជំនះនេះ និងលើកអំណាចទៅអោយ សីហនុ និង ប៉ុល ពត ដែលបំរើខាងកុម្មុយនិស្ត។ ១៣ថ្ងៃក្រោយពីយៀកកុងឈ្នះលើរបប

សាធារណរដ្ឋខ្មែរ លន់ នល់ គឺ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៧៥ យួនកុម្មុយនិស្តបានបញ្ចប់សង្គ្រាមរវាងយួនខាងជើង និងយួនខាងត្បូងភ្លាម។ ត្រង់នេះបញ្ជាក់អោយឃើញថា សង្គ្រាមដែលយួនធ្វើឡើង មានគោលបំណងវាតទីទឹកដីនិងផលប្រយោជន៏របស់ជាតិគេ ដើម្បីដាក់ប្រទេសទាំងអស់អោយទៅជាចំណុះ សហព័ន្ធឥណ្ឌូចិន។ ដូច្នេះ ថ្ងៃ ១៧ មេសា ១៩៧៥ ជាថ្ងៃជ័យជំនះរបស់ពួកកុម្មុយនិស្តឥណ្ឌូចិន ដែលមានយួនធ្វើជាមេក្លោង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យួនបានរៀបចំផែនការល្បិចលួន់តាមគោលការណ៏សហព័ន្ធឥណ្ឌូចិន មកកកូរស្ថានការណ៏ក្នុងប្រទេសខ្មែរក្នុងរបបនេះ រួមជាមួយខ្មែរកុម្មុយនិស្តទាំងពីរក្រុម ដែលយួនបានបំពាក់បំប៉នមនោគមន៏កុម្មុយនិស្តរួចជាស្រេច។ កត្តាទាំងអស់នេះហើយ ជាបុព្វហេតុធ្វើអោយប្រទេសខ្មែរធ្លាក់ទៅក្នុងគ្រោះមហន្តរាយមួយយ៉ាងធ្ងន់ធ្ងរទៅក្នុងរបបប្រល័យពូជសាសន៏។ យួនយកលិទ្ធិកុម្មុយនិស្តជាមធ្យោបាយ ធ្វើអោយខ្មែរ ទាំងខ្មែរក្រោម និងខ្មែរបច្ចុប្បន្ន ស្លាប់រង្គាលអស់រាប់លាននាក់ ក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩។ នៅចន្លោះពេលនោះប្រទេសខ្មែរដឹកនាំដោយ នរោត្តម សី ហនុ និង សាឡុត ស ហៅថា ប៉ុល ពត។ ក្នុងសង្គ្រាមជាមួយខ្មែរសាធារណរដ្ឋ លន់ នល់ យៀកកុងបានស្លៀកពាក់ និងពាក់រូបឆាយល័ក្ខសម្តេចឪ ដើម្បីយកឈ្នះខាងចិត្តសាស្ត្រ បំភ័ន្តប្រជាពលរដ្ឋខ្មែរអោយគាំទ្រ ដោយក្លែងធ្វើជាកងទ័ពសីហនុ។ ក្រោយពីឈ្នះខ្មែរសាធារណះរដ្ឋយួនបានប្តូរខោអាវពីយៀកកុង ទៅស្លៀកពាក់ខោអាវខ្មៅបំភ័ន្តជាខ្មែរក្រហមវិញ រួមជាមួយក្រុមខ្មែរក្រហមដែលបណ្តុះបណ្តាលពីហាណូយបានសម្លាប់បញ្ញវ័ន្តខ្មែរ អ្នកប្រាជ្ញខ្មែរ អ្នកស្នេហាជាតិខ្មែរ ធ្វើអោយប្រទេសវិកវរនៅក្នុងរបប ប៉ុល ពត។ ក្រោយមក យួនបានផ្លាស់ប្តូរនយោបាយថ្មី បញ្ជូនកម្លាំងទ័ព ចូលមកឈ្លានពានខ្មែរកាន់កាប់ ទឹកដីខ្មែរនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ជម្លោះរវាង យួន និង ចិន បានធ្វើអោយយួនដោះដៃពីចិនហើយបានងាកទៅទំនាក់ទំនងជាមួយសូវៀត ចំណែកឯនយោបាយខ្មែរវិញ យួនបានប្តូរខ្មែរកុម្មុយនិស្តចាស់ដែលនិយមចិន និងលើកខ្មែរកុម្មុយនិស្តថ្មីនិយមយួន ដូចជា ហេង សំរិន ហ៊ុន សែន ជា ស៊ីម ជំនួសវិញ អោយកាន់អំណាចបំរើនយោបាយអោយខ្លួន។ ប្រទេសខ្មែរបានធ្លាក់ចូលទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី៣ រវាងយួនឈ្លានពាន និង របបកុម្មុយនិស្ត ហ៊ុន សែន ខុសច្បាប់ ជាមួយនិងក្រុមខ្មែរស្នេហាជាតិ ខ្មែរអ្នកតស៊ូតាមជាយដែន។ សង្គ្រាមនេះ មិនខុសពីសង្គ្រាមឥណ្ឌូចិនលើកទី ២ ដែលមានខ្មែរម្ខាងកុម្មុយនិស្តយួន សីហនុ និង ប៉ុល ពត (នៅទស្សវត្ស ៦០-៧០) ចំណែកខ្មែរម្ខាងទៀតខាងសេរី ខ្មែរសាធារណរដ្ឋ លន់ នល់ សេរីមតះឡើយ។ សង្គ្រាមនេះបានបន្តរហូតដល់សង្គ្រាមត្រជាក់រវាងកុម្មុយនិស្ត និងសេរី បញ្ចប់នៅឆ្នាំ ១៩៨៩។ យួនក៏បានដកកងទ័ពឯកសណ្ឋានយោធាចេញពីប្រទេសខ្មែរ តែបង្កប់ទុកកងទ័ពស្លៀកពាក់ស៊ីវិលត្រួតត្រាខ្មែរបន្តទៀត នៅក្នុងជួរគណបក្សប្រជាជន ហ៊ុន សែន ដោយមិនអនុញ្ញាតអោយអង្គការសហប្រជាជាតិត្រួតពិនិត្យឡើយ។ រហូតដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ខ្មែរបួនភាគីបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងសន្តិភាព

បើកឱកាសអោយយួនដោះដៃចេញពីឆាកអន្តរជាតិ រួចខ្លួនពីការចោទប្រកាន់ថា យួនឈ្លានពានខ្មែរ ព្រោះយួនមាន ហ៊ុន សែន និង សី ហនុ ជាកូនអុក ធ្វើអោយអន្តរជាតិមើលឃើញថា សង្គ្រាមដែលកើតមាននៅក្នុងប្រទេសខ្មែរ ជាសង្គ្រាមស៊ីវិលទៅវិញ។ នៅឆ្នាំ ១៩៩៣ ប្រទេសខ្មែរទទួលបានពន្លឺនៃលិទ្ធិប្រជាធិបតេយ្យ តាមរយៈការរៀបចំបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ។ ខណៈពេលនោះ អង្គការសហប្រជាជាតិមិនទាន់បញ្ចប់បេសកកម្មពេញលេញផង ស្រាប់តែពេលដែល ហ៊ុន សែន ចាញ់ឆ្នោតនៅឆ្នាំ១៩៩៣ ហ៊ុន សែន បានបង្កើតតំបន់អប្បគមន៍នៅត្រើយខាងកើត គំរាមធ្វើសង្គ្រាម ព្រោះ ហ៊ុន សែន សំអាងយួននៅពីក្រោយខ្នង ដែលកាលនោះមាននរោត្តមចក្រពង្ស ជាអ្នកដឹកនាំធ្វើ។ ស្តេច សីហនុ បានដេញអង្គការសហប្រជាជាតិអោយដកចេញពីប្រទេសខ្មែរ ហើយបែងចែកអំណាចអោយពួកកុម្មុយនិស្ត ហ៊ុន សែន ធ្វើជានាយករដ្ឋមន្ត្រីទី២។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋខ្មែរគ្មានវាសនាទទួលបាននូវសុខសន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ពិតប្រាកដ ដូចអ្វីដែលអង្គការសហប្រជាជាតិខិតខំនោះឡើយ ព្រោះនៅថ្ងៃ ៥-៦ កក្កដា ១៩៩៧ ជនផ្តាច់ការ ហ៊ុន សែន បានធ្វើរដ្ឋប្រហារដណ្តើមអំណាច សម្លាប់អ្នកស្នេហាជាតិខ្មែរ អ្នកប្រជាធិបតេយ្យ នៅក្នុងគណបក្សហ្វ៊ុនស៊ិនប៉ិច និង សមាជិកលោកតា សឺន សាន អស់ជាង ២៨០នាក់។ នេះជាមេរៀនខ្មែរត្រូវចងចាំថា ពួកកុម្មុយនិស្តមិនដែលចាត់ទុកខ្មែរអ្នកស្នេហាជាតិ ជាខ្មែរនោះទេ វាតែងតែស្តាប់ចៅហ្វាយយួនរបស់វា ប្រើល្បិចបោកប្រាស់ខ្មែរ អោយចូលទៅក្នុងទ្រុង បន្ទាប់មកគេចាប់សម្លាប់ខ្មែរតាមចិត្ត។ បញ្ហាទាំងនេះក៏ដោយសារការលង់ជឿមេដឹកនាំបោកប្រាស់ដូចជនកុម្មុយនិស្ត សី ហនុ ម្តងហើយម្តងទៀត។ ចំណែកការបោះឆ្នោតក្រោយៗមកជាបន្តបន្ទាប់ វាជាការរៀបចំរបស់គណបក្សប្រជាជន ដើម្បីបំភ័ន្តភ្នែកជាតិ និងអន្តរជាតិតែប៉ុណ្ណោះ លទ្ធផលបោះឆ្នោតទាំងអស់នោះ មិនមែនចេញពីឆន្ទៈប្រជាពលរដ្ឋខ្មែរពិតប្រាកដទេ។ ការរៀបរាប់បង្ហាញខាងលើបានសរអោយឃើញថា ប្រទេសខ្មែរបច្ចុប្បន្នកំពុងតែធ្លាក់ទៅក្នុងរបបផ្តាច់ការ ហ៊ុន សែន ក្រោមអាណានិគមន៍យួនបែបថ្មី ដែលធ្វើអោយប្រជាពលរដ្ឋខ្មែររងទុក្ខឥតល្ហែរហូតមកដល់ពេលនេះ។

# សេចក្តីថ្លែងអំណរគុណ (Acknowledgement)

ជាបឋមខ្ញុំសូមលើកហត្ថថ្វាយបង្គំ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ និងជាម្លប់ដ៏ត្រជាក់សំរាប់សង្គមជាតិខ្មែរគ្រប់សម័យកាល។ ខ្ញុំសូមក្រាបថ្វាយបង្គំ លោកឪពុក អ្នកម្តាយ ដែលជាអ្នកមានគុណដ៏លើសលុប បានផ្តល់កំណើតអោយកូនកើតជាជាតិខ្មែរ ចិញ្ចឹមបីបាច់ថែរក្សាកូន ដោយគ្មានគិតការនឿយហត់។ ខ្ញុំសូមថ្លែងអំណរគុណដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីផ្តល់ចំណេះដឹងដល់ខ្ញុំ និងសិស្សានុសិស្សគ្រប់រូប ដើម្បីជាប្រទីបមួយសំរាប់បំភ្លឺផ្លូវក្នុងជីវិត។ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណដល់បងប្អូនជនរួមជាតិខ្មែរ អ្នកស្នេហាជាតិខ្មែរទាំងអស់ដែលបានចូលរួមឧបត្ថមគាំទ្រ ដើម្បីអោយសៀវភៅនេះលេចចេញជារូបរាងឡើង ក្នុងការផ្តល់ចំណេះដឹងថ្មីៗ ដល់ប្រជាជាតិខ្មែរទាំងអស់ ដែលមិនធ្លាប់បានឃើញ មិនធ្លាប់បានឮពីរឿងរ៉ាវប្រទេសរបស់ខ្លួនកន្លងមក ដោយសារតែការលាក់បាំង ការបំភ័ន្តសំរាប់ចំណេញនយោបាយ ផលប្រយោជន៏ផ្ទាល់ខ្លួន អំណាច និងផែនការរបស់យួនហាណូយ ដើម្បីមកលេបយកទឹកដីខ្មែរយើងតែម្តង។

សៀវភៅ **ឫសគល់ ៧ មករា** ដែលខ្ញុំបានចងក្រងឡើងនេះ ជាការរំលឹកគុណដល់វីរភាពអ្នកស្នេហាជាតិខ្មែរគ្រប់សម័យកាល ដែលបានតស៊ូដើម្បីបុព្វហេតុជាតិខ្មែរ ទាំងអ្នកដែលបានបាត់បង់ជីវិត និងអ្នកដែលនៅមានជីវិតតែពិការ និងរងគ្រោះផ្សេងៗដោយសារពួកកុម្មុយនិស្តយួន និងហ៊ុន សែន។ វាជាកូនសៀវភៅតូច មួយសំរាប់រួមចំណែកក្នុងការផ្តល់ចំណេះដឹង ជាឯកសារសំរាប់អ្នកសិក្សាស្រាវជ្រាវ អោយយល់ដឹងបន្ថែមផ្នែក នយោបាយ ហើយជួយយកពតិមាននេះទៅផ្សព្វផ្សាយដល់ប្រជាជាតិខ្មែរទាំងអស់ អ្នកស្នេហាជាតិខ្មែរ អ្នកជាតិនិយម អ្នកប្រជាធិបតេយ្យ អោយមើលឃើញបញ្ហាពិតប្រាកដដែលបាននឹងកំពុងកើតមាននៅក្នុងសង្គមខ្មែរ។ អាស្រ័យហេតុនេះ យើងជាខ្មែរត្រូវហ៊ានងើបឡើង ប្តេជ្ញាចិត្តទាំងអស់គ្នាដោះស្រាយ ឫសគល់បញ្ហានេះអោយចប់ ហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បី បុព្វហេតុ ជាតិ សាសនា ប្រជាជាតិខ្មែរ របស់យើងដោយមិនបណ្តោយ អោយជនមួយក្តាប់តូច ដែលអោនក្បាលបំរើនយោបាយអោយយួនកុម្មុយនិស្ត ដូចគណបក្សប្រជាជន ហ៊ុន សែន លក់ជាតិ បំផ្លាញជាតិ អោយរលាយ តាមផែនការសហព័ន្ធឥណ្ឌូចិននោះឡើយ។

ចុងបញ្ចប់ខ្ញុំសូមឧទ្ទិសដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ដែលថែរក្សាប្រទេសខ្មែរ ជួយថែរក្សាបងប្អូនជនរួមជាតិខ្មែរ ជាពិសេសអ្នកស្នេហាជាតិខ្មែរទាំងអស់ ដែលហ៊ានងើបឡើងប្រឈមមុខដោះស្រាយបញ្ហាប្រទេសជាតិអោយបានសេចក្តីសុខចំរើន សុភមង្គល មានជីវភាពធូរធារ តាមការប៉ងប្រាថ្នា។ ចំពោះបងប្អូនជនរួមជាតិខ្មែរដែលលះបង់ជួយថតចំលងសៀវភៅនេះផ្សព្វផ្សាយបន្តអោយប្រជាពលរដ្ឋខ្មែរ សូមអោយអស់លោកទទួលបានបុណ្យកុសលច្រើន ជួបតែសុខសុភមង្គល រួចផុតពីទុក្ខវេទនានិងគ្រោះចង្រៃផ្សេងៗដែលកើតមានបច្ចុប្បន្ន និងអនាគត។

ធ្វើនៅទីក្រុងវ៉ាស៊ីនតោន ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៩

**បណ្ឌិត ស ធម្មរង្សី**

## មាតិកា


សេចក្តីផ្តើម ------------------------------------------------------------ ១

អារម្ភកថា ------------------------------------------------------------ ៤

សេចក្តីថ្លែងអំណរគុណ ------------------------------------------------------------ ៧

ជំពូកទី ១

ឫសគល់បញ្ហា

I-ដើមកំណើតខ្មែរកុម្មុយនិស្តនៅក្នុងប្រទេសខ្មែរ ----------------------------------------១១

II-ឫសគល់នៃរបបប្រល័យពូជសាសន៍ខ្មែរ ----------------------------------------២០

III-ហេតុអ្វីបានជាខ្មែរធ្លាក់ក្នុងរបបប្រល័យពូជសាសន៍ ----------------------------------------២១

IV-ឫសគល់ ថ្ងៃ ៧ មករា ----------------------------------------២៥

V-យួនកុម្មុយនិស្តឈ្លានពានត្រួតត្រាខ្មែរ ថ្ងៃ ៧ មករា ១៩៧៩ ----------------------------------------២៦

VI-សង្គ្រាមរវាងខ្មែរអ្នកតស៊ូ ជាមួយយួនឈ្លានពាន និងរបបកុម្មុយនិស្ត ហ៊ុន សែន ខុសច្បាប់-----------២៧

VII-សន្និសញ្ញាទីក្រុងប៉ារីស ----------------------------------------២៨

VIII-កំណើតលិទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសខ្មែរឡើងវិញ ----------------------------------------២៩

IX-ការធ្លាក់ចុះលិទ្ធិប្រជាធិបតេយ្យ ----------------------------------------៣០

X-ប្រទេសខ្មែរធ្លាក់ក្នុងរបបផ្តាច់ការ ហ៊ុន សែន ក្រោមអណានិគមន៍យួនបែបថ្មី -------------------- ៣១

XI-គ្មានតុល្យភាពខាងនិតិបញ្ញត្តិ និតិប្រតិបត្តិ និងតុលាការ ---------------------------------------- ៣២

១-ព័ត៌មាន ---------------------------------------- ៣២

២-ការអប់រំ ---------------------------------------- ៣៣

៣-ការបោះឆ្នោត ----------------------------------------៣៤

៤-សេរីភាពបញ្ចេញមតិ ----------------------------------------៣៤

៥-ច្បាប់ ----------------------------------------៣៥

XII-មេដឹកនាំផ្តាច់ការបច្ចុប្បន្នបានធ្វើអ្វីខ្លះ ប៉ះពាល់ប្រជាពលរដ្ឋ ----------------------------------------៣៥

១-ការបណ្តេញប្រជាពលរដ្ឋ រឹបអូសយកដី ----------------------------------------៣៥

២-អំពើពុករលួយ ----------------------------------------៣៦

៣-ភាពក្រីក្រ ---------------------------------------- ៣៧

៤-កាត់ទោសខ្មែរក្រហម ---------------------------------------- ៣៧

៥-អាណានិគមន៍យួនបែបថ្មី ----------------------------------------៣៩

៦-ធនធានធម្មជាតិ ----------------------------------------៣៩

## ជំពូកទី ២

## បញ្ចប់បញ្ហា

I-តើប្រជាពលរដ្ឋខ្មែរចង់បានអ្វី? ---------------------------------------------------- ៤២

II-តើខ្មែរត្រូវធ្វើអ្វីខ្លះដើម្បីជួយសង្គ្រោះខ្មែរ? ---------------------------------------------- ៤២

III-តើប្រជាពលរដ្ឋក្នុងតំបន់ដែលរងគ្រោះ ឡាវ ម៉ុង ចាម ខ្មែរ ត្រូវធ្វើដូចម្តេច? ---------------------៤៣

IV-តើសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ជួយអ្វីខ្លះដល់ប្រជាជាតិរងគ្រោះ? ---------------------៤៣

V- ប្រទេសខ្មែរត្រូវដឹកនាំតាមគោលការណ៍ប្រជាធិបតេយ្យឯករាជ្យពិតប្រាកដ - ------------------- ៤៤

១-និតិបញ្ញត្តិ ------------------------------------------------------------- ៤៥

២-តុលាការ ------------------------------------------------------------- ៤៥

៣-និតិប្រតិបត្តិ ------------------------------------------------------------- ៤៥

៤-ព័ត៌មាន ------------------------------------------------------------- ៤៥

៥-បំបាត់អំពើពុករលួយ ------------------------------------------------------- ៤៦

៦-បង្កើនជីវភាពប្រជាពលរដ្ឋ --------------------------------------------------- ៤៦

៧-គណបក្សនយោបាយ---------------------------------------------------------- ៤៦

៨-គណៈកម្មការរៀបចំបោះឆ្នោត ---------------------------------------------- ៤៦

៩-ជនអន្តោប្រវេសន៍ និងចារកម្មយួន ------------------------------------------- ៤៧

VI-ការសន្និដ្ឋាន ---------------------------------------------------------------- ៤៧

ឯកសារយោង ---------------------------------------------------------------- ៤៨

# ជំពូកទី ១

## ឫសគល់បញ្ហា (The Root of Problems)

### I. ដើមកំណើតខ្មែរកុម្មុយនិស្តនៅក្នុងប្រទេសខ្មែរ (Origin of Khmer Communism in Cambodia)

ក្នុងដំណាក់កាលដែលលិទ្ធិកុម្មុយនិស្តកំពុងតែរីករាលដាលខ្លាំងនៅទ្វីបអឺរ៉ុប កើតមានសង្គ្រាមលោកលើកទី ២ ហើយសង្គ្រាមនេះបានបញ្ចប់នៅឆ្នាំ ១៩៤៥។ អង្គការសហប្រជាជាតិត្រូវបានគេបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាពិភពលោក ក្នុងនោះមានប្រទេសសំខាន់៧ជាសមាជិកអចិន្រ្តៃយ៍ ដូចជា សហរដ្ឋអាមេរិក សហភាពសូវៀត ចិន អង់គ្លេស និងបារាំង។ ពិភពលោកបានធ្លាក់ទៅក្នុងសង្គ្រាមត្រជាក់។ កាលនោះពិភពលោកបានបែងចែកជាពីរ កុម្មុយនិស្ត និងសេរី។ ប្រទេសកុម្មុយនិស្តមានចំនួន ៩៧ ប្រទេស និងមួយចំនួនផ្សេងទៀតជា ប្រទេសកាន់លិទ្ធិប្រជាធិបតេយ្យសេរី។ កុម្មុយនិស្តមានប្រភពដើមចេញមកពីប្រទេសរ៉ូស្ស៊ី( លេនីន ស្តាលីន) អាឡឺម៉ង់ (អ៊ីង្គែល កាលម៉ាក្ស) អ៊ីតាលី អឺរ៉ុបខាងកើត បារាំង ចំណែកប្រទេសកាន់លិទ្ធិប្រជាធិបតេយ្យសេរីវិញគឺមាន សហរដ្ឋអាមេរិក អង់គ្លេស និងប្រទេសមួយចំនួនទៀត។ លិទ្ធិកុម្មុយនិស្តបានរីកសាយភាយនៅអឺរ៉ុបនិង មកតំបន់ អាស៊ី ក្នុងនោះមានប្រទេសចិន (ម៉ៅ សេទុង ) ប្រទេសយៀកណាម (ហូ ជីមិញ) និងប្រទេសខ្មែរជាដើម ដែលបានយកលិទ្ធិកុម្មុយនិស្តមកអនុវត្តន៏។ ប្រទេសខ្មែរបានធ្វើតាមមនោគមន៏កុម្មុយនិស្តពេលដែលយៀកណាមយកលិទ្ធិនេះមកផ្សព្វផ្សាយ ចាប់តាំងពីខ្មែរនៅក្នុងសម័យអាណានិគមនបារាំង។ នៅពេលនោះ យៀកណាមដឹកនាំដោយ ហូ ជីមិញ ធ្វើបដិវត្តន៏ផ្លាស់ប្តូរស្តេច បៅ ដាយ និងរំដោះប្រទេសអោយរួចចេញពីអាណានិគមន៏បារាំង។ ដោយរស់នៅក្រោមអាណានិគមន៏បារាំង គ្មានសិទ្ធិសេរីភាព ពិបាកវេទនា ពេលនោះស្តេចយួន បៅ ដាយ បានមានគតិបណ្ឌិតទុកថា ***ធ្វើជាប្រជារាស្ត្រសាមញ្ញក្នុងប្រទេសឯករាជ្យ មានសិទ្ធិសេរីភាពប្រសើរជាងធ្វើស្តេច មន្ត្រីក្រោមបរទេសត្រួតត្រា។*** ទើបនៅឆ្នាំ ១៩៤៥ បៅ ដាយ បានដាក់រាជ្យប្រគល់អោយ ហូ ជីមិញ ដឹកនាំ។ ហូ ជីមិញ បានផ្លាស់ប្តូររបបគ្រប់គ្រងពីរបបរាជានិយមទៅជាសាធារណរដ្ឋសង្គមនិយមយៀកណាម ហើយបន្តតស៊ូដេញបារាំងចេញពីទឹកដីរបស់ខ្លួន។ និស្សិតខ្មែរមួយចំនួន ដែលបានចេញទៅរៀននៅក្រៅប្រទេស ជាពិសេស និស្សិតដែលបានទៅសិក្សានៅប្រទេសបារាំង ដូចជា សាឡុត ស អៀង សារី បាននាំយកលិទ្ធិកុម្មុយនិស្តមកសាបព្រោះនៅក្នុងប្រទេសខ្មែរ។ លិទ្ធិកុម្មុយនិស្តនេះមិនមែនចេញពីឆន្ទៈនយោបាយរបស់ខ្លួនពិតប្រាកដ ដែលមានឥស្សរះភាព ឯករាជ្យ ដើម្បីផលប្រយោជន៏ជាតិខ្មែរឡើយ តែជាលិទ្ធិកុម្មុយនិស្តសាខារបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ដែលបានរៀបចំដឹកនាំដោយយួន ហូ ជីមិញ។ អ្នកដឹកនាំមានយួនឈ្មោះ ស៊ឹង ង៉ុកមិញ ហៅអាចារ្យ មៀន បន្លំខ្លួនធ្វើជាប្អូន ស៊ឹង ង៉ុកថាញ់ ជាប្រធានបក្សកុម្មុយនិស្តកម្ពុជា (សាខាបក្សកុម្មុយនិស្តឥណ្ឌូចិន)។ ទូ សាមុត និង សា ឡុតសរ បានចូលទៅធ្វើការក្រោមបក្សកុម្មុយនិស្តនោះ។ ពេលនោះហើយដែលយួនបានយកលិទ្ធិកុម្មុយនិស្តនេះ មកបណ្តុះបណ្តាលដល់កូនចៅខ្មែរ ដែលក្មេងខ្ចី មិនទាន់ដឹងអំពីប្រវត្តិសាស្ត្រ និងនយោបាយច្បាស់លាស់ ដើម្បីអោយខ្មែរបំរើនយោបាយរបស់គេ ក្នុងគោលបំណងត្រួតត្រាលេបទឹកដីខ្មែរ នៅតំបន់ឥណ្ឌូចិនទាំងមូល។

ក្នុងដំណាក់កាលដែលប្រទេសទាំងបី ខ្មែរ យៀកណាម ឡាវ នៅក្រោមអាណានិគមបារាំង ដោយមានជំនួយពីបក្សកុម្មុយនិស្តចិន គួមីងតាំង និងស្របពេលដែល ហូ ជីមិញ បានចូលជាសមាជិកបក្សកុម្មុយនិស្តអន្តរជាតិ យួនបានរៀបចំធ្វើបដិវត្តន៍មួយដើម្បីដេញបារាំងចេញពីទឹកដីឥណ្ឌូចិន។ យួនបានយកលិទ្ធិកុម្មុយនិស្តជាមធ្យោបាយ អំពាវនាវអោយប្រជាជនក្នុងតំបន់ចូលរួមតស៊ូដេញបារាំងចេញពីទឹកដីឥណ្ឌូចិន ដើម្បីប្រទេសទទួលបានឯករាជ្យ។ សូមបញ្ជាក់ថា មនោគមន៍កុម្មុយនិស្តដែលយួនបណ្តុះបណ្តាលខ្មែរនោះ គឺជាមនោគមន៍កុម្មុយនិស្តខុសទឹសសំរាប់បំរើនយោបាយអោយយួនប៉ុណ្ណោះ។ ការធ្វើដូចនេះ ព្រោះយួនចង់រំលើងជាតិខ្មែរអោយខ្សោយ ដូចជានៅក្នុងរបប ប៉ុល ពត ដើម្បីលេបយកទឹកដីខ្មែរ។ យួនកុម្មុយនិស្តបានចូលមកបញ្ចុះបញ្ចូលខ្មែរជាសម្ងាត់នៅក្នុងទឹកដីខ្មែរ បណ្តុះបណ្តាលខ្មែរនៅក្នុងទឹកដីខ្មែរ ដើម្បីអោយខ្មែរចូលជាសមាជិកបក្សកុម្មុយនិស្តយួនចាប់តាំងពីឆ្នាំ១៩៤៦ ។ ក្រោយមក យួនបានចាប់កូនខ្មែរចំនួន ៣ ៥00 នាក់ ទៅ ៤ 000 នាក់ យកទៅបណ្តុះបណ្តាលមនោគមន៏វិជ្ជាកុម្មុយនិស្តនៅទីក្រុងហាណូយ។ ពួកក្មេងខ្មែរទាំងនោះនៅក្មេងខ្ចីខាងប្រវត្តិសាស្ត្រ និងនយោបាយ ធ្វើអោយខ្មែរទាំងនោះលង់ក្នុងមនោគមន៍កុម្មុយនិស្តយួន ហើយបំរើនយោបាយអោយក្រុងហាណូយ កៀបសង្កត់ជិះជាន់ជាតិឯងជាបន្តបន្ទាប់មករហូតដល់សព្វថ្ងៃ។



*មេដឹកនាំយួន ឈ្មោះ ង្វៀង អៃកុក ( ហូ ជីមិញ)*

បក្សកុម្មុយនិស្តឥណ្ឌូចិនត្រូវបាន ហូ ជីមិញ បង្កើតឡើងនៅទីក្រុង ហុង កុង នាថ្ងៃ ៣ កុម្ភៈ ១៩៣0។ បក្សកុម្មុយនិស្តនេះមានការគាំទ្រពីចិន និងបក្សកុម្មុយនិស្តអន្តរជាតិរ៉ូស្ស៊ី។ ចិនបានបណ្តុះបណ្តាលកម្មាភិបាលយួនផ្តល់ជំនួយផ្នែកសេដ្ឋកិច្ច សម្ភារៈសព្វាវុធ និងផ្តល់កន្លែងហ្វឹកហាត់អោយ ហូ ជីមិញនៅភាគខាងត្បូងនៃប្រទេសចិនខាងជើងប្រទេសថៃ ប្រទេសលាវ ចំណែកឯរ៉ូស៊ីវិញជួយខាងហ្វឹកហាត់កម្មាភិបាលយួនសំខាន់ៗ។ ហូ ជីមិញបានយកលទ្ធិកុម្មុយនិស្ត ពីម៉ាក្ស លេនីន មកសាបព្រោះនៅតំបន់ឥណ្ឌូចិន ក្រោយពីខ្លួនបានចូលជាសមាជិកបក្សកុម្មុយនិស្តអន្តរជាតិមួយនេះ។ ហូ ជីមិញ បានដឹកនាំប្រទេសទាំង ៣ នៅឥណ្ឌូចិន ដើម្បីរំដោះប្រទេសចេញពីអាណានិគមន៍បារាំង និងផ្លាស់ប្តូរការដឹកនាំ ប្រទេសរបស់ខ្លួនពីរបបរាជានិយមទៅជារបបសាធារណរដ្ឋ

សង្គមនិយម ដែលកាលនោះ ប្រទេសយៀកណាមស្ថិត នៅក្នុងការដឹកនាំរបស់ស្តេច បៅ ដាយ នៅឡើយ។ ទីបញ្ចប់ ហូ ជីមិញ បានទទួលជ័យជំនះស្តេចលើ បៅ ដាយ នៅឆ្នាំ១៩៤៥ ប្តូរប្រទេសទៅជាសាធារណរដ្ឋ។ ហូ ជីមិញ បានបន្តនយោបាយរបស់ខ្លួនដើម្បីដេញអាណានិគមន៍ បារាំងចេញពីឥណ្ឌូចិនទៀត។ ហូ ជីមិញ មានឈ្មោះទាំងអស់ ១៩ និងជាអ្នកមានប្រជាប្រិយមួយរូបក្នុងចំណោមប្រជាជនវៀតណាម ។ ហូ ជីមិញ កើតនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៨៩០ នៅក្នុងភូមិ គីម លៀន ក្នុងខេត្ត ញេអាន ប្រទេសយៀកណាម។ នៅឆ្នាំ ១៩១១ ហូ ជីមិញ បានចាកចេញពីប្រទេសវៀតណាមទៅប្រទេសបារាំងតាមកាប៉ាល់ទឹក ដោយធ្វើជាចុងភៅរបស់បារាំង។ ហូ ជីមិញ បានក្លាយជាសមាជិកបក្សកុម្មុយនិស្តបារាំងនៅឆ្នាំ ១៩២០ ហើយបានប្តូរឈ្មោះទៅជា ង្វៀង អៃកុក មានន័យថា អ្នកស្នេហាជាតិ។ នៅឆ្នាំ ១៩២១-១៩២៩ ហូ ជីមិញ បានចូលរួមសកម្មភាពនយោបាយជាមួយបក្សកុម្មុយនិស្តអន្តរជាតិ និងផ្សព្វផ្សាយសៀវភៅមួយមានចំណងជើងថា **ផ្លូវបដិវត្តន៍** នៅឆ្នាំ ១៩២៧។ នៅឆ្នាំ ១៩២៣ ហូ ជីមិញ បានទៅសហភាពសូវៀត ដើម្បីស្វែងរកការគាំទ្រ អំពីបុព្វហេតុនៃការតស៊ូរបស់គាត់ក្នុងចំណោមជនជាតិ យៀកណាម ដែលជាអ្នកប្រឆាំង ហើយបាននិរទេសទៅក្រៅប្រទេស។ ហូ ជីមិញក៏បានធ្វើដំណើរទៅកាន់ប្រទេសចិន ភូមា និងឥណ្ឌាផងដែរ។ ចលនានយោបាយ យួនយៀកមិញបានចូលមកធ្វើចលនាស្ងាត់ៗនៅទឹកដីខ្មែរ ដែលកាលនោះមានយួនភាគច្រើន ធ្វើជាកម្មករកៅស៊ូ តែពួកគេជាជនកុម្មុយនិស្តដំបូង ចូលមកធ្វើចលនានយោបាយនៅប្រទេសខ្មែរ ដូចជានៅតាមខេត្តកំពង់ចាម ខេត្តកំពត និងខេត្តមួយចំនួនទៀត។ យួនបានចាប់ផ្តើមធ្វើការឃោសនា និងធ្វើចិត្តសាស្ត្រជាមួយខ្មែរ ដែលធ្វើកម្មករនៅទីនោះ ដើម្បីអោយខ្មែរចូលជាសមាជិករបស់បក្សកុម្មុយនិស្តឥណ្ឌូចិន បំរើនយោបាយអោយពួកកុម្មុយនិស្តយួន។ តាមរយៈការឃោសនាយួនកុម្មុយនិស្ត (យៀកមិញធ្មេញខ្មៅ) ខ្មែរមួយចំនួនបានលង់ជឿ ចូលបំរើសកម្មភាពនយោបាយអោយបក្សកុម្មុយនិស្តយួននោះ។ នៅ ចន្លោះឆ្នាំ ១៩៤៦-១៩៥៤ ក្មេងខ្មែរ ជាច្រើនពាន់នាក់ ៣៥០០-៤០០០នាក់ ត្រូវបានគេចាប់យកទៅបំពាក់បំប៉នមនោគមន៍កុម្មុយនិស្តពីក្រុងហាណូយ ដែលពេលនោះ ខ្មែរហៅថាប្រម៉ាត់ប្រម៉ង់ ក្រោយៗមកទៀតយួននៅតែបន្តយកកូនខ្មែរទៅបណ្តុះបណ្តាលជាបន្តបន្ទាប់។ ហូ ជីមិញ បានធ្វើការតស៊ូជាមួយបារាំងរហូតដល់ឈ្មោះសង្គ្រាមនៅ ឌៀន បៀនភូ នៅឆ្នាំ ១៩៥៤ ហើយបានចាប់ទាហានបារាំងជាចំណាប់ខ្មាំង បង្ខំអោយបារាំងចុះហត្ថលេខា ប្រគល់ឯករាជ្យមកអោយឥណ្ឌូចិន នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤។ យួនចាប់ផ្តើមបន្តធ្វើនយោបាយ ដើម្បីត្រួតត្រាឥណ្ឌូចិនជំនួសបារាំងបន្តទៀត។



*កូនខ្មែរដែលយួនកុម្មុយនិស្ត បំពាក់បំប៉នមនោគមន៍កុម្មុយនិស្ត អោយសម្លាប់ខ្មែរ*

ចំណែកនិស្សិតខ្មែរដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងវិញ ដូចជា សា ឡុត សរ អៀង សារី ជួន មុំ ហ៊ូ នឹម ហ៊ូ យន់ បានចាប់អារម្មណ៍និងសៀវភៅក្រហមរបស់កុម្មុយនិស្ត ម៉ាក្ស លេនីន ដែលកាលនោះទ្រឹស្តីកុម្មុយនិស្តកំពុងតែមានប្រជាប្រិយនៅទ្វីបអឺរ៉ុប។ នៅពេលនោះនិស្សិតខ្មែរទាំងអស់នោះបានចាប់យកលិទ្ធិកុម្មុយនិស្ត ធ្វើការប្រឆាំងនយោបាយជាមួយរបបសក្តិភូមិរបស់សម្តេច សី ហនុ ។ ទីបំផុត នរោត្តម សីហនុ បានកាត់ផ្តាច់អាហារូបករណ៍របស់និស្សិតមួយចំនួន ក្នុងនោះមាន សា ឡុតសរ ដែលជាអ្នកប្រឆាំង នរោត្តម សីហនុ ។ នៅឆ្នាំ ១៩៥១ ពេលដែល សា ឡុតសរ ត្រឡប់មកប្រទេសខ្មែរវិញទាំងមិនទាន់រៀនចប់ផ្នែកខាងអេឡិចត្រូនិចផងនោះ សា ឡុតសរ បានធ្វើជាគ្រូបង្រៀន និងបង្កើតសាលារៀនឯកជនឈ្មោះកម្ពុជបុត្រ។ សា ឡុតស បានធ្វើចលនានយោបាយប្រឆាំងនរោត្តមសីហនុជាសម្ងាត់ ។ ពេលដែលបែកការណ៍ នរោត្តម សីហនុ បានប្រកាសចោទប្រកាន់ដេញចាប់ សា ឡុតសរ និងបក្សពួកមួយចំនួន បន្ទាប់មកក្រុមរបស់គាត់បានរត់ចូលព្រៃ ចូលរួមតស៊ូជាមួយបក្សបដិវត្តន៍ប្រជាជនកម្ពុជា ដែលជាសាខារបស់បក្សកុម្មុយនិស្តឥណ្ឌូចិន។ បក្សបដិវត្តន៍ប្រជាជនកម្ពុជានេះ ដឹកនាំដោយយួនឈ្មោះ ស៊ឺង ង៉ុកមិញ ហៅថា អាចារ្យ មៀន ដែលបន្លំធ្វើជាខ្មែរ។ ការដែលយួនដាក់ឈ្មោះ ស៊ឺង ង៉ុកមិញ គឺដើម្បីបំភ័ន្តខ្មែរថាជាប្អូនរបស់ ស៊ឺង ង៉ុកថាញ់ មកដឹកនាំខ្មែរ ពីព្រោះ ស៊ឺង ង៉ុកថាញ់ ជាមេដឹកនាំខ្មែរ មានប្រជាប្រិយមួយរូបដែលប្រជាពលរដ្ឋខ្មែរស្គាល់ថាជាអ្នកស្នេហាជាតិខ្មែរនាសម័យនោះ។ បក្សបដិវត្តន៍ប្រជាជនខ្មែរនោះ បានក្លាយជាគណបក្សប្រជាជនកម្ពុជាដឹកនាំដោយ ហេង សំរិន ជា ស៊ីម ហ៊ុន សែន នាពេលបច្ចុប្បន្ននេះ។ ដូចនេះ តាមការសង្កេតឃើញថា នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០០៩ ជាឆ្នាំគំរប់ខួបទី ៥៨ របស់គណបក្សប្រជាជនកម្ពុជា។

ក្រោយពីសិទ្ធិសញ្ញា ទីក្រុងហ្សឺណែវ ប្រទេសទាំងបី ខ្មែរ ឡាវ យួន នៅឥណ្ឌូចិនបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៤។ យៀកមិញដែលនៅក្នុងប្រទេសខ្មែរ ត្រូវបានគេតំរូវអោយដកចេញពីប្រទេសខ្មែរ។ ពេលដែលយួនយៀកមិញដកចេញទៅ យួនបានចាប់យកកូនខ្មែរមួយចំនួនទៅបំពាក់បំប៉នមនោគមន៍កុម្មុយនិស្តខុសទឹស និងខ្មែរមួយចំនួនបានទៅតាមកប៉ាល់យួន។ ខ្មែរទាំងអស់នោះហើយ ដែលយួនបញ្ជូនមកប្រទេសខ្មែរវិញ ដើម្បីធ្វើជាពិជឃាតសម្លាប់ខ្មែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ *ខ្មែរដែលយួនបណ្តុះបណ្តាលទាំងអស់នោះហើយ ជាឫសគល់នៃការប្រល័យពូជសាសន៍ខ្មែរ ធ្វើអោយប្រជាពលរដ្ឋខ្មែរប្រមាណជាង ១.៧ លាននាក់ស្លាប់ (១៩៧៥-១៩៧៩)។* ចំណែកឯវាសនាកូនខ្មែរទាំងអស់នោះ ក៏ត្រូវយួនរៀបចំផែនការសម្លាប់បំបិទភស្តុតាងជាបន្តបន្ទាប់ ក្រោយពីយួនប្រើប្រាស់អស់ផលប្រយោជន៍ហើយ ដើម្បីកុំអោយខូចផែនការក្រុងហាណូយ ដែលមានបំណងលេបទឹកដីខ្មែរ។

នៅឆ្នាំ ១៩៥៨ យួនកុម្មុយនិស្តបានចាប់ផ្តើមធ្វើសង្គ្រាមជាមួយយួនខាងត្បូងទៀត ដោយមានគោលការណ៍ថា ដើម្បីបង្រួបបង្រួមប្រទេសទាំងពីរ រវាងយៀកណាមខាងជើង និងយៀកណាមខាងត្បូង។ តែតាមការពិត សង្គ្រាមនេះយួនមានគោលបំណងពង្រីកទឹកដី វាតទីនៅតំបន់ឥណ្ឌូចិនតែប៉ុណ្ណោះ។ យួន

កុម្មុយនិស្តបានចោទយួនខាងត្បូងដែលដឹកនាំដោយ ង៉ោ ឌិញយីម ថាជាអាយ៉ងបរិវារបស់អាមេរិកកាំង។ យួនយៀកកុងសុំអោយខ្មែរជួយផ្តល់ជំរកដល់ទ័ពយៀកកុងជ្រកនៅលើទឹកដីខ្មែរភាគខាងកើត ដើម្បីធ្វើសង្គ្រាមដេញអាមេរិកកាំង។ ក្រោមលេសថា ធ្វើសង្គ្រាមដេញអាមេរិកាំង ពួកប្រតិកិរិយាចេញពីទឹកដីឥណ្ឌូចិន សី ហនុ បានចុះហត្ថលេខាស្ងាត់ៗជាមួយ ហូ ជីមិញ នៅឆ្នាំ១៩៦៥ អនុញ្ញាតអោយយួនដាក់កងទ័ពយៀកកុងនៅក្នុងទឹកដីខ្មែរភាគខាងកើតមាន ខេត្តក្រចេះ មណ្ឌលគីរី ព្រៃវែង ស្វាយរៀង និងកំពង់ចាមជាដើម។ យួនដាក់ទ័ពនេះដោយសុំអោយខ្មែរជួយ ដើម្បីវាយយួនខាងត្បូង និងដេញអាមេរិកាំងចេញ តែនេះជាល្បិចខ្ចីផ្លូវដើរ ដើម្បីខ្ចប់យកបូរីរបស់យួនកុម្មុយនិស្តតែប៉ុណ្ណោះ ព្រោះថាយួនបានពង្រីកសង្គ្រាម នោះធ្លាក់មកលើប្រទេសខ្មែរ។ សមរភូមិសង្គ្រាមពិតប្រាកដគឺ ទឹកដីខ្មែរ ព្រោះមូលដ្ឋានទ័ពព្រៃយួនយៀកកុងតាំងនៅលើទឹកដីខ្មែរ ហេតុនេះ ទាំងយួនខាងត្បូង និងអាមេរិកាំងបានវាយលុកចូលមកក្នុងទឹកដីខ្មែរ ធ្វើអោយប្រជាពលរដ្ឋខ្មែរស្លាប់បាត់បង់ជីវិត និងរងគ្រោះយ៉ាងខ្លាំង។

នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៦៩ ហូ ជីមិញ បានទទួលមរណភាព ហើយសាកសពត្រូវបានគេរក្សាទុករហូតមកដល់បច្ចុប្បន្ន។ មេដឹកនាំខ្មែរមាន សីហនុ និង ហ៊ុន សែន ក៏អោនក្បាលគោរពសពហូជីមិញដែរ។ នៅផ្ទះ ហ៊ុន សែន បានរៀបចំអាសនៈដាក់តាំងរូប ហូ ជីមិញ ថ្វាយបង្គំ ប្រៀបបានដូចជាព្រះពុទ្ធ។



សីហនុ កំពុងគោរពខ្មោចហូជីមិញ

សង្គ្រាមឥណ្ឌូចិនលើកទី២ នេះ យួនទទួលបានផលប្រយោជន៍ជាច្រើន ផលប្រយោជន៍ទាំងនោះ មានដូចជា ផ្នែកហិរញ្ញវត្ថុ ផ្នែកសម្ភារៈ និងសព្វាវុធ និងទឹកដីខ្មែរ។ល។ កាលដែលហូជីមិញត្រូវស្លាប់ ពីព្រោះយួនត្រូវដោះដៃចេញពីចិន ដោយមិនបានសងបំណុលផ្សេងៗទៅប្រទេសចិន ដែលជួយយួនតាំងពីឆ្នាំ ១៩៣០ ។ យួនបានផលប្រយោជន៍ពីជំនួយពីអាមេរិកាំង ដែលជួយយួនខាងត្បូង ង៉ោ ឌិញយីម និងចំណេញទឹកដីខ្មែរ ខ្មែរក្រោម ទឹកដីលាវ។ ដើម្បីការពារផលប្រយោជន៍ទាំងអស់នេះ យួនបានងាកទៅចងសម្ព័ន្ធជាមួយសហភាពសូវៀតវិញ។ ដូចនេះយើង សង្កេតឃើញថា យួនទទួលបានផលប្រយោជន៍ជាច្រើនពីមហាអំណាចទាំង៣ ហើយ និងផលប្រយោជន៍ពីប្រទេសតូចៗ ដូចជា លាវ ខ្មែរ និងចាមជាដើម។ ក្នុងពេលសង្គ្រាមនោះ យួនយៀកកុងបានជំរិតសេដ្ឋកិច្ចខ្មែរ តាមការបោះពុម្ពលុយក្លែងក្លាយ ទិញទំនិញខ្មែរ បាញ់គោក្របីខ្មែរ ធ្វើជាចំណីអាហារ (ខ្ចីដី និងសេដ្ឋកិច្ចខ្មែរ ដើម្បីចិញ្ចឹមកងទ័ព)។ ចំណែកយួនខាងត្បូងវិញ បានទទួលជំនួយពីអាមេរិកកាំង និងកាន់កាប់ទឹកដីខ្មែរនៅកម្ពុជាក្រោម។ ហូជីមិញ សុខចិត្តលះបង់ជីវិតស្លាប់នៅឆ្នាំ ១៩៦៩ ដើម្បីផលប្រយោជន៍ជាតិ យៀក

ណោមទាំងមូល ដោយមិនចាំបាច់សងសំណងទាំងឡាយទៅអោយចិន និងអាមេរិកហើយផ្លាស់នយោបាយ ងាកទៅរកប្រទេសរ៉ូស៊ី ដើម្បីប្រឆាំងនិងសហរដ្ឋអាមេរិក និងបំបាត់កិច្ចសន្យាវវាង សី ហនុ និង ហូ ជីមិញ ដើម្បីបានគ្រប់គ្រងលេបទឹកដីខ្មែរទៀតផង ។



*សីហនុ ជួយផ្ដល់ស្បៀងអោយយួន និង ផ្ដល់ជំរកអោយយួន ( កុម្មុយនិស្ត ) ឬ យៀកកុង*

ហូ ជីមិញ ជាសមាជិកកុម្មុយនិស្តអន្តរជាតិ គូ មីងតាំង ។ ដើម្បីពង្រីកកុម្មុយនិស្តនៅតំបន់អាស៊ី ហូជីមិញ ជាសមាជិកមួយរូបរបស់បក្សកុម្មុយនិស្តអន្តរជាតិដែលរៀបចំបង្កើតដោយចិន បានទៅប្រទេសថៃ ម៉ាឡេស៊ី និងសិង្ហបូរី ដើម្បីធ្វើជាអធិបតីក្នុងការបង្កើតសាខាបក្សកុម្មុយនិស្តនៅក្នុងប្រទេសទាំងនេះ ។ សហភាពសូវៀតបានប្រគល់អោយ ហូ ជីមិញ ទទួលខុសត្រូវបង្កើតសាខាបក្សកុម្មុយនិស្តនៅក្នុងប្រទេសខ្មែរ និងឡាវ ដែលជាផ្នែកមួយនៃបក្សកុម្មុយនិស្តអន្តរជាតិ តាមការយល់ព្រមផ្ដល់មូលនិធិដោយសហភាពសូវៀត ។ អ្វីដែលជាផែនការរបស់ ហូ ជីមិញ បង្កើតឡើងដើម្បីពង្រីកទឹកដីវៀតណាមអោយធំដោយឈ្លានពានប្រទេសខ្មែរ លាវ ហើយក្រោយមកទៀត ប្រទេសនៅអាស៊ីអាគ្នេយ៍ ដូចអ្វីដែលស្តាលីន និងរ៉ូស៊ីបានធ្វើឡើង ចំពោះប្រទេសជិតខាងរបស់គេក្នុងការបង្កើតសហភាពសូវៀតដែរ ។ នៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី ២ ដោយមានជំនួយឧបត្ថម្ភនិងអនុញ្ញាតពីនរោត្តម សីហនុ យួនបានជ្រៀតចូលទឹកដីខ្មែរកាន់តែជ្រៅទៅពាសពេញទឹកដីខ្មែរ ដោយយួនបានខ្ចីទឹកដីខ្មែរដើម្បីធ្វើជាសមរភូមិប្រយុទ្ធ បោះពុម្ពលុយក្លែងក្លាយ ដើម្បីទិញទំនិញសាច់ស្បៀង ដូចជា អង្ករ ជ្រូក គោ យកទៅចិញ្ចឹមកងទ័ពគេ ។ ចំណែក សី ហនុ មិនបាននៅដោះស្រាយបញ្ហាដែលកំពុងតែវិកវរនៅក្នុងប្រទេសទេ ដូចជាបាតុកម្មដុតស្ថានទូតយៀកកុង យៀកកុងនៅពាសពេញប្រទេស ដោយត្រូវមហេសី ម៉ូនិច និង ម្ដាយក្មេក នាំទៅកំសាន្តនៅប្រទេសបារាំងទៅវិញ ។ តំណាងរាស្ត្រ ២ រូបបានទៅយាងព្រះអង្គមកពីប្រទេសបារាំង ដើម្បីដោះស្រាយបញ្ហាទាំងឡាយ ដែលព្រះអង្គបានបង្កើតឡើង ដូចជាកងទ័ពយៀកកុងលុកលុយចូលទឹកដីខ្មែរភាគខាងកើត និងពីកំពង់សោម រហូតមកដល់កំពង់ស្ពឺជាដើម ។ ប៉ុន្តែព្រះអង្គមិនព្រមយាងត្រឡប់មកវិញ ដោយស្ដាប់តាមយោបល់ម្ដាយក្មេក និងមហេសី ដែលលើកជើងបញ្ជោរថា ព្រះអង្គជាអ្នកមានបុណ្យ ជាព្រះបាទធម្មិក គ្មាននរណាធ្វើអ្វីកើតទេ ។ ទោះជាព្រះមាតា កុសមៈ ទូរស័ព្ទទៅដើម្បីយាងមកក៏ដោយ ក៏សីហនុចចេស មិនស្ដាប់

យោបល់អ្នកណាទាំងអស់។ ហេតុនេះហើយទើប លន់ នល់ សេរីមតៈ បានទំលាក់សម្តេច សីហនុ នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧០ ដោយការបោះឆ្នោតដកសេចក្តីទុកចិត្តពីសភា ដើម្បីដោះស្រាយបញ្ហាកងទ័ពយួនយៀកុង ដែលកំពុងតែឈ្លានពានលើទឹកដីខ្មែរភាគខាងកើតនៃប្រទេស។ ក្រោយពី សី ហនុ ធ្លាក់ពីអំណាចព្រះអង្គមិនព្រមគង់នៅស្ងៀមនោះទេ ទោះជាគេសន្យាថានិងប្រគល់អំណាចមកអោយព្រះអង្គវិញ ក្រោយពីដោះស្រាយបញ្ហាយៀកកុងឈ្លានពានចេញពីទឹកដីចប់ក៏ដោយ។ ព្រះអង្គបានយាងទៅប្រទេស រ៉ូស៊ី និង ប្រទេសចិន ដើម្បីស្វែងរកការគាំទ្រ។ ពេលនោះចិនបានគាំទ្រ យួនជាអ្នកជួយពីក្រោយខ្នង សន្យាដណ្តើមរាជបល្ល័ង្គមកអោយព្រះអង្គវិញ។ តាមការញុះញង់របស់ពួកកុម្មុយនិស្ត សីហនុ អោយបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧០ ដោយព្រះអង្គជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា រួមជាមួយពួកខ្មែរក្រហម ដែលដឹកនាំដោយ ប៉ុល ពត អៀង សារី ខៀវ សំផន។ ចំណែកឯយួនកុម្មុយនិស្តវិញ ជាអ្នកជួយខ្មែរក្រហមខាងគ្រាប់រំសេវកាំភ្លើងតូច ធំ ស្បៀង កម្លាំង និងការហ្វឹកហ្វឺនធ្វើអោយមានជ័យជំនះលើខ្មែរសាធារណរដ្ឋ នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ ក្រោយពីទទួលបានជ័យជំនះលើពួកសារធារណរដ្ឋខ្មែរ លន់ នល់ យួនបានលើកអំណាចអោយខ្មែរក្រហម (ខ្មែរកុម្មុយនិស្ត)។ យួនដែលបានក្លែងភេទទៅជាខ្មែរ និងខ្មែរដែលយួនបំពាក់បំប៉នមនោគមន៍កុម្មុយនិស្តនោះ បានទទួលបញ្ជាពីហាណូយ អោយមកបោសសំអាតខ្មែរសាធារណរដ្ឋដែលប្រឆាំងយួន ជាហេតុនាំអោយមានរបបប្រល័យពូជសាសន៏ខ្មែររាប់លាននាក់កើតមាននៅក្នុងប្រទេសខ្មែរ និងខ្មែរនៅកម្ពុជាក្រោមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីចាប់ខ្មែរអ្នកប្រឆាំងនិងយួនកុម្មុយនិស្ត គេរកលេសចោទប្រកាន់ទំលាក់កំហុស ដូចជា គេចោទប្រកាន់ថាភ្នាក់ងារ ស៊ី អាយ អេ របស់អាមេរិក កា សេ បេ ឬខ្មាំងរបស់បដិវត្តន៏ ហើយចាប់យកទៅសម្លាប់ ។ ខ្មែរភាគច្រើននៅក្នុងសាធារណរដ្ឋខ្មែរ មាននិស្សិត បញ្ញវន្ត អ្នកស្នេហាជាតិ ត្រូវគេកាប់សម្លាប់អស់នៅក្នុងរបបនោះ។ របបប្រល័យពូជសាសន៏នេះ ធ្វើអោយខ្មែរខូចឈ្មោះយ៉ាងខ្លាំងនៅលើឆាកអន្តរជាតិ ថាខ្មែរជាតិសាសន៏ឃោឃៅ សម្លាប់ជាតិសាសន៏ឯង ចំណែកឯយួនចំណេញទាំងទឹកដី និងទ្រព្យសម្បត្តិខ្មែរ ដោយថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ យួនបានចូលមកប្តូរនយោបាយថ្មី លើកបន្តុបខ្មែរវៀតមិញ ដែលយួនបានបណ្តុះបណ្តាល ដូចជា ប៉ែន សុវណ្ណ ចាន់ ស៊ី ហេង សំរិន ហ៊ុន សែន ជា ស៊ីម អោយធ្វើតាមនយោបាយរបស់ខ្លួន។

*ថ្ងៃ ៧ មករា ១៩៧៩ មិនមែនជាថ្ងៃដែលយួនរំដោះខ្មែរទេ ប៉ុន្តែជាថ្ងៃដែលយួនឈ្លានពានខ្មែរ ប្លន់ទ្រព្យសម្បត្តិខ្មែរ បន្តកាប់សម្លាប់ខ្មែរតាមយុទ្ធសាស្ត្រ ដោយចោទថា ប៉ុល ពត និងបព្ជូនខ្មែរអោយស្លាប់នៅ តំបន់ ក ៥ទៀត*។ យួនបានដាក់កងទ័ព ១២០ ០០០ នាក់ ធ្វើអាណានិគមន៏លើទឹកដីខ្មែរ ហើយកែប្រែនយោបាយតាមស្ថានការណ៏ ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។ ពួកកុម្មុយនិស្តដែលប្រឆាំងយួន(ខ្មែរក្រហម) ត្រូវផ្លាស់ប្តូរថ្មីដោយពួកកុម្មុយនិស្ត(ខ្មែរក្រហម)និយមយួន ហើយយួនហាណូយលើកបន្តុបអោយកាន់អំណាច ដូចមានពួក ហ៊ុន សែន ហេង សំរិន និងជា ស៊ីម ដែលឥឡូវនេះ ពួកនេះកំពុងតែត្រួតត្រាប្រទេសខ្មែរ។

*ដូចនេះបក្សកុម្មុយនិស្តឥណ្ឌូចិន ហូ ជីមិញ បានចាប់ផ្តើមនយោបាយអាណានិគមន៍បែបថ្មីលើប្រទេសខ្មែរ និង ប្រទេសលាវ ដោយចាត់ទុកជនជាតិវៀតណាមភាគច្រើនដែលរស់នៅក្នុងប្រទេសទាំងនេះ ជាជនជាតិខ្មែរ ឬ ជនជាតិលាវ* ។ ការអនុវត្តផែនការដើម្បីត្រួតត្រាខ្មែរនេះ គេបានបញ្ចូលភ្នាក់ងារយួនកុម្មុយនិស្តដែលបានអប់រំបណ្តុះបណ្តាលនៅហាណូយរួចហើយ ដើម្បីបង្កើតមុខរបរផ្សេងៗដោយខ្លួនគេនៅក្នុងប្រទេសទាំងនេះ ហើយឥឡូវនេះកូនប្រុស និងកូនស្រីរបស់ជនជាតិវៀតណាមទាំងនោះបានរៀបចំដឹកនាំរបៀបកុម្មុយនិស្តនៅក្នុងប្រទេសខ្មែរ និងលាវ។ ក្រោយពីចប់សង្គ្រាមឥណ្ឌូចិនលើកទី ៣ យួនបានរក្សាទុកកងទ័ពយួននៅក្នុងប្រទេសលាវ មានចំនួនយ៉ាងច្រើនដើម្បីជួយកុម្មុយនិស្តប្រទេសឡាវ ក្នុងការបង្ក្រាបពួក ម៉ុង ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ ចំណែកប្រទេសខ្មែរវិញ ក្រោយពីការចរចារគ្នា និងចុះហត្ថលេខា លើសន្ធិសញ្ញាក្រុងប៉ារីស ២៣ តុលា ១៩៩១ យួនបានដកតែកងទ័ពឯកសណ្ឋាន ដោយយួនបានបង្កប់ទុកកងទ័ពស៊ីវិលជាច្រើនធ្វើការនៅក្នុងក្រសួងសំខាន់ៗ នៅក្នុងប្រទេសខ្មែរ តាមការអនុញ្ញាតដោយគណបក្សប្រជាជនកម្ពុជា ក្នុងការបង្ក្រាបពួកអ្នកប្រឆាំងនិងយួនកុម្មុយនិស្ត ។ ចំពោះប្រជាជនយួនបានហូរមករស់នៅលើទឹកដីខ្មែរ ជាជនអន្តោប្រវេសន៍ខុសច្បាប់យ៉ាង អាណាធិបតេយ្យ មានអត្តសញ្ញាណប័ណ្ណជាជនជាតិខ្មែរទៀតផង ដូចជានៅ បឹងទន្លេសាប ច្បារអំពៅ អ្នកលឿង ក្រចេះ កំពង់ឆ្នាំង និងកំពង់ចាមជាដើម។ ការបង្ក្រាបរបស់យួនកុម្មុយនិស្តទៅលើពួកប្រឆាំងទាំងពីរប្រទេសដែលគេចោទថាជាបរិវារអាមេរិកាំង ឬពួកប្រតិកិរិយា គឺគេធ្វើដល់ឬសគល់វាតែម្តង ដែលមានពាក្យស្លោកគេនិយាយថា *ដឹកស្មៅដឹកទាំងឫស* មានន័យថាសម្លាប់អ្នកប្រឆាំង បរិវារអាមេរិកកាំងអោយអស់ នេះជាពាក្យមនោគមន៍ដែលយួនសាបព្រោះលើខ្មែរ ដើម្បីអោយខ្មែរសម្លាប់ខ្មែរ ដោយមិនដឹងខ្លួន តែផ្ទុយទៅវិញ យួនជាអ្នកចំណេញក្នុងការលេបទឹកដីខ្មែរ ពេលដែលអ្នកប្រាជ្ញ បញ្ញវន្តខ្មែរស្លាប់អស់។




*ប្រធានាធិបតីអាមេរិក រីឆាត និចសុន ពន្យល់ពីការឈ្លានពានរបស់យួនកុម្មុយនិស្តនៅឥណ្ឌូចិន*

បច្ចុប្បន្ននេះ យួនបានបន្តនយោបាយកុម្មុយនិស្តឥណ្ឌូចិនរបស់ ហូ ជីមិញ ដើម្បីត្រួតត្រាខ្មែរ និង លាវ ដោយធ្វើអោយគេមើលឃើញថា ប្រទេសលាវជាខេត្តមួយរបស់យួនខាងជើង។ ចំណែកប្រទេសខ្មែរវិញ យួនបានរក្សាទុកកងទ័ពស្លៀកពាក់ស៊ីវិលចំនួន ៣០០០ នាក់ ដោយរួមបញ្ចូលទាំងភ្នាក់ងារចារកម្ម និងកម្លាំងពិសេសដែលមានរថក្រោះ និងឧទ្ធម្ភាគចក្រស្ថិតនៅចំងាយប្រមាណ ២ គីឡូម៉ែត្រកន្លះនៅក្រៅទីក្រុងភ្នំពេញ ជាប់ទួល

ក្រសាំង ក្បែរតាខ្មៅ ជាពិសេសទាហានយួន ដែលស្លៀកពាក់ស៊ីវិលមកធ្វើជាកម្មករចំការកៅស៊ូ និងតាមរយៈរូបភាព ក្រុមហ៊ុនវិនិយោគ ដណ្តើមរឹបអូសយកដីប្រជាពលរដ្ឋខ្មែរជាបន្តបន្ទាប់។ ទាហានយួនមាននៅទីនោះ ដើម្បីធានាអង្កេតមើលថា អាយ៉ងរបស់ហាណូយ ហ៊ុន សែន មិនងាករេពីនយោបាយរបស់ក្រុងហាណូយកំពុងដាក់អាណានិគមនីយួនបែបថ្មីនៅលើប្រទេសខ្មែរ។ ចំណែកអង្គរក្សរបស់ ហ៊ុន សែន ដែលដឹកនាំដោយ អ៊ឹង ប៊ុន ហៀង ជាជនជាតិយួនលាយឡំជាមួយខ្មែរមានចំនួន ៤០ ០០០ នាក់។

កុម្មុយនិស្តយៀកណាមបានចាប់ផ្តើមដាក់អាណានិគមនីបែបថ្មីលើប្រទេសខ្មែរ និងប្រទេសលាវ តាមគោលនយោបាយពង្រីកទឹកដីរបស់ខ្លួន ដោយដំបូងគេយកកងទ័ពមកកាន់កាប់ទឹកដីប្រទេសទាំងពីរ ហើយបន្ទាប់មកគេយកក្រុមគ្រួសាររបស់គេមកតាំងជំរកនៅក្នុងទឹកដីថ្មី។ ក្រោយមកទៀត យួនផ្លាស់ប្តូរកងទ័ពទាំងនោះ ទៅស្លៀកពាក់ជាស៊ីវិល ធ្វើជាប្រជាពលរដ្ឋសាមញ្ញ និងបានផ្លាស់ប្តូរទាហានទាំងនោះជាកងទ័ពមួយថ្មី ដើម្បីពង្រីកកម្លាំងបន្ថែមទៀត។

នៅឆ្នាំ ១៩៨៩ ក្រោយពីយួនបានចាញ់ប្រៀបខាងនយោបាយការទូតរបស់ចលនាតស៊ូទាំង ៣ ក្រុមនៅតាមព្រំដែនខ្មែរថៃ យួនបានបង្ខំអាយ៉ង ហ៊ុន សែន អោយចុះហត្ថលេខាខុសច្បាប់អនុញ្ញាតផ្តល់ដីភាគខាងកើតនៃប្រទេសខ្មែរអោយកងទ័ពយួន និងពលរដ្ឋវៀតណាមទាំងនោះជាង ៥០០ ០០០ នាក់ ដូចកាលដែល សី ហនុ ចុះហត្ថលេខាស្ងាត់ៗអោយយៀកកុងនៅឆ្នាំ១៩៦៥ ដែរ។ ហេតុដូច្នេះហើយ យួនទូបនីយកម្មនៅក្នុងប្រទេសខ្មែរកើតមានតាំងពីយួនបានកាន់កាប់ត្រួតត្រាខ្មែរនៅថ្ងៃ ៧ មករា ១៩៧៩ មក។ យួនបង្ខំអោយរបបអាយ៉ងក្រុងភ្នំពេញចេញផ្សាយនៅឆ្នាំ ១៩៨២ សារាចរណ៍លេខ ២៤០ សរ មច ហហ និងសារាចរណ៍អំពាវនាវអោយប្រជាពលរដ្ឋខ្មែរទាំងអស់ពិចារណាអំពីការពង្រឹកសាមគ្គីភាព ជាមួយប្រជាពលរដ្ឋវៀតណាម និងភារៈកិច្ចរបស់គេក្នុងការជួយជនជាតិវៀតណាមដើម្បីជ្រកកោននៅក្នុងប្រទេសខ្មែរ។ នៅឆ្នាំ ១៩៨៩ ចំនួនជនជាតិយួនតាំងជំរកនៅក្នុងប្រទេសខ្មែរមានរហូតដល់ ១ ២៥០ ០០០នាក់។ ក្រោយមកយួនបានបង្កើតផែនទីថ្មី បង្ខិតព្រំដែនថ្មីពង្រីករហូតដល់ ៤០ គីឡូម៉ែត្រចូលមកទឹកដីខ្មែរ និងទឹកដីលាវ។ ហ៊ុន សែន បានកាត់ដីតាមព្រំដែន កាត់កោះត្រល់ និងកោះសេះទាំងនោះអោយក្រុងហាណូយជាផ្លូវការ តាមរយៈសន្ធិសញ្ញាជាបន្តបន្ទាប់ និងថ្មីៗបំផុតសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាខុសច្បាប់នាទសវត្ស ១៩៨០ ដែលចុះហត្ថលេខានៅថ្ងៃទី ១០ តុលា ២០០៥ ដោយព្រះមហាក្សត្រ នរោត្តម សីហមុនី។ ប្រជាពលរដ្ឋយួនភាគច្រើននៅខាងកើតនៃប្រទេសដូចជាខេត្ត ស្វាយរៀង និងព្រៃវែង។

យួនកុម្មុយនិស្តបានបន្តនយោបាយរបស់ខ្លួនធ្វើអាណានិគមនីបែបថ្មី ដោយពង្រីកមកតាមព្រំដែន ដូចជាតាមឆ្នេរសមុទ្រ និងកោះ (កោះត្រល់ កោះក្រចកសេះ)តាមសន្ធិសញ្ញាខុសច្បាប់ដែលរបបអាយ៉ងក្រុងភ្នំពេញបានធ្វើខុសរំលោភលើសន្ធិសញ្ញាទីក្រុងប៉ារីស។

ឥឡូវនេះ អង្គការមិត្តភាពកម្ពុជាវៀតណាមដែលមានឈ្មោះថា រណសិរ្សរួបរួម ដើម្បីកសាងជាតិ និងការពារកម្ពុជា ជារណសិរ្សរបស់យួនបានបង្កើតឡើងនៅខេត្តក្រុងទាំងអស់នៅក្នុងប្រទេសខ្មែរ។ រណសិរ្សនេះ

ប្រៀបដូចជារណសិរ្សរំដោះជាតិដែលបង្កើតឡើងដោយ ហាណូយ អំឡុងពេលសង្គ្រាមវៀតណាម ដែលហៅថា សង្គ្រាមឥណ្ឌូចិនលើកទី ២ដែរ ។

នៅពេលថ្មីៗនេះ នាឆ្នាំ ២០០៤ វៀតណាមបានបញ្ជាអោយរបបកុម្មុយនិស្តអាយ៉ង លាវ និងខ្មែរ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងអភិវឌ្ឍន៍តំបន់ត្រីកោណ ។ កិច្ចព្រមព្រៀងនេះធ្វើអោយយួនពង្រីកទឹកដីដោយស្របច្បាប់ឆ្ពោះមកទិសខាងលិច មកខេត្ត ចំនួន ៣ នៅភាគខាងឦសាន្តនៃប្រទេសកម្ពុជាមាន ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី ហើយខេត្ត ៣ នៃប្រទេសលាវ មាន អាតឺ ពឺ សេកុង និង សារាវ៉ាន់។ ក្រុមហ៊ុនចំការកៅស៊ូ និងក្រុមហ៊ុនផ្សេងៗចំនួន ៤០០ ក្រុមហ៊ុន ដែលជាគំរបបិទបាំងកងទ័ពយួនចូលមកនៅក្នុងប្រទេសខ្មែរ ធ្វើជាកម្មករ ហើយនិងវិទ្យុយួន ដែលនិយាយភាសាយួននៅក្រុងព្រះសីហនុជាដើម ។

ទោះបីជា ហូ ជីមិញ ស្លាប់ទៅហើយក៏ដោយ ក៏ប៉ុន្តែផែនការរបស់ហូជីមិញនៅតែគេយកមកអនុវត្តជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន ដោយយកលំនាំតាមរបៀបសហភាពសូវៀត ។ ប្រទេសខ្មែរឥឡូវនេះគ្រប់គ្រងដោយអាយ៉ងរបស់ហាណូយ ហ៊ុន សែន និង ត្រួតត្រាពីក្រោយខ្នងមិនចេញមុខដោយយួនកុម្មុយនិស្ត ។

## II. ឫសគល់នៃរបបប្រល័យពូជសាសន៍ខ្មែរ (The Root of Khmer Genocide)

រហូតមកដល់ពេលនេះ ប្រជាពលរដ្ឋខ្មែរភាគច្រើននៅតែមានចម្ងល់ និងមិនបានដឹងច្បាស់អំពីមូលហេតុនៃការស្លាប់ពលរដ្ឋខ្មែរប្រមាណជាង ១.៧ លាននាក់នៅក្នុងរបប ប៉ុល ពត ។ ជាពិសេសខ្មែរយើងមួយចំនួន ដែលបាក់ស្បាតដោយការគំរាមកំហែងរបស់ពួកកុម្មុយនិស្ត ដែលធ្វើគ្រប់បែបយ៉ាងមិនអោយខ្មែរយល់ដឹងឮអំពីរឿងនយោបាយ និយាយរឿងនយោបាយជាតិ គឺតគួររឿងជាតិ ដោយពួកវាខិតខំលាក់បាំងប្រវត្តិសាស្ត្រពិតរបស់ខ្មែរ ។ ពួកកុម្មុយនិស្តបានពង្វក់អោយខ្មែរវង្វេងតាមការបំពុលមនោគមន៍ផ្សេងៗ ការឃោសនា ដែលជាការរៀបចំរបស់ពួកកុម្មុយនិស្ត ។ ពួកវាធ្វើអោយខ្មែរនៅវង្វេងជាមួយការបំភ័ន្តរបស់កុម្មុយនិស្តយួន និងការប្រើកលល្បិចឃោសនា រំលឹកតែសម័យ ប៉ុលពត ដើម្បីអោយខ្មែរចងកំហឹងនិងខ្មែរគ្នាឯង បែកបាក់សាមគ្គី ហើយដឹងគុណយួនថ្ងៃ ៧ មករា ១៩៧៩ ថាជាអ្នកល្អមកជួយសង្គ្រោះខ្មែរជាដើម ។ តែពួកនេះមិនបានលាតត្រដាង អំពីប្រវត្តិសាស្ត្រពិតប្រាកដរបស់ខ្មែរ តាំងពីសម័យសង្គមរាស្ត្រនិយម សាធារណរដ្ឋខ្មែរ ចាប់ពីទសវត្សឆ្នាំ ៦០ រហូតមកដល់បច្ចុប្បន្ន ដើម្បីអោយខ្មែរបានដឹងនោះទេ ។ ព្រោះថា បើនិយាយពីការពិតនៅក្នុងប្រវត្តិសាស្ត្រ វាប៉ះពាល់អ្នកមានអំណាចសព្វថ្ងៃ និងនយោបាយឈ្លានពានរបស់យួនកុម្មុយនិស្ត ។ ចាប់ពីពេលនេះទៅខ្មែរឈប់វង្វេងទៀតហើយ កាលពីពេលដែលពួកយួនកុម្មុយនិស្ត (យៀកកុង) ឈ្លានពានដណ្តើមជ័យជំនះលើខ្មែរទាំងស្រុង នៅថ្ងៃ ១៧ មេសា ១៩៧៥ ពួកគេបានបំផ្លាញ គម្ពីរក្បួនខ្នាត និងសម្លាប់ខ្មែរអ្នកចេះចោលអស់ ដើម្បីផ្តាច់ឫសគល់ខ្មែរ មិនអោយដឹងអំពីព្រឹត្តការណ៍ និង ប្រវត្តិសាស្ត្រកើតឡើងចន្លោះពេលនោះ ។ ពួកយួនកុម្មុយនិស្តជាអ្នករៀបចំផែនការអោយខ្មែរធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍នេះ ដោយយួនបានយកលទ្ធិកុម្មុយនិស្ត ជាមធ្យោបាយ មកសាបព្រោះបណ្តុះបណ្តាលលើខ្មែរ គួបផ្សំជាមួយមេដឹកនាំខ្មែរ ដូច សី ហនុ និង ប៉ុល ពត ដែលលោភលន់អំណាច លង់ជឿការបោកប្រាស់ ចិន និងយួន ធ្វើអោយខ្មែរកើតកលយុគ ក្រឡាប់ចាក់ធ្លាក់ចុះ

កាប់សម្លាប់គ្នា។ កល្បិចខ្ទីកម្លាំងខ្មែរ តាមការប្រើមនោគមន៍នេះហើយ ធ្វើអោយប្រជាពលរដ្ឋខ្មែរ យើងនៅតែយល់ច្រឡំថា *ខ្មែរសម្លាប់ខ្មែរ* រហូតមកដល់សព្វថ្ងៃ។ យួនកុម្មុយនិស្តកែប្រែនយោបាយបន្តិចម្តងៗ តាមរយៈប្រើ ហ៊ុន សែន ជាកូនអុក បន្តត្រួតត្រាខ្មែរ ដោយមិនចេញមុខ។ ពេលដែលខ្មែរធ្លាក់ចុះខ្សោយដល់កំរិតសូន្យ គ្មានគម្ពីរ ឯកសារ ស្លាប់អ្នកចេះដឹងអស់ហើយ យួនងាយស្រួលត្រួតត្រាខ្មែរ កែប្រែប្រវត្តិសាស្ត្រ ដើម្បីលេបយកទឹកដីខ្មែរ និងដណ្តើមផលប្រយោជន៍ពីខ្មែរដូចសព្វថ្ងៃ។ ដូចនេះអ្នកដែលសម្លាប់ខ្មែរ គឺយួនកុម្មុយនិស្ត ឬកុម្មុយនិស្តឥណ្ឌូចិន ដែលយកលិទ្ធិកុម្មុយនិស្តជាមធ្យោបាយ បំពាក់បំប៉នខ្មែរ អោយសម្លាប់ខ្មែរ និងមេដឹកនាំខ្មែរមួយចំនួន ដែលលង់ក្នុងអំណាច រាជបល្ល័ង្គ បំរើធ្វើជាឧបករណ៍យួន ដើម្បីធ្វើអោយខ្មែរវឹកវរ កាប់សម្លាប់ លេបយកទឹកដីខ្មែរ តាមផែនការសហព័ន្ធឥណ្ឌូចិន។ ដើម្បីរំលើងជាតិខ្មែរអោយធ្លាក់ខ្សោយ ងាយស្រួលគេគ្រប់គ្រងត្រួតត្រា ឯកសារត្រូវគេបំផ្លាញចោល បញ្ញវន្តត្រូវគេសម្លាប់ ចំណែកឯប្រវត្តិសាស្ត្រខ្មែរក្រោយមកទៀត ត្រូវបានគេលាក់បាំង កែប្រែបំបាត់ក្នុងគោលបំណងចំណេញនយោបាយ ជាពិសេសគឺឯកសារ ប្រវត្តិសាស្ត្រនយោបាយពាក់ព័ន្ធទៅនឹងមេដឹកនាំកុម្មុយនិស្តផ្តាច់ការនាពេលបច្ចុប្បន្ន។ ហេតុដូច្នេះហើយ *ឫសគល់នៃរបបប្រល័យពូជសាសន៍ខ្មែរ គឺជាផែនការរបស់យួនកុម្មុយនិស្តដែលយកលិទ្ធិកុម្មុយនិស្តជាមធ្យោបាយ* ពង្វក់មេដឹកនាំខ្មែរដែលមានស្តេច សីហនុ ប៉ុល ពត ហ៊ុន សែន អោយដើរតាមមនោគមន៍កុម្មុយនិស្ត ដែលគោលបំណងចុងក្រោយគឺដើម្បីលេបទឹកដីខ្មែរ ដាក់ជាចំណុះយួនតាមផែនការសហព័ន្ធឥណ្ឌូចិនរបស់យួនហាណូយ។

### III. ហេតុអ្វីបានជាខ្មែរធ្លាក់ក្នុងរបបប្រល័យពូជសាសន៍? (Why Cambodia fell in Genocide?)

ដូចបានរៀបរាប់ខាងលើមកហើយថា កុម្មុយនិស្តខ្មែរ មានដើមកំណើតមកពីបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលជាសាខារបស់បក្សកុម្មុយនិស្តអន្តរជាតិ បង្កើតឡើងដោយយួន ហូ ជីមិញ នៅទីក្រុង ហុង កុង ថ្ងៃទី ៣ កុម្ភៈ ១៩៣០។ បក្សកុម្មុយនិស្តឥណ្ឌូចិននេះមានការគាំទ្រ ផ្តល់ហិរញ្ញវត្ថុពីកុម្មុយនិស្តអន្តរជាតិ។ បក្សកុម្មុយនិស្តឥណ្ឌូចិនបានបង្កើតសាខារបស់ខ្លួននៅប្រទេសខ្មែរ និងនៅប្រទេសលាវ គឺបក្សកុម្មុយនិស្តខ្មែរ និងបក្សកុម្មុយនិស្តលាវ ព្រមទាំងសាខានៅប្រទេសមួយចំនួនទៀត ដូចជា ថៃ ម៉ាឡេស៊ី និងសិង្ហបូរីជាដើម។ ការដែលខ្មែរស្លាប់ទាំងខ្មែរក្រោម និងខ្មែរកន្លងមក វាជាផែនការដ៏ខ្មៅក្រខ្វក់របស់យួនកុម្មុយនិស្ត ក្នុងការរំលាយពូជសាសន៍ខ្មែរ ដើម្បីបំពេញមហិច្ឆតារបស់ខ្លួនក្នុងការលេបទឹកដីរបស់ប្រទេសជិតខាងនៅតំបន់ឥណ្ឌូចិនតែប៉ុណ្ណោះ។ ពួកគេបានប្រើវិធីបំភ័ន្តលាក់បាំងខ្មែរ កែក្រឡៃប្រវត្តិសាស្ត្រខ្មែរទៅជាប្រវត្តិសាស្ត្រឥណ្ឌូចិន (សត្រូវបងប្អូន) អោយកូនខ្មែររៀន ធ្វើតាមគ្រប់មធ្យោបាយ គៀបសង្កត់ខ្មែរមិនអោយមានសិទ្ធិសេរីភាព មិនអោយខ្មែរដឹងពីនយោបាយ និយាយពីរឿងប្រទេសជាតិ ដោយចោទប្រកាន់តាមវិធីផ្សេងៗចំពោះអ្នកដែលនិយាយការពិត ឬប្រឆាំង។ ធ្វើអោយខ្មែរខ្លាច មិនអោយខ្មែរនិយាយអំពីរឿងនយោបាយ និងប្រវត្តិសាស្ត្ររបស់ខ្លួន ដោយមានការគំរាមកំហែងចាប់ និងសម្លាប់តាមការប្រើវិធីគ្រប់បែបយ៉ាង។ បក្សកុម្មុយនិស្តខ្មែរដឹកនាំដោយយួនបន្លំខ្លួន ធ្វើជាខ្មែរឈ្មោះ សឺង ង៉ុកមិញ ឬអាចារ្យ មៀន និងទូសាមុត សា ឡុតសរ ដែលជាសាខារបស់បក្សកុម្មុយនិស្តឥណ្ឌូចិន។ យួនកុម្មុយនិស្តបានចូលមកធ្វើចលនានយោបាយជាសម្ងាត់នៅក្នុងទឹកដីខ្មែរនៅតំបន់ចំការកៅស៊ូ ខេត្តកំពង់ចាម

នៅសំឡូត និងកំពត ចាប់តាំងពីឆ្នាំ ១៩៤៦។ យួនបានឃោសនាអោយខ្មែរ និងលាវចូលរួបរួមជាមួយគេ ដើម្បីដេញអាណានិគមន៍បារាំងចេញពីទឹកដី តែនៅពីក្រោយខ្នងនយោបាយនេះ យួនបានរៀបផែនការត្រួតត្រា ឥណ្ឌូចិនជំនួសបារាំងវិញ ព្រោះយួនមាន ចិន និងសូវៀត ជាអ្នកនៅជួយពីក្រោយខ្នង។ នៅឆ្នាំ១៩៥៤ បារាំងបាន ចុះហត្ថលេខានៅទីក្រុងហ្សឺណែវ ប្រគល់ឯករាជ្យមកអោយឥណ្ឌូចិន ពេលដែលយួនបានធ្វើសង្គ្រាមឈ្នះបារាំងនៅ ឌៀន បៀនភូ។ ក្រោយពីយួនទទួលបានឯករាជ្យពីបារាំងហើយ តាមសន្និសញ្ញាក្រុងហ្សឺណែវបានតំរូវអោយ កងទ័ពយួន (យៀកមិញ) ដកចេញពីប្រទេសខ្មែរ និងលាវទាំងអស់។ ពេលនោះយួនបានដកចេញពីប្រទេសខ្មែរ ដោយយួនបានចាប់កូនខ្មែរតូចៗទៅជាមួយផង ដើម្បីយកទៅបណ្តុះបណ្តាល នៅទីក្រុង ហាណូយ។

ចំណែកឯ សា ឡុតសរ ដែលទទួលបានអាហាររូបករណ៍ទៅសិក្សាប្រទេសបារាំងផ្នែកអគ្គីសនីបានចាប់ អារម្មណ៍រឿងនយោបាយ ហើយបានអានសៀវភៅកុម្មុយនិស្ត(សៀវភៅក្រហម)នៅប្រទេសបារាំង។ ដំបូង ឡើយ សា ឡុតសរ បានដឹកនាំធ្វើការតស៊ូប្រឆាំង និងការដឹកនាំរបបសក្តិភូមិរបស់ នរោត្តម សី ហនុ តាំងពី គាត់កំពុងសិក្សានៅប្រទេសបារាំង ក្រោយមកស្តេច នរោត្តម សីហនុ បានកាត់ផ្តាច់អាហារូបករណ៍វិញ ដោយគាត់ មិនទាន់រៀនចប់ផង ក៏ត្រឡប់មកប្រទេសខ្មែរវិញ។ ក្រោយពេលដែលគាត់មកដល់ប្រទេសខ្មែរ ដោយការមិន ពេញចិត្តនិងរបបសក្តិភូមិ ដឹកនាំដោយ សីហនុ គាត់បានរៀបចំធ្វើនយោបាយបដិវត្តន៍នៅក្នុងប្រទេសខ្មែរ ហើយ ផែនការបានបែកធ្លាយដល់អាជ្ញាធរ សីហនុ ទើប សីហនុ បានប្រកាសដេញចាប់ សា ឡុតស និងអ្នកចូលរួម ក្នុងកិច្ចការនេះមួយចំនួនទៀត មានចំនួន ៦៣ នាក់ក្នុងនោះមាន សុន សេន ដែរ។ ពេលនោះ សា ឡុតសរ បានរត់ចូលព្រៃហើយបានចូលទៅធ្វើជាលេខារបស់ ទូ សាមុត ដែលដឹកនាំដោយ ស៊ឹង ង៉ុកមិញ។ យើងឃើញថា យួនបានជួយខ្មែរក្រហមអោយប្រឆាំង និងនរោត្តម សីហនុ



*សីហនុ ជាមេខ្មែរក្រហម បំរើនយោបាយអោយពួកកុម្មុយនិស្ត យួន និង ចិន*

តែពីក្រោយខ្នងម្ខាងទៀតយួនបានសុំអោយ សីហនុ ជួយផ្តល់ស្បៀងអាហារ និងទឹកដីជំរកដល់យួន យៀកកុងដើម្បីធ្វើសង្គ្រាមជាមួយយៀកណាមខាងត្បូង និងសហរដ្ឋអាមេរិក។ សង្គ្រាមនេះបានធ្លាក់មក លើប្រទេសខ្មែរ ធ្វើអោយវិនាសអន្តរាយ ដូចយកភ្លើងមកដុតផ្ទះខ្លួនឯង។ យួនខាងជើងចាប់ផ្តើមសង្គ្រាមជាមួយ

យួនខាងត្បូងតាំងពីឆ្នាំ ១៩៥៨ ហើយសង្គ្រាមនេះបានរីករាលដាលនៅលើទឹកដីខ្មែរជាបន្តបន្ទាប់ ចាប់ពីឆ្នាំ ១៩៦៥ ដោយសារតែ សី ហនុ បានអនុញ្ញាតផ្តល់ទឹកដីខ្មែរភាគខាងកើតចំនួន ៥ ខេត្ត អោយយួនយៀកកុងដាក់ទ័ពចំនួន ៦០ ០០០ នាក់ ទៅ ៨០ ០០០ នាក់ ធ្វើសង្គ្រាមដែលកាលនោះកងទ័ពខ្មែរមានតែចំនួន ៣០ ០០០ នាក់ ។ ចំណែកខ្មែរនៅកម្ពុជាក្រោម ត្រូវបានយួនឃោសនាអោយចូលបំរើខាងយួនកុម្មុយនិស្ត ដោយយួនកុម្មុយនិស្តយក ឈ្មោះ សីហនុ ទៅឃោសនាថារំដោះទឹកដីកម្ពុជាក្រោម ឯខ្មែរក្រោមមួយចំនួនទៀតបានចូលទៅខាងយួនខាងត្បូង (សេរី) ដើម្បីប្រឆាំងនិងការឈ្លានពានរបស់ពួកយួនកុម្មុយនិស្ត។ យួនកុម្មុយនិស្តយករូបថតសម្តេច សីហនុ និង ថាសថតសម្លេង ដើម្បីធ្វើការឃោសនាអោយខ្មែរជឿ សីហនុ ចូលរួមជាមួយសម្តេច ដើម្បីធ្វើសង្គ្រាមរំដោះខ្មែរ កម្ពុជាក្រោម។ ហេតុនេះខ្មែរជាអ្នកស្លាប់ទាំងសងខាង កុម្មុយនិស្ត និងសេរី ដោយយួនខ្ចីដៃខ្មែរសម្លាប់ខ្មែរ។ ចំណែកខ្មែរខាងលើវិញ ខ្មែរម្ខាងខាងសាធារណរដ្ឋ ខ្មែរម្ខាងទៀតខាង សីហនុ ប៉ុល ពត និងកុម្មុយនិស្តយួន។ ពួកយួនយៀកកុងបានយករូបសញ្ញា សីហនុ ពាក់បំភ័ន្តខ្មែរអោយគាំទ្រថាជាកងទ័ព សម្តេចឪ ដើម្បីអោយខ្មែរ គាំទ្រ។ សង្គ្រាមរវាងយួនខាងជើង និងយួនខាងត្បូងបានបញ្ចប់នៅថ្ងៃ ៣០ មេសា ១៩៧៥ គឺ ១៣ ថ្ងៃប៉ុណ្ណោះ ក្រោយពីយួនកុម្មុយនិស្តឈ្នះខ្មែរសាធារណរដ្ឋនៅថ្ងៃ ១៧ មេសា ១៩៧៥។ យួនទទួលបានផលប្រយោជន៍ ចំណេញជាច្រើន ដូចជា ជំនួយពីចិន ដែលជួយយួនកុម្មុយនិស្ត ជំនួយពីអាមេរិក ដែលជួយយួនខាងត្បូងសេរី តែខ្មែរក្រោម និងខ្មែរស្លាប់រាប់លាននាក់ បើកឱកាសអោយយួនលុកលុយ ចូលមកកាន់កាប់លេបទឹកដីខ្មែរ បច្ចុប្បន្នទៀត។ ពេលដែលកងទ័ពយៀកកុងនៅពាសពេញទឹកដីខ្មែរភាគខាងកើតនិងតាមក្រុងព្រះសីហនុ ដល់ ខេត្តកំពង់ស្ពឺ សី ហនុ មិនបាននៅដោះស្រាយបញ្ហាកងទ័ពយួននៅលើទឹកដីខ្មែរ ដែលខ្លួនអនុញ្ញាតជាសម្ងាត់ នោះទេ តែបែរជាចាកចេញទៅដើរកំសាន្តនៅប្រទេសបារាំងជាមួយភរិយា ម៉ូនិចទៅវិញ ។ ព្រះមាតា កុសមៈ បានសរសេរសំបុត្រ ទៅយាងព្រះអង្គមកវិញ តែព្រះអង្គសុខចិត្តស្តាប់ភរិយានិងម្តាយក្មេក មិនបានយាង ត្រឡប់មកវិញ ដើម្បីដោះស្រាយយៀកកុងនៅពេញទឹកដីខ្មែរ ទោះបីជាព្រះអង្គបានសន្យាជាមួយអ្នកតំណាង រាស្ត្រថា ព្រះអង្គនិងយាងមកប្រទេសខ្មែរ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ១៩៧០ ដើម្បីដោះស្រាយបញ្ហានោះក៏ដោយ តែផ្ទុយទៅវិញ ព្រះអង្គបានបដិសេធក្នុងការយាងត្រឡប់មកវិញ។ ហេតុដូច្នេះ ដើម្បីដោះស្រាយយួនកុម្មុយនិស្ត ដែលកំពុងតែឈ្លានពានទឹកដីខ្មែរ ទើបនៅថ្ងៃ ១៨ មីនា ១៩៧០ សិរិមតៈ លន់ នល់ ធ្វើការប្រជុំសភា ទំលាក់នរោត្តម សីហនុ ចេញពីអំណាច ដើម្បីដេញយួនយៀកកុងចេញពីទឹកដីខ្មែរ។ ក្រោយពី លន់ នល់ ទំលាក់ស្តេច សីហនុ មក សីហនុ បានធ្វើដំណើរទៅប្រទេសរ៉ូស៊ី និងបន្ទាប់មកទៅប្រទេសចិន ដើម្បីស្វែងរកការ គាំទ្រ ដណ្តើមអំណាច រាជបល្ល័ង្គមកវិញ ។ ដោយមានចិន និងយួននៅពីក្រោយខ្នង ចិនបានបញ្ចុះបញ្ចូលអោយ សាឡុត ស និងសីហនុរួបរួមគ្នាបង្កើតជារណសិរ្សរួបរួមជាតិកម្ពុជាមួយនៅទីក្រុងប៉េកាំង នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧០ ធ្វើសង្គ្រាមជាមួយខ្មែរសារធារណរដ្ឋ ដែលមាន លន់ នល់ និងសេរីមតៈ ជាដើម។ ក្នុងនោះ ចិនជាអ្នកជួយ ខាងសព្វាវុធ ស្បៀង ចំណែកយួនជាអ្នកជួយខាងបច្ចេកទេស ហ្វឹកហាត់ បញ្ចូលមនោគមន៍ និងជួយកម្លាំងច្បាំង ដល់ខ្មែរក្រហម។ ដើម្បីតែអំណាច និងរាជបល្ល័ង្គ សីហនុ មិនបានគិតពីផលប្រយោជន៍

ប្រទេសជាតិ និងអាយុជីវិតរបស់ប្រជាពលរដ្ឋខ្មែរដែលស្លាប់នោះឡើយ។ កងទ័ពយៀកកុង ដែលមាននៅក្នុងទឹកដីខ្មែរស្រាប់បានពាក់ផ្លាករូបភាព សី ហនុ ប្រាប់ប្រជាពលរដ្ឋខ្មែរជាកងទ័ព សម្តេចឪ ដើម្បីអោយប្រជាពលរដ្ឋខ្មែរជួយគាំទ្រ ព្រោះយួនដឹងថាពេលនោះស្តេច សីហនុ នៅមានប្រជាប្រិយចំពោះប្រជាពលរដ្ឋខ្មែរនៅឡើយ។ ខ្មែរភាគច្រើនបានជួយគាំទ្រជួយយួនយៀកកុងទាំងនោះ ដើម្បីធ្វើសង្គ្រាមជាមួយកងកម្លាំងខ្មែរសាធារណរដ្ឋ ខ្មែរអ្នកស្នេហាជាតិ ដែលមាន និស្សិត បញ្ញវ័ន្ត ព្រះសង្ឃ ប្រជាពលរដ្ឋខ្មែរបានរួបរួមគ្នាឡើង។ ចំណែកខ្មែរមួយចំនួនទៀតលង់ជឿ ការឃោសនារបស់យួនយៀកកុង ដែលយកឈ្មោះ សីហនុ មកប្រើ និងការប្រកាសរបស់ ស្តេច សីហនុ អោយខ្មែររត់ចូលព្រៃម៉ាគី ដើម្បីច្បាំងដណ្តើមអំណាច និងរាជបល្ល័ង្កមកអោយព្រះអង្គវិញ។ ទីបំផុតពួកខ្មែរក្រហម ដែល ប្រឆាំង នរោត្ត សីហនុ បានរួបរួមគ្នា ដោយមាន ចិន និងយួនយៀកកុងជាអ្នកជួយ ដើម្បីច្បាំងនិងខ្មែរសារធារណរដ្ឋ លន់ នល់ ដែលត្រង់ចំណុចនេះ ខ្មែរបានដើរក្រោមយុទ្ធសាស្ត្ររបស់ពួកកុម្មុយនិស្ត ធ្វើតាមពួកកុម្មុយនិស្ត ខ្ចីដៃខ្មែរ ធ្វើសង្គ្រាមជាមួយខ្មែរ ខ្មែរជាអ្នកខាតប្រជាពលរដ្ឋខ្មែរជាអ្នកស្លាប់ ទឹកដីខ្មែរត្រូវបំផ្លាញដោយសារសង្គ្រាម ទីបំផុតប្រទេសខ្មែរត្រូវធ្លាក់ក្នុងកណ្តាប់ដៃយួនកុម្មុយនិស្ត។

ពេលដែលកងទ័ពសហរដ្ឋអាមេរិកបានដកចេញពីឥណ្ឌូចិន ក្រោយពីចុះហត្ថលេខាជាមួយយួននៅទីក្រុងប៉ារីសនៅឆ្នាំ១៩៧៣ ដើម្បីបញ្ចប់សង្គ្រាមឥណ្ឌូចិនលើកទី ២ យួនបាននៅតែបន្តធ្វើសង្គ្រាមឈ្លានពានខ្មែរទៀតក្រោមផ្លាក សីហនុ និងខ្មែរក្រហម ជាអ្នកបិទបាំងអោយអន្តរជាតិមើលឃើញថា សង្គ្រាមស៊ីវិល រហូតដល់យួនកុម្មុយនិស្តបានឈ្នះសាធារណរដ្ឋខ្មែរនៅថ្ងៃ ១៧ មេសា ១៩៧៥ ហើយលើកជ័យជំនះនោះទៅអោយខ្មែរ ក្រហមដែលមាន សីហនុ និងប៉ុល ពត ជាមេដឹកនាំ ចំណែកយួនវិញបានផ្លាស់ប្តូរខោអាវយៀកកុងទៅពាក់អាវបន្លំខ្លួនធ្វើជាខ្មែរក្រហម បន្តសម្លាប់ខ្មែរ។ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជំនះនោះ កាលនោះខ្មែរក្រហមមានបីក្រុមទី១ ខ្មែរក្រហម ដែលយួនចាប់ទៅបណ្តុះបណ្តាលដោយក្រុងហាណូយ ពួកនេះសំរាប់ធ្វើជាពិឃាតសម្លាប់ខ្មែរដែលប្រឆាំងយួនដោយការចោទប្រកាន់ផ្សេងៗ ដូចជាចោទថា ភ្នាក់ ស៊ី អាយ អេ ការសេបេ និង បរិវារអាមេរិកាំងជាដើម។ ទី២ ខ្មែរក្រហមដែលគាំទ្រ សីហនុ ទី៣ ខ្មែរក្រហមដែលគាំទ្រ ប៉ុល ពត ខ្មែរទាំងបីក្រុមនេះ សុទ្ធតែបណ្តុះបណ្តាលមនោគមនីវិជ្ជានយោបាយខុសទីស ពីហាណូយ (ចងគំហឹងនិងខ្មែរសម្លាប់ខ្មែរតែគាំទ្រយួន)។ ហេតុដូចនេះហើយ អ្នកដែលបង្កវិនាសសកម្មសម្លាប់ខ្មែរនៅក្នុងប្រទេសខ្មែរនៅក្នុងរបបនេះ គឺក្រុមពិឃាតដែលយួនបានបំពាក់បំប៉នមនោគមន៏កុម្មុយនិស្តមក ហើយពួកពិឃាតទាំងនោះត្រូវបានគេបញ្ជូនជាបន្តបន្ទាប់ ពីក្រុងហាណូយចូលមកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីសម្លាប់ខ្មែរ (យួនយកលិទ្ធិកុម្មុយនិស្តនេះជាមធ្យោបាយ ខ្ចីដៃខ្មែរអោយសម្លាប់ខ្មែរ ដើម្បីបំភ័ន្តខ្មែរអោយ មើលឃើញថាខ្មែរសម្លាប់ខ្មែរ ចំណេញនយោបាយយួន ៧ មករា ១៩៧៩)។ ក្រុមទាំងនេះទទួលផែនការ ផ្ទាល់ពីក្រុងហាណូយ ដើម្បីសម្លាប់ខ្មែរជីកស្មៅជីកទាំងឫស។ មនោគមន៏របស់ពួកកុម្មុយនិស្តយួន ប្រឆាំងនិងពួកប្រតិកិរិយា បរិវារ ដែលសំដៅរំលើងឫសគល់របស់ជាតិខ្មែរ អោយដួលរលំធ្លាក់ចុះ ធ្វើអោយខ្មែរច្របូកច្របល់ ជាហេតុនាំអោយខ្មែរក្រហមខាង

ប៉ុលពត មានការសង្ស័យ ហើយបង្កើតអោយមានការកាប់សម្លាប់តបតវិញ ក្រោយពីយួនកក្កូរស្ថានការណ៍ក្នុងសង្គមខ្មែរ នេះជាការគ្រោងទុករបស់យួន ក្រោយពីខ្មែរច្របូលច្របល់វិកវរក្នុងប្រទេសហើយ យួនបានចូលមកកែប្រែនយោបាយថ្មី ៧ មករា ១៩៧៩។ ពេលដែលគេសម្លាប់ខ្មែរ អ្នកចេះដឹងអស់ហើយ ដូចនេះប្រទេសត្រូវធ្លាក់ក្នុងការគ្រប់គ្រងរបស់ពួកកុម្មុយនិស្តឥណ្ឌូចិនដែលមានយួនជាមេក្លោងរហូតមកដល់ពេលនេះ។ ចំពោះខ្មែរដែលនៅសល់សព្វថ្ងៃ ខ្លាចបាក់ស្បាត មិនហ៊ាននិយាយការពិត មានតែការឈឺចាប់ធ្វើគរ ធ្វើថ្លង់មិនហ៊ាននិយាយបញ្ហាពិតដែលកើតឡើងនៅក្នុងសង្គម និងអោនក្បាលក្រោមយួនដើម្បីជីវិតរស់ ដោយការកៀបសង្កត់គ្រប់បែបយ៉ាងតាមការប្រើអំណាចផ្តាច់ការរបស់ពួកកុម្មុយនិស្តសព្វថ្ងៃ *តើយើងបណ្តោយទុកអោយជាតិខ្មែរទាំងមូលត្រូវរលាយបាត់បង់ ហើយទុក្ខវេទនាត្រូវធ្លាក់លើកូនចៅយើងជំនាន់ក្រោយទៀត ឬមួយយ៉ាងណា?* ។

## IV-**ឫសគល់ ថ្ងៃ ៧ មករា** (The Root of 7 January)

ដូចបានរៀបរាប់ខាងលើមកហើយថា នយោបាយរបស់យួនកុម្មុយនិស្តធ្វើតាមផែនការរបស់ហូ ជីមិញ ដែលរៀបចំតាំងពីឆ្នាំ ១៩៣០។ ដើម្បីអោយប្រជាពលរដ្ឋជាច្រើនរបស់ខ្លួនរស់នៅស្រួល យួនត្រូវវាតទីទឹកដីនៅតំបន់ឥណ្ឌូចិន ដូចមានប្រទេស លាវ ខ្មែរ ចាម និង ខ្មែរនៅកម្ពុជាក្រោម ដើម្បីដាក់ជាចំណុះរបស់សហព័ន្ធឥណ្ឌូចិន។ យួនកុម្មុយនិស្តបានធ្វើសង្គ្រាម លុកលុយប្រទេសខ្មែរ ប្រើល្បិចកល យុទ្ធសាស្ត្រគ្រប់វិធីដើម្បីធ្វើអោយជាតិខ្មែរធ្លាក់ខ្សោយ។ យួនបានរៀបចំផែនការ ផ្តាច់ឫសគល់ជាតិខ្មែរអោយដួលរលំធ្លាក់ខ្សោយនៅក្នុងរបបប៉ុល ពត ដូចជាការដុតគម្ពីរ ក្បួនខ្នាត លុបបំបាត់ប្រវត្តិសាស្ត្រ និងសម្លាប់អ្នកប្រាជ្ញ បញ្ញវន្តជាដើម។ សូមបញ្ជាក់ថា របបខ្មែរក្រហម ដែលមានសីហនុ ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាធ្វើការសហការជាមួយ ប៉ុលពត នេះ គឺមានយួនក្រហម (កុម្មុយនិស្ត) ឬហៅថាយៀកកុងនិងចិន ជាអ្នកជួយគ្រប់បែបយ៉ាង រាប់តាំងពីការបណ្តុះបណ្តាល ផ្តល់សព្វាវុធ គ្រាប់រំសេវ ជួយច្បាំងជាមួយកងទ័ព លន់ នល់ សេរីមតៈ រហូតបានជ័យជំនះនៅថ្ងៃ១៧ មេសា១៩៧៥។ ពួកយៀកកុងទាំងនេះ បានលើកជ័យជំនះអោយពួក **ខ្មែរក្រហម** (ខ្មែរកុម្មុយនិស្ត)។ យៀកកុងដែលនៅក្នុងខ្មែរស្រាប់ និង ខ្មែរដែលយួនបណ្តុះបណ្តាល ប្តូរខោអាវទៅស្លៀកពាក់ខោអាវខ្មៅ បន្លំធ្វើខ្មែរ (ក្រហម) ដើម្បីបំភ័ន្តអោយឃើញថា **ខ្មែរសម្លាប់ខ្មែរ** នៅក្នុងរបបនេះ។ ក្រោយពីយួនកក្កូរស្ថានការណ៍អោយធ្លាក់ចុះដល់កំរិតសូន្យហើយ យួនបានប្តូរនយោបាយថ្មី វាយលុកឈ្លានពានខ្មែរ កាន់កាប់ទឹកដីខ្មែរទាំងស្រុងបន្តកាប់សម្លាប់ខ្មែរថ្ងៃទី ៧ មករា ១៩៧៩តែម្តង។ ការបំផ្លាញខ្ទេចខ្ទីគម្ពីរក្បួនខ្នាត សម្លាប់អ្នកប្រាជ្ញ អ្នកចេះដឹងដែលជាគ្រឹះយ៉ាងរឹងមាំរបស់ជាតិសាសន៍ខ្មែរ ហើយបន្សល់ទុកអ្នកដែលចេះដឹងពីនយោបាយតិចតួច។ បន្ទាប់មកពួកគេខិតខំកែក្រឡៃប្រវត្តិសាស្ត្រថ្មីអោយកូនចៅខ្មែរជំនាន់ក្រោយរៀន។ ដើម្បីចំណេញនយោបាយលេបទឹកដីយួនលាក់បាំងប្រវត្តិសាស្ត្រពិតប្រាកដ មិនអោយខ្មែរជំនាន់ក្រោយបានដឹងច្បាស់លាស់ ធ្វើអោយខ្មែរវង្វេងរកការពិតមិនឃើញ។ ឥឡូវនេះតាមគ្រប់សាលារៀន នាយកសាលាគេបង្ខំអោយកាន់គណបក្សប្រជាជន ហាមមិនអោយខ្មែររៀនប្រវត្តិសាស្ត្រ និយាយពីប្រវត្តិសាស្ត្រពិតប្រាកដ ហាមប្រាមគ្រូមិនអោយនិយាយពីរឿងសង្គមពិត និង ប្រវត្តិសាស្ត្រពិត។ បើលោកគ្រូអ្នកគ្រូណាហ៊ាននិយាយការពិត នោះគេចោទថារឿងនយោបាយ ឬបង្រៀន

នយោបាយ។ តែគេកំពុងតែបង្រៀនប្រវត្តិសាស្ត្រឥណ្ឌូចិនជំនួសវិញ (យួនជាអ្នកមានគុណ ជួយរំដោះខ្មែរជាដើម)។ ដូចនេះហើយ យើងឃើញថាឫសគល់របស់ **ថ្ងៃ ៧ មករា គឺ យួនកុម្មុយនិស្ត (សហព័ន្ធឥណ្ឌូចិន )** ដែលបានយកលទ្ធិកុម្មុយនិស្តមកសាបព្រោះលើខ្មែរ។ យួនឈ្នះខ្មែរ តាំងពីថ្ងៃ ១៧ មេសា ១៩៧៥ ដោយប្រើនយោបាយទាំងត្រជាក់ទាំងក្តៅ ប្រើពួកខ្មែរកុម្មុយនិស្ត ឬខ្មែរក្រហមដែលនិយមយួន ហេង សំរិន ជា ស៊ីម ហ៊ុន សែន អោយកាន់អំណាចជំនួស រហូតមកដល់បច្ចុប្បន្នដើម្បីលេបទឹកដីខ្មែរ សំរេចតាមផែនការសហព័ន្ធឥណ្ឌូចិន។



ជនជាតិវៀតខ្មែរលាវរួមសាមគ្គីម៉ឺនឆ្នាំ

## V.យួនកុម្មុយនិស្តត្រួតត្រាខ្មែរ ថ្ងៃ ៧ មករា ១៩៧៩

(Vietnamese Communist Colonize Cambodia on January 7, 1979)

ចាប់ពីថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ យួនបានផ្លាស់ប្តូរនយោបាយថ្មី ដោយយួនបានផ្លាស់ប្តូរខ្មែរ (ក្រហម) កុម្មុយនិស្តនិយមចិនចេញពីអំណាច លើកបន្តុបខ្មែរក្រហម (កុម្មុយនិស្ត)និយមយួនវិញ អោយកាន់អំណាច។ ពួកកុម្មុយនិស្តដែលនិយមយួនមានដូចជា ប៉ែន សុវណ្ណ ចាន់ ស៊ី ហេង សំរិន ហ៊ុន សែន ជា ស៊ីម សាយ ប៊ូថង និងជាច្រើនទៀត។ យួនលើកខ្មែរ ដើម្បីធ្វើជាឧបករណ៍នយោបាយអោយខ្លួន ព្រោះយួនបានងាកពីចិន ហើយភ្ជាប់ទំនាក់ទំនងជាមួយរ៉ូស៊ី។ ចិនមានជម្លោះជាមួយរ៉ូស៊ី ចិនបានប្តូរទំនាក់ទំនងទៅរកសហរដ្ឋអាមេរិកវិញ។ ជាក់ស្តែងនៅពេលដែលយួនលើក ប៉ែន សុវណ្ណ និង ចាន់ស៊ី អោយធ្វើជាអាយ៉ង បំរើនយោបាយរបស់ខ្លួន តែប៉ែន សុវណ្ណ និងចាន់ ស៊ី មិនធ្វើតាមនយោបាយរបស់ខ្លួន យួនបានចាក់ថ្នាំ ចាន់ ស៊ី សម្លាប់នៅលើយន្តហោះដែលទៅព្យាបាលនៅប្រទេសរ៉ូស៊ី។ ចំណែកឯ ប៉ែន សុវណ្ណវិញត្រូវ ហ៊ុន សែន និង សាយ ប៊ូថង ឃុបឃិតជាមួយយួន ចាប់យកទៅដាក់គុកនៅទីក្រុងហាណូយ ចំនួន ១០ ឆ្នាំ ៥២ថ្ងៃ នេះដោយសារប៉ែន សុវណ្ណ មានប្រពន្ធយួនជាកូនប្រសារផាំវ៉ាន់ដុង ម្ល៉េះត្រូវស្លាប់ដូច ចាន់ ស៊ី។ យួនបានលើកបន្តុបជនល្មោភអំណាចដូច ហ៊ុន សែន ជា ស៊ីម និងហេង សំរិន អោយកាន់អំណាចរហូតមកដល់បច្ចុប្បន្ន។ យួនបានឈ្លានពានកាន់កាប់ទឹកដីខ្មែរ រឹបអូសប្លន់យកទ្រព្យសម្បត្តិខ្មែរ ចាប់ពីពេលនោះមក ហើយថែមទាំងដេញសម្លាប់ខ្មែរដែលប្រឆាំងនិងយួន របបអាយ៉ងយួន ដោយ

ចោទថាពួក ប៉ុល ពត។ ចំណែកអ្នកដែលនៅសេសសល់ប្រុសៗ ដែលជាអ្នកមានកម្លាំង វាបានចាប់បង្ខំអោយទៅធ្វើជាទាហាន និងខ្លះត្រូវចាប់មកធ្វើជាពលករ ទៅស្លាប់នៅតំបន់ក ៥ ភាគច្រើនស្លាប់ដោយសារជម្ងឺគ្រុនចាញ់ជាន់មីនជាដើម។ នៅក្នុងពេលនោះ យួនកុម្មុយនិស្តជាអ្នកកាន់កាប់ប្រទេសខ្មែរទាំងស្រុង។ យួនបានដេញសម្លាប់ខ្មែរអ្នកតស៊ូនៅតាមជាយដែនទៀត ដោយធ្វើសង្គ្រាមបោសសំអាត សម្លាប់ខ្មែរដែលតស៊ូជាមួយយួននៅតាមជាយដែននៅឆ្នាំ ១៩៨៤។ ទីបំផុតខ្មែរតស៊ូតាមជាយដែនបានចាញ់យួន ហើយបានប្រមូលគ្នាទៅរស់នៅជំរំសាយធូ និងសាយប៊ី ជាដើម។ នៅឆ្នាំ ១៩៨៥ ទើបសហរដ្ឋអាមេរិកចាប់ផ្តើមផ្តល់ជំនួយដល់អ្នកតស៊ូ ដោយផ្តល់ទឹកប្រាក់ប្រមាណ ៥ លានដុល្លា ផ្តល់សម្ភារៈសឹក និងហ្វឹកហាត់ទាហាននៅក្លាំងដុង ។ ចំណែកយួនត្រូវបានអន្តរជាតិ និងប្រទេសក្នុងតំបន់ ដូចជា ចិន អាស៊ាន ថ្កោលទោសដោយសារ ការឈ្លានពានរំលោភអធិបតេយ្យភាពប្រទេសខ្មែរ លើកលែងតែប្រទេសឥណ្ឌូនេស៊ីនៅជាអាព្យាក្រិត ចំណែកប្រទេសរ៉ូស្ស៊ីប៉ុណ្ណោះដែលគាំទ្រយួន។ ក្រោយពីការដួលរលំរបស់សហភាពសូវៀតនៅឆ្នាំ ១៩៨៩ សូវៀតឈប់ផ្តល់ជំនួយអោយយួន ព្រោះរ៉ូស៊ីមានវិបត្តិហិរញ្ញវត្ថុ ដោយអស់ថិរវិកាពីទុនបំរុង។ ការអស់ថវិកាពីទុនបំរុងនេះ ព្រោះតែសហភាពសូវៀតពង្រឹងផ្នែកយោធាខ្លាំងពេក ជាពិសេស ខាតជាច្រើនចំពោះនយោបាយនៅឥណ្ឌូចិន តែចំណេញនៅខាងអឺរ៉ុបខាងកើត។ យួនចាញ់ប្រៀបខាងការទូត ចំពោះកម្លាំងអ្នកតស៊ូ ដែលជួយឧបត្ថម្ភដោយសហរដ្ឋអាមេរិក ចិន និងអាស៊ាន។ ប៉ុន្តែតាមការសិក្សាស្រាវជ្រាវឃើញថា កងទ័ពអ្នកតស៊ូខ្មែរ ពុំមានបច្ចេកទេសគ្រប់គ្រាន់ក្នុងការធ្វើសង្គ្រាមធ្វើអោយចាញ់ប្រៀបកងទ័ពយួនដែលមានការហ្វឹកហាត់ច្បាស់លាស់ សព្វាវុធគ្រប់គ្រាន់។ ពេលនោះ គេបានបញ្ជូនកងកម្លាំងតស៊ូខ្មែរអោយទៅរៀននៅ ម៉ាឡេស៊ី និងប្រទេសថៃ ។ ក្រោយមកទើបកម្លាំងតស៊ូមានប្រៀបលើយួនកុម្មុយនិស្ត និងពួកអាយ៉ង ហេង សំរិន ហ៊ុន សែន ព្រោះសូវៀតដែលជាសម្ព័ន្ធមិត្ររបស់យួនបានចាញ់អាមេរិកក្នុងសង្គ្រាមត្រជាក់ សូវៀតបានងាកទៅរកសហរដ្ឋអាមេរិកវិញ នៅក្នុងរដ្ឋាភិបាល កូ បាឆូវដើម្បីអោយសេដ្ឋកិច្ចរបស់ខ្លួនដំណើរការល្អវិញ។ ហេតុដូចនេះហើយ ទើបយួនបានផ្លាស់ប្តូរឥរិយាបថអោយ ហ៊ុន សែន និងសីហនុ ចចារចុះសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសនាថ្ងៃ ២៣ តុលា ១៩៩១ ដើម្បីប្រមូលខ្មែរអ្នកស្នេហាជាតិ ចូលក្នុងទ្រុងអោយពួកកុម្មុយនិស្តចាប់ខ្មែរសម្លាប់ម្តងមួយម្តងមួយ ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។

## VI. សង្គ្រាមរវាងខ្មែរអ្នកតស៊ូ ជាមួយយួនឈ្លានពាន និងរបបកុម្មុយនិស្តផ្តាច់ការ ហ៊ុន សែន ខុស ច្បាប់
(The War between Khmer Resistances with Vietnamese Aggressor and Illegal Dictactor Hun Sen)

ចាប់តាំងពីសង្គ្រាមឥណ្ឌូចិនលើកទី ២ នាទសវត្សទី ៦០ យួនតែងតែប្រើខ្មែរ ប្រើមេដឹកនាំខ្មែរដែលល្មោភអំណាច ជាឧបករណ៍បំរើនយោបាយអោយខ្លួន។ ដូចកាលពីឆ្នាំ ១៩៧០ យួនបានប្រើ សី ហនុ និង ប៉ុល ពត ជាឧបករណ៍ ជាគំរូបអោយអន្តរជាតិមើលឃើញថាសង្គ្រាមដែលកើតឡើងជាសង្គ្រាមស៊ីវិល ។ ចំណែកនៅឆ្នាំ ១៩៧៩ យួនបានប្រើពួកកុម្មុយនិស្ត ហ៊ុន សែន ជាឧបករណ៍សំរាប់បំរើនយោបាយអោយខ្លួន ខ្ចីដៃខ្មែរធ្វើសង្គ្រាមជាមួយខ្មែរទៀត ដូចកាលដែលយួនធ្វើសង្គ្រាមកាលពីឆ្នាំ ១៩៧០ ដែលយួនខ្ចីដៃខ្មែរក្រហម ប៉ុល ពត និងខ្មែរក្រហម សីហនុ មកធ្វើសង្គ្រាមជាមួយខ្មែរសាធារណរដ្ឋ។ នៅពេលនោះ យួនបានលុកលុយប្រទេសខ្មែរ

ពាសពេញផ្ទៃប្រទេស ហើយចាប់ផ្តើមធ្វើនយោបាយយួនទូបនីយកម្មនៅក្នុងប្រទេសខ្មែរ ដោយទាហានយួនបានយកប្រពន្ធខ្មែរ ចំណែកឯស្រីយួនបានយកប្តីខ្មែរ ហើយយួនចំនួន ៥ នាក់នៅទីក្រុង ឬទីប្រជុំជន ១ នាក់ ចំណែកនៅតាមជនបទយួន ១នាក់ខ្មែរ ៥ នាក់។ ដំណាក់កាលនេះ គឺមិនខុសពីសង្គ្រាមសម័យសាធារណរដ្ឋប៉ុន្មានទេ ព្រោះខ្មែរម្ខាងគាំទ្រដោយកុម្មុយនិស្តយួន ដែលមានពួកអាយ៉ង ហ៊ុន សែន ហើយម្ខាងទៀតគាំទ្រដោយ ចិន អាមេរិកកាំង អាស៊ាន ជាហេតុធ្វើអោយអ្នកតស៊ូតាមជាយដែនមានប្រៀបលើយួន និង របបកុម្មុយនិស្ត ហ៊ុន សែន ខុសច្បាប់។ ពេលដែលសហភាពសូវៀតបានដួលរលំ ហើយបញ្ចប់សង្គ្រាមត្រជាក់ជាមួយអាមេរិក នៅឆ្នាំ ១៩៨៩ ចំណែកប្រទេសអាល្លឺម៉ង់បានក្លាយទៅជាប្រទេសតែមួយ សូវៀតបានឈប់ជួយឧបត្ថម្ភយួន ពេលនោះយួនបានសំរេចចិត្តដកកងទ័ពស្លៀកពាក់ឯកសណ្ឋានចេញពីប្រទេសខ្មែរមុន តែយួនបានបង្កប់ទុកកងទ័ពយួន ដែលស្លៀកពាក់ស៊ីវិលជាច្រើននៅក្នុងប្រទេសខ្មែរវិញ។ យួនបានប្រើ ហ៊ុន សែន ទៅចរចារជាមួយ សី ហនុ ជាបន្តបន្ទាប់រហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅថ្ងៃ ២៣ តុលា ១៩៩១។ យួនធ្វើដូចនេះ ដើម្បីដោះដៃពីការថ្កោលទោសពីអន្តរជាតិ ថាយួនឈ្លានពានខ្មែរ ធ្វើអោយអន្តរជាតិមើលឃើញថាជាសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ។ បើយើងក្រឡេកមើលនៅក្នុងរបបខ្មែរក្រហមដែលមានខ្មែរស្លាប់រាប់លាន ក៏យួនធ្វើដូចនេះដែរ ដោយយួនយកខ្មែរទៅបណ្តុះបណ្តាលមនោគមន៍កុម្មុយនិស្ត ធ្វើជាពិឃាដមកសម្លាប់ខ្មែរ ហើយប្រើខ្មែរក្រហម សីហនុ ប៉ុល ពត ដើរតាមនយោបាយរបស់ខ្លួន បំភ័ន្តខ្មែរអោយវង្វេងរហូតមកដល់សព្វថ្ងៃ។ ការចរចាររវាង សីហនុ និង ហ៊ុន សែន ជាបន្តបន្ទាប់នៅ ប៉ាតាយ៉ា ប្រទេសថៃ នៅយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី ហើយនៅទីបំផុតនៅ ទីក្រុងប៉ារីសប្រទេស បារាំងនៅថ្ងៃ ២៣ តុលា ១៩៩១។

## VII‸សន្ធិសញ្ញាទីក្រុងប៉ារីស (Paris Agreement Treaties)

សន្ធិសញ្ញាទីក្រុងប៉ារីសបានធ្វើឡើង ក្រោយពីមានការចរចារជាបន្តបន្ទាប់រវាង សីហនុ និង ហ៊ុន សែន ចាប់ពីឆ្នាំ ១៩៨៧ មក។ ចំណែកសង្គ្រាមត្រជាក់រវាងកុម្មុយនិស្ត និងសេរីបានបញ្ចប់នៅឆ្នាំ ១៩៨៩។ សហភាពសូវៀតប្រើមនោគមន៍កុម្មុយនិស្ត ចំណែកសហរដ្ឋអាមេរិកប្រើមនោគមន៍សេរី និងប្រជាធិបតេយ្យ។ សហភាពសូវៀតជាអ្នកគាំទ្រយួនកុម្មុយនិស្តទាំងខាងបច្ចេកទេស អ្នកជំនាញការ និងសម្ភារៈសព្វាវុធ។ ក្នុងពេលនោះជំនាញការសូវៀតទាំងចល័ត និងអចិន្ត្រៃយ៍ជាច្រើនប្រមាណ ១ សែននាក់ ធ្វើការនៅក្នុងប្រទេសយៀកណាម។ ចំណែកឯប្រទេសចិន សហរដ្ឋអាមេរិក និងអាស៊ានជាអ្នកគាំទ្រចលនាតស៊ូខ្មែរទាំង ៣ក្រុម។ ខ្មែរទាំង៣ក្រុម នោះមានក្រុមទី១ រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរដឹកនាំដោយ លោកតា សឺន សាន ក្រុមទី ២ កម្ពុជា ប្រជាធិបតេយ្យដឹកនាំដោយ ខៀវ សំផន ចំណែកក្រុមទី៣ ហ៊្វុនស៊ិនប៉ិច ដឹកនាំដោយ នរោត្តម សីហនុ។ ដោយសារចិន សហរដ្ឋអាមេរិក និងអាស៊ាន បានដាក់សម្ពាធការទូតទៅលើរដ្ឋាបាលក្រុងហាណូយ និងនៅពេលដែលសហភាពសូវៀតបានដួលរលំ មិនអាចគាំទ្រយួនបន្តទៅទៀត ធ្វើអោយយួនចាញ់ប្រៀបខ្មែរអ្នកតស៊ូខាងការទូត និងនយោបាយក្នុងប្រទេសយួនបានដកកងទ័ពស្លៀកពាក់ឯកសណ្ឋានត្រឡប់ទៅវិញ តែទុកកងទ័ពស្លៀកពាក់ស៊ីវិល បង្កប់ទុកនៅក្នុងប្រទេសខ្មែរ តាមរយៈការបិទបាំងរបស់គណបក្សប្រជាជនកម្ពុជា ហ៊ុន

សែន។ យួនបានអោយ ហ៊ុន សែន មកចរចារជាមួយ សី ហនុ ដែលតំណាងអ្នកតស៊ូខ្មែរជំនួសវិញ។ ពេលនោះ យួនបានដោះដៃចេញពីការថ្កោលទោសពីឆាកអន្តរជាតិ ដោយអន្តរជាតិមើលឃើញថាសង្គ្រាមដែលកើតឡើងនៅប្រទេសខ្មែរជាសង្គ្រាមស៊ីវិល មិនមែនជាសង្គ្រាមឈ្លានពាននោះទេ។ ការចរចារគ្នាជាបន្តបន្ទាប់ រវាង ហ៊ុន សែន និង សីហនុ រហូតឈានទៅដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅថ្ងៃ ២៣ តុលា ១៩៩១ ដែលមាន ឥណ្ឌូនេស៊ី និង បារាំង ធ្វើជាសហប្រធានក្នុងពេលចុះហត្ថលេខាសន្ធិសញ្ញាសន្តិភាពបួនភាគី សឺន សាន តំណាងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ នរោត្តម រណឫទ្ធិ ហ៊្វុនស៊ិនប៉ិច ខៀវ សំផន កម្ពុជាប្រជាធិបតេយ្យ និង ហ៊ុន សែន រដ្ឋកម្ពុជា។ កាលដែលប្រទេសទាំង ២ នេះ ធ្វើជាសហប្រធាននោះ ពីព្រោះប្រទេសទាំង២ នេះ ជាប្រទេសអព្យាក្រិតនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី៣នេះ ដោយមិនគាំទ្រខាងយួន ឬគាំទ្រខាងខ្មែរអ្នកតស៊ូ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសបាននាំអោយប្រទេសខ្មែរ ឈប់បាញ់គ្នា និងធ្វើអោយប្រទេសឈានទៅរកលិទ្ធិប្រជាធិបតេយ្យសន្តិភាព តាមរយៈការរៀបចំបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិ ហៅកាត់ថា អ៊ុនតាក់នៅឆ្នាំ ១៩៩៣។ នៅពេលនោះគណបក្សហ៊្វុនស៊ិនប៉ិច ដឹកនាំដោយ នរោត្តម រណឫទ្ធិ ជាអ្នកឈ្នះឆ្នោត ទទួលសម្លេងបាន ៥៨ កៅអី ។ គណបក្សប្រជាជនកម្ពុជាបានចាញ់ឆ្នោតទទួលសម្លេងបាន ៥១ កៅអី។ ហ៊ុន សែន រៀបចំធ្វើអប្បគមន៍នៅត្រើយខាងកើតទន្លេមេគង្គ ដើម្បីធ្វើសង្គ្រាម។ សី ហនុ បានដេញអង្គការសហប្រជាជាតិចេញពីទឹកដីខ្មែរ ហើយចែកអំណាចអោយពួកកុម្មុយនិស្ត ហ៊ុន សែន ដែលមានយួននៅពីក្រោយខ្នងធ្វើជានាយករដ្ឋមន្ត្រីទី២។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃ ២៣ តុលា ១៩៩១ ជាចំណុចរបត់នយោបាយមួយយ៉ាងសំខាន់សំរាប់ប្រវត្តិសាស្ត្រខ្មែរ និងជាក្តីសង្ឃឹមសំរាប់ប្រជាជាតិខ្មែរទូទៅ ពីព្រោះថា កិច្ចព្រមព្រៀងនេះ បាននាំខ្មែរឈានទៅរកសន្តិភាព និងលិទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ ប៉ុន្តែផ្ទុយទៅវិញ កិច្ចព្រមព្រៀងនោះត្រូវបានលុបបំបាត់ចោល ប្រែជាឥតន័យ ដោយជនកុម្មុយនិស្តផ្តាច់ការ ហ៊ុន សែន មិនគោរពតាមកិច្ចព្រមព្រៀងនេះឡើយ ថែមទាំងធ្វើរដ្ឋប្រហារសម្លាប់អ្នកស្នេហាជាតិខ្មែរ អ្នកប្រជាធិបតេយ្យ នៅថ្ងៃ ៥-៦ កក្កដា ១៩៩៧ រំលោភសិទ្ធិមនុស្សជាបន្តបន្ទាប់។ ជនផ្តាច់ការ ហ៊ុន សែន ដែលជាឧបករណ៍នយោបាយរបស់យួន បាននាំប្រទេសខ្មែរអោយធ្លាក់ចូលក្នុងរបបកុម្មុយនិស្តក្រោមយួនត្រួតត្រាដដែល។

## VIII-ដើមកំណើតលិទ្ធិប្រជាធិបតេយ្យសារឡើងវិញ (The Democracy Was Reborn)

ដើមកំណើតលិទ្ធិប្រជាធិបតេយ្យសារឡើងវិញ គឺនៅពេលដែលអង្គការសហប្រជាជាតិ បានរៀបចំបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជានាឆ្នាំ ១៩៩៣។ ប្រទេសជាតិត្រូវខាតបង់ជាច្រើននៅក្នុងសង្គ្រាមលុកលុយរបស់យួននេះ យួនជាអ្នកចំណេញគ្រប់បែបយ៉ាង រាប់ចាប់តាំង ទ្រព្យសម្បត្តិ លើដី ក្រោមដី ដែលយួនឆក់ប្លន់យកទៅប្រទេសគេ បាត់ទឹក បាត់ដី តាមសិទ្ធិសញ្ញាខុសច្បាប់រវាងអាយ៉ងយួន និងពួកឈ្លានពាន។ ការពលីជីវិតរបស់ខ្មែរអ្នកស្នេហាជាតិ និងបងប្អូនជនរួមជាតិខ្មែរទាំងអស់ ប្រែជាឥតន័យ ដោយសារមេដឹកនាំឆ្កួតលីលា តាមខ្សែញាក់នយោបាយរបស់យួនកុម្មុយនិស្ត ដូចស្តេច សីហនុ និង ហ៊ុន សែន។ យើងសង្កេត

ឃើញថានៅឆ្នាំ ១៩៩៣ ប្រជាពលរដ្ឋបានទៅបោះឆ្នោតយ៉ាងច្រើនកុះករ ដោយសារចង់អោយប្រទេសមានការផ្លាស់ប្តូរប្រទេសជាតិមានការរីកចំរើនតាមប្រជាធិបតេយ្យ ពីព្រោះ ប្រជាពលរដ្ឋខ្មែររស់នៅរងនូវការគៀបសង្កត់ជិះជាន់ ធ្វើទុក្ខបុកម្នេញ បិទសិទ្ធិសេរីភាព ពីពួកអាយ៉ង ហ៊ុន សែន និង យួនកុម្មុយនិស្ត ជាយូរមកហើយ។ អង្គការសហប្រជាជាតិ ជាអ្នករៀបចំការបោះឆ្នោតមួយដោយសេរី និងយុត្តិធម៌។ ពីព្រោះខ្មែរ ដែលធ្លាប់រស់នៅរងការគៀបសង្កត់ជិះជាន់ ធ្វើបាបគ្រប់បែបយ៉ាងរបស់ពួកអាយ៉ង និងយួនកុម្មុយនិស្ត។ ប៉ុន្តែប្រជាពលរដ្ឋខ្មែរអស់សង្ឃឹម ដោយសារ សី ហនុ បានដេញអង្គការសហប្រជាជាតិចេញពីប្រទេស ហើយប្រគល់អំណាចអោយពួកកុម្មុយនិស្ត ហ៊ុន សែន វិញ។ កាលនោះ គេឃើញប្រទេសខ្មែរដឹកនាំដោយនាយករដ្ឋមន្ត្រី ២ គឺនាយកមន្ត្រីទី១ នរោត្តម រណរិទ្ធិ និង នាយករដ្ឋមន្ត្រីទី២ គឺ ហ៊ុន សែន។ ចាប់ពីឆ្នាំ ១៩៩៣ មកដល់ឆ្នាំ ១៩៩៧ ប្រទេសខ្មែរបានស្គាល់នៅពន្លឺប្រជាធិបតេយ្យមួយរយៈពេលខ្លី តែក្រោយមកពួកកុម្មុយនិស្ត ហ៊ុន សែនបានធ្វើរដ្ឋប្រហារសម្លាប់អ្នកប្រជាធិបតេយ្យ អ្នកស្នេហាជាតិអស់ប្រមាណជាង ២៨០ នាក់។ មាតុភូមិជាទីស្នេហារបស់យើង បានធ្លាក់ចុះសន្សឹមបន្តិចម្តងៗ ចូលទៅក្នុងកណ្តាប់ដៃរបស់ជនផ្តាច់ការ ហ៊ុន សែន ដែលស្ថិតនៅក្រោមយួនត្រួតត្រាមិនចេញមុខ រហូតមកដល់បច្ចុប្បន្ន។

## IX-ការធ្លាក់ចុះប្រជាធិបតេយ្យ (Declining down the Democracy)

ការធ្លាក់ចុះប្រជាធិបតេយ្យទៅក្នុងកណ្តាប់ដៃរបស់ពួកកុម្មុយនិស្តគឺចាប់តាំងពី ហ៊ុន សែន ធ្វើរដ្ឋប្រហារដណ្តើមអំណាចពីគណបក្សហ៊្វុនស៊ិនប៉ិច ដឹកនាំដោយ នរោត្តម រណរិទ្ធ នៅថ្ងៃទី ៥-៦ កក្កដា ១៩៩៧ ម្លេះ។ ហ៊ុន សែន លើកបន្តុប អ៊ឹង ហ៊ួត ជាតុក្កតាជំនួសវិញ។ ការធ្វើរដ្ឋប្រហារនេះ ជាផែនការរបស់ពួកកុម្មុយនិស្តដែលមានយួន ជាមេក្លោង ដើម្បីផ្តាច់ឬសគល់អ្នកស្នេហាជាតិ អ្នកប្រជាធិបតេយ្យដែលមានកម្លាំងខ្លាំងអោយអស់ដើម្បីងាយស្រួលយួននិង ពួកអាយ៉ង ធ្វើបាបប្រជាពលរដ្ឋខ្មែរដូចបច្ចុប្បន្ន។ កាលនោះគេឃើញមានអ្នកប្រជាធិបតេយ្យ និងអ្នកស្នេហាជាតិជាច្រើន នៅក្នុងគណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនារបស់លោកតា សឺន សាន ត្រូវគេចាប់យកទៅសម្លាប់ដូចជា ហូ សុខ ក្រូច យឿម ចៅសម្បត្តិ ជា រិទ្ធីឈុត និងជាច្រើននាក់ទៀត ប្រមាណជិត ៣០០នាក់។ ចំណែកអ្នកដែលរួចខ្លួននៅសែសល់បានរត់ទៅកាន់តំបន់ អូស្មាច់ ហើយធ្វើការតស៊ូជាមួយពួក ហ៊ុន សែន និង យួនកុម្មុយនិស្តទៀត។ ពួក ហ៊ុន សែន បានលើកអំណាច ខ្យល់ទៅអោយ អ៊ឹង ហ៊ួត ជំនួសវិញ ដូចកាលដែលយួនចូលមកឈ្លានពានខ្មែរ ថ្ងៃ ៧ មករា ១៩៧៩ ហើយលើកអំណាចខ្យល់អោយ ហេង សំរិន និង ហ៊ុន សែន ដែរ។ ពេលដែលពួក ហ៊ុន សែន មិនអាចវាយបែកក្រុមអ្នកតស៊ូនៅអូស្មាច់ប្រមាណ ៣០០នាក់ ។ ពេលនោះ ព្រឹទ្ធសភាសហរដ្ឋអាមេរិក រ៉ូណា បែគ័រ បានចុះមកត្រួតពិនិត្យផ្ទាល់ដល់តំបន់អូស្មាច់ ដំណឹងនេះបានធ្វើអោយ សីហនុ ប្រាប់កូននរោត្តម រណរិទ្ធិ អោយហៅ ញឹក ប៊ុនឆៃ ខាន់ សាវឿន ត្រឡប់ចូលទៅក្នុងប្រទេសវិញ ដោយសន្យាថាអោយតំណែងជាដើម តែទីបំផុតអំណាចនោះ ត្រូវពួកកុម្មុយនិស្តដកបន្តិចម្តងៗរហូតដល់ចប់តែម្តង។ អ្វីដែលប្រជាពលរដ្ឋខ្មែរនៅតែភ័ន្តច្រឡំនោះយល់ថា ស្តេច សីហនុ ជាអ្នកស្រឡាញ់កូនចៅប្រជាពលរដ្ឋខ្មែរពិតប្រាកដ ដែលអ្នកស្នេហាជាតិខ្មែរ

អ្នកប្រជាធិបតេយ្យខំដង្ហែរតាមព្រះអង្គតាំងពីតស៊ូព្រៃម៉ាគី តស៊ូតាមជាយដែនខ្មែរ-ថៃ ដោយការយល់ច្រឡំស្មានថាស្តេច សីហនុ បំរើផលប្រយោជន៏អោយជាតិខ្មែរ ស្រឡាញ់ការពារប្រជាពលរដ្ឋខ្មែរ តែទីបំផុត ស្តេច សីហនុ ជាជនកុម្មុយនិស្ត ដែលក្លែងខ្លួនទៅតាមជំនោរនយោបាយបំរើអោយកុម្មុយនិស្ត តាមការញោក់ប្រមូលខ្មែរអ្នកស្នេហាជាតិ មកអោយពួកកុម្មុយនិស្តសម្លាប់ជាថ្មី ។ សី ហនុ ប៉ុល ពត ហ៊ុន សែន សុទ្ធតែជាជនកុម្មុយនិស្ត ដែលហៅថា ខ្មែរ ក្រហម ។

ដូច្នេះហើយ យើងឃើញថា ការបោះឆ្នោតដែលកើតឡើងជាបន្តបន្ទាប់ក្រោយពីរដ្ឋប្រហារឆ្នាំ ១៩៩៧ ជាការរៀបចំរបស់គណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ លទ្ធផលបោះឆ្នោតទាំងអស់នោះ មិនមែនចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរពិតប្រាកដទេ។ ការធ្លាក់ទៅក្នុងអំណាចរបស់ពួកកុម្មុយនិស្តនេះហើយ ធ្វើអោយពួកប្រជាធិបតេយ្យ ពួកអ្នកស្នេហាជាតិខ្មែរ ត្រូវគេសម្លាប់ជាបន្តបន្ទាប់មកទៀត ដោយគ្មានរកឃាតករមកផ្តន្ទាទោសឡើយ។ ប្រទេសបានធ្លាក់ក្នុងកណ្តាប់ដៃរបស់មនុស្សតែម្នាក់ រដ្ឋជាអ្នកសំរេចកិច្ចការគ្រប់បែបយ៉ាង ប្រជាពលរដ្ឋខ្មែរ គ្មានសិទ្ធិសេរីភាពក្នុងការសំរេចកិច្ចការទាំងឡាយ ព្រោះខ្លាចគេប្រើប្រព័ន្ធ តុលាការ និងអំណាច ចាប់ដាក់គុក និងគំរាមកំហែងសំលាប់ជាដើម។

## X-ប្រទេសខ្មែរធ្លាក់ក្នុងរបបផ្តាច់ការ ហ៊ុន សែន ក្រោមអាណានិគមន៍យួនបែបថ្មី
(Cambodia fell into Hun Sen Dictatorship under Vietnamese Neo-Colonism)

បើយើងក្រឡេកមើលប្រវត្តិសាស្ត្រខ្មែរយើង ចាប់តាំងពីសម័យត្រសក់ផ្អែមមក ឃើញថាអតីតកាលមានការច្របូកច្របល់ មិនច្បាស់លាស់ ព្រោះគម្ពីរក្បួនខ្នាតត្រូវបានគេបំផ្លាញចោល លុបប្រវត្តិសាស្ត្រ គ្មានការកត់ត្រាច្បាស់លាស់។ កត្តាទាំងនេះ ធ្វើអោយប្រទេសខ្មែរធ្លាក់ក្នុងភាពច្របូកច្របល់ សង្គ្រាមរីករ៉ៃ មិនចេះចប់ ដោយសារការពឹងលើបរទេស មិនជឿ និងអោយតំលៃជាតិសាសន៏ខ្លួនឯង។ គន្លងប្រវត្តិសាស្ត្រនេះ បានធ្លាក់មកលើប្រទេសខ្មែរម្តងហើយម្តងទៀត រហូតមានការកាប់សម្លាប់ខ្មែរ ជិតផុតពូជនៅក្នុងសម័យ ប៉ុល ពត។ គម្ពីរក្បួនខ្នាត ប្រវត្តិពង្សាវតាត្រូវគេដុតបំផ្លាញអស់ ថែមទាំងក្លែងប្រវត្តិសាស្ត្រក្លែងក្លាយ មកអោយកូនចៅខ្មែរជំនាន់ក្រោយរៀនសូត្រទៀតផង។ ជាក់ស្តែងនៅក្នុងប្រវត្តិសាស្ត្រខ្មែរថ្មីៗនេះ ក្រោយពីខ្មែរបានទទួលឯករាជ្យពីបារាំងមក យើងឃើញថាការកែក្រឡៃប្រវត្តិសាស្ត្រ ដើម្បីបំភ័ន្តខ្មែរអោយគាំទ្រ ព្រោះអំណាច និងរាជបល្ល័ង្កប៉ុណ្ណោះ។ យួនបានរៀបចំឆាកនយោបាយនៅក្នុងតំបន់ឥណ្ឌូចិន បង្កើតជាបក្សកុម្មុយនិស្ត នៅតាមបណ្តាប្រទេសនីមួយៗ មាន លាវ ខ្មែរ ជាដើម។ យួនជាអ្នកបង្កើតអោយមានខ្មែរក្រហម (ខ្មែរកុម្មុយនិស្ត)។ ក្រោយមកយួនបានប្តូរខ្មែរក្រហម ដែលដឹកនាំដោយ ប៉ុល ពត និង សីហនុ ដោយលើកខ្មែរក្រហម ហេង សំរិន ជា ស៊ីម ហ៊ុន សែន អោយកាន់អំណាច បំរើនយោបាយអោយខ្លួនបន្តទៅទៀត។ ដូច្នេះហើយ យើងឃើញថា ប្រទេសខ្មែរបាន ធ្លាក់ក្នុងការកាន់កាប់របស់យួនកុម្មុយនិស្តតាំងពីថ្ងៃ ៧ មករា ១៩៧៩។ ថ្ងៃ ៧ មករា ១៩៧៩ មិនមែនជាថ្ងៃយួនមកជួយខ្មែរទេ ជាថ្ងៃយួនឈ្លានពានលេបទឹកដីខ្មែរ ផ្លាស់ប្តូរនយោបាយថ្មី ដើម្បីបំភ័ន្តខ្មែរតែប៉ុណ្ណោះ។ អ្នកកាច់ចង្កូតនយោបាយ គឺចេញពីយួនហាណូយដដែល ព្រោះយួនបានរៀបផែនការ ផ្តាច់ឫសគល់ជាតិ

ខ្មែរ គឺសម្លាប់តែនិស្សិតបញ្ញវន្ត ។ ពួកកុម្មុយនិស្ត កំពុងតែឃោសនាគ្រប់បែបយ៉ាង អោយមតិប្រជាពលរដ្ឋ មតិជាតិ និងអន្តរជាតិមើលឃើញថា ប្រទេសខ្មែរជាប្រទេសប្រជាធិបតេយ្យ ***តែផ្ទុយទៅវិញប្រទេសខ្មែរស្ថិតនៅក្នុងរបបផ្តាច់ការ ហ៊ុន សែន ក្រោមអាណានិគមន៍យួនបែបថ្មី***។ យួនក្លែងភេទជាខ្មែរ ត្រួតត្រាខ្មែរ ពាក់ផ្លាកប្រជាធិបតេយ្យ តាំងស្តេចជាវនាំងបាំង កុំអោយខ្មែរមើលឃើញពីគោលបំណងនយោបាយត្រជាក់របស់ពួកវា ដើម្បីលេបទឹកដីខ្មែរទាំងមូល។ ចាប់ពីយួនដកទ័ពឯកសណ្ឋានយោធាទៅ បន្សល់ទុកកងទ័ព ឯកសណ្ឋានស៊ីវិល អោយកាន់កាប់តំណែងខ្ពស់ៗ សំខាន់ៗ ធ្វើអោយខ្មែរយើងវង្វេង និង កលល្បិចនយោបាយរបស់យួន ធ្វើអោយប្រជាពលរដ្ឋខ្មែរយល់ថា ប្រទេសខ្មែរបានសុខសន្តិភាព។ តែផ្ទុយទៅវិញ ខ្មែរកំពុងតែរងទុក្ខវេទនាគ្រប់បែបយ៉ាង ដោយរបបផ្តាច់ការរបស់ ហ៊ុន សែន ដែលយួនបានលើកបន្តុបតាំងពីឆ្នាំ ១៩៧៩។ ឥឡូវនេះ ប្រទេសខ្មែរមានតែសំបកខាងក្រៅថាជាខ្មែរ តែតាមពិតខ្មែរត្រូវស្ថិតនៅក្នុងអាណានិគមន៍យួនបែបថ្មី ដោយយួនយករូបភាពក្រុមហ៊ុន ច្បាប់ ការចោទប្រកាន់ ចាប់ដាក់គុក ដើម្បីគំរាមកំហែង បំបាក់ស្មារតីខ្មែរខ្លាចមិនហ៊ានប្រឆាំងជាមួយនិងពួកវា។

### XI. គ្មានតុល្យភាពខាងនិតិបញ្ញត្តិ នីតិប្រតិបត្តិ និងនិតិតុលាការ
(No Balance in Legislative, Executive and Court)

តាមគោលការណ៍ប្រជាធិបតេយ្យ អំណាចរដ្ឋទាំងបី(និតិបញ្ញត្តិ និតិប្រតិបត្តិ តុលាការ) ត្រូវតែមានអំណាចស្មើរគ្នា ហើយស្ថិតនៅដាច់ដោយឡែកពីគ្នា។ ប៉ុន្តែ ចំពោះការដឹកនាំនៅក្នុងប្រទេសខ្មែរវិញ មិនមែនជាប្រទេសដែលកាន់លិទ្ធិប្រជាធិបតេយ្យ មានសិទ្ធិសេរីភាព ពិតប្រាកដទេ ព្រោះយើងឃើញថាអំណាចទាំង ៣ នេះស្ថិតនៅក្រោមតែមនុស្សតែម្នាក់ គឺហ៊ុន សែន។ ពួកកុម្មុយនិស្តយកប្រជាធិបតេយ្យសេរីពហុបក្ស មកបិទបាំងថាជាប្រទេសប្រជាធិបតេយ្យសេរី ដើម្បីបំភ័ន្តភ្នែកប្រជាពលរដ្ឋខ្មែរ។ យើងសង្កេតឃើញថា ប្រជាធិបតេយ្យនៅក្នុងប្រទេសខ្មែរខុសពីគោលការណ៍ប្រជាធិបតេយ្យពិតប្រាកដ។ អំណាចតុលាការ គ្មានឯករាជ្យ ពុករលួយ អយុត្តិធម៌ លំអៀងទៅអ្នកមានលុយ និងអ្នកមានអំណាច ជាពិសេស អំណាចតុលាការ ខ្លាចអំណាច ហ៊ុន សែន ដែលជាកូនអុករបស់យួន។ តាមពិតតុលាការមិនត្រូវស្ថិតនៅក្រោមឥទ្ធិពលបុគ្គលណាម្នាក់ គណបក្សនយោបាយណាមួយឡើយ។ ចំណែកឯអំណាចនិតិបញ្ញត្តិវិញ សមាជិកសភា ព្រឹទ្ធសភាភាគច្រើន មិនបានដើរតួរជាអ្នកតំណាងរាស្ត្រ តំណាងប្រជាពលរដ្ឋ ពិតប្រាកដទេ បែជាតំណាងអោយបក្សទៅវិញ។ ការជជែកពិភាក្សាដោះស្រាយមិនបានស្វះស្វែងរកផលប្រយោជន៍ជាតិ ការពារផលប្រយោជន៍ជាតិ តែនាំគ្នាខិតខំដើម្បីដណ្តើមអំណាចគ្នា ការពារអំណាច ប្រព្រឹត្តិ អំពើពុករលួយ គេងប្រវ័ញ្ច ជញ្ជក់ឈាមពីជាតិ សាសនា និង ប្រជាជាតិខ្មែរ មកដាក់ផលប្រយោជន៍ផ្ទាល់ខ្លួន ប៉ុណ្ណោះ។

#### ១-ព័ត៌មាន (Information)

ព័តិមានត្រូវតែឯករាជ្យ មានសេរីភាពពេញលេញបើកចំហរ។ ចំពោះប្រព័ន្ធសារព័តិមាននៅក្នុងប្រទេសខ្មែរវិញ យើងឃើញថា ស្ទើរតែគ្រប់បណ្តាញផ្សព្វផ្សាយពតិមាន វិទ្យុ ទូរទស្សន៍ ការសែតភាគច្រើន ត្រូវគ្រប់គ្រងដោយគណបក្សកាន់អំណាច ឬស្ថិតនៅក្រោមឥទ្ធិពលរបស់ (គណបក្សប្រជាជនកម្ពុជា)។ នេះចំណុច

មួយទៀត ដែលផ្ទុយពីគោលការណ៍របស់ប្រជាធិបតេយ្យពិតប្រាកដ ព្រោះថាតាមគោលការណ៍ប្រជាធិបតេយ្យពិតប្រាកដ ពត៌មានត្រូវធ្វើតាមវិជ្ជាជីវៈ ឯករាជ្យត្រឹមត្រូវសំរាប់ឆ្លុះបញ្ចាំងទង្វើរបស់មេដឹកនាំ និងអ្វីដែលកើតមាននៅក្នុងសង្គមពិតប្រាកដ។ ប្រទេសដែលកាន់លិទ្ធិប្រជាធិបតេយ្យសេរី ប្រព័ន្ធសារព័ត៌មានត្រូវតែឯករាជ្យមិនលំអៀងទៅរកគណបក្សនយោបាយណាមួយឬស្ថិតនៅក្រោមអំណាចរបស់បុគ្គលណាម្នាក់។ បើយើងក្រឡេកមើលការដឹកនាំនៅក្នុងប្រទេសខ្មែរវិញ តើជាប្រទេសប្រជាធិបតេយ្យ ឬផ្តាច់ការ បើមានមេដឹកនាំតែម្នាក់កាន់អំណាច ចំណែកអ្នកសារពត៌មាន មិនហ៊ានសរសេរការពិតនៅក្នុងសង្គម ភាគច្រើនសរសើររដ្ឋាភិបាល បើសិនជាហ៊ានរិះគន់ ត្រូវគេគំរាមកំហែង គៀបសង្កត់ចោទប្រកាន់ ប្តឹងអំពីបទបរិហារកេរ្តិ៍ ញុះញង់ ចាប់ឬបាញ់សម្លាប់ជាដើម។ ជាក់ស្តែងនៅក្នុងពេលថ្មីៗនេះ អ្នកការសែត គឹមសម្បូរ ត្រូវគេបាញ់សម្លាប់ អ្នកនិពន្ធការសែតខ្មែរម្ចាស់ស្រុកមួយរូបឈ្មោះ ហង្ស ចក្រា ត្រូវគេប្តឹង ហើយចាប់ដាក់គុករយៈពេល ២ ឆ្នាំ។ ឯលោកមឿង សុន ត្រូវគេចោទប្រកាន់ថា ផ្សាយព័ត៌មានមិនពិត និងញុះញង់ ដោយសារតែលោកនិយាយការពិតប្រាប់ប្រជាពលរដ្ឋខ្មែរ អំពីការប៉ះពាល់អច្ឆរិយវត្ថុខ្មែរ អង្គរវត្ត ដែលត្រូវពួកជនពុករលួយ យួន សុខ គង់ កំពុងតែដាប់ថ្មប្រាសាទដាក់អំពូលភ្លើង។ ហេតុនេះហើយ បើសិនជាខ្មែរយើងហ៊ាននិយាយពីការពិតនៅក្នុងសង្គម ពួកគេត្រូវប្រឈមមុខគ្រោះថ្នាក់ដល់អាយុជីវិតនិង សុវត្ថិភាព ព្រួយបារម្ភ ពីសុវត្ថិភាព និងសន្តិសុខ។ អ្នកសារព័ត៌មាន អ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យភាគច្រើន ដែលឃាតករបាញ់សម្លាប់អាជ្ញាធរ ហ៊ុន សែន មិនដែលចាប់ឃាតករ ឬជនល្មើសយកមកផ្តន្ទាទោសឡើយ តែផ្ទុយទៅវិញ ពួកគេចាប់តែជនស្លូតត្រង់មកដាក់កំហុសជំនួសវិញ។ ពត៌មានមិនបានបើកទូលំទូលាយដល់ប្រជាពលរដ្ឋអោយបានដឹង ផ្ទុយទៅវិញ អ្នកដែលស្តាប់វិទ្យុ អាស៊ីសេរី វីអូអេ ត្រូវគេបំភិតបំភ័យ គំរាមកំហែង ហាមមិនអោយស្តាប់។



យួន សុខ គង់ ដាប់ថ្មប្រាសាទអង្គរវត្ត បំផ្លាញអច្ឆរិយវត្ថុខ្មែរ

### ២ -ការអប់រំ (Education)

ការអប់រំត្រូវមានទាំងគុណភាព និងបរិមាណសំរាប់ប្រជាពលរដ្ឋខ្មែរទូទៅ។ ដោយសារអំពើពុករលួយ ក៏រិតអប់រំនៅក្នុងប្រទេសខ្មែរនៅតែមិនទាន់មានគុណភាពសិក្សាគ្រប់គ្រាន់ តាមក៏រិតតំបន់ ក៏រិតអន្តរជាតិ ឬមានក៏រិតស្មើនឹងប្រទេសជិតខាងឡើយ ដោយប្រព័ន្ធអប់រំមានអំពើពុករលួយ ខ្វះសម្ភារៈសិក្សា ខ្វះពេលវេលា សិក្សា

ស្រាវជ្រាវដោយសារតែជីវភាពក្រីក្រ គ្រូប្រាក់ខែមិនគ្រប់គ្រាន់ ជាហេតុធ្វើអោយគ្រូគ្មានទឹកចិត្តក្នុងការបង្រៀន និងជាពិសេសស្ថិតនៅក្រោមគំនាបឥទ្ធិពលនយោបាយ មិនបានលើកតំកើងអោយរៀនប្រវត្តិសាស្ត្រខ្មែរពិតប្រាកដ និងមិនបានអប់រំអោយចេះស្រឡាញ់ជាតិរបស់ខ្លួន។ ការមិនប្រាប់ពីគោលបំណងគោលដៅដល់សិស្សអោយបាន ច្បាស់លាស់ ដើម្បីធ្វើប្រយោជន៍ជូនជាតិមាតុភូមិ ការពារផលប្រយោជន៍ជាតិ តែបង្រៀនអោយខ្មែរមើលឃើញ លុយជារឿងសំខាន់ និងរៀនដើម្បីស្វែងរកការងារ រកលុយជាដើម។ គ្រូបង្រៀនគ្មានសិទ្ធិសេរីភាពគ្រប់គ្រាន់ ក្នុងការនិយាយការពិត ពីបញ្ហាសង្គមនៅក្នុងប្រទេស ដោយសារការគៀបសង្កត់ពីនាយកសាលាដែលគេបង្ខំ អោយបំរើគណបក្សប្រជាជនកម្ពុជា។ អ្នកដែលហ៊ាននិយាយប្រាប់សិស្សពីរឿងសង្គម ត្រូវបាន គេគំរាមកំហែងថា ខុសសីលធមិ ឫដកហូតសិទ្ធិមិនអោយបង្រៀន ជាក់ស្តែងថ្មីៗនេះ លោកគ្រូ ស៊ុន ធុន ជាគ្រូបង្រៀននៅ ខេត្តកំពង់ធំជាដើម។ នៅក្នុងប្រព័ន្ធអប់រំបានកាត់បន្ថយមិនអោយសិក្សារៀនប្រវត្តិសាស្ត្រ ភូមិសាស្ត្រពិតប្រាកដ របស់ខ្មែរ ដែលអាចប៉ះពាល់ទៅលើមេដឹកនាំនយោបាយ កំពុងតែធ្វើនយោបាយ បំផ្លិចបំផ្លាញផលប្រយោជន៍ជាតិ ធ្វើអោយខ្មែរវង្វេងរកការពិត មិនឃើញគ្មានឯកភាពគ្នា ឈ្លោះប្រកែកគ្នា បែកបាក់តាមមនោគមន៍នយោបាយ របស់យួនកុម្មុយនិស្ត និងពួកអ្នកកាន់អំណាចដែលមិននិយាយការពិត។

### ៣-ការបោះឆ្នោត (The Election)

ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតដូចៗគ្នា ។ ការបោះឆ្នោតត្រូវរៀបចំដោយសេរី និងយុត្តិធមិ។ ការ បោះឆ្នោតក្រោយៗមក លើកលែងតែការរៀបចំដោយអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៩៣ វាជាការបោះឆ្នោត ដែលគ្មានយុត្តិធមិត្រឹមត្រូវទេ។ លទ្ធផលបោះឆ្នោតទាំងអស់នោះ មិនបានចេញពីឆន្ទៈប្រជាពលរដ្ឋខ្មែរ ពិតប្រាកដទេ តែជាលទ្ធផលដែលរៀបចំឡើងដោយគណបក្សប្រជាជនកម្ពុជា ដែលមានយួននៅពីក្រោយខ្នង និងចារកម្មយួន ដែលបន្លំខ្លួនធ្វើជាខ្មែរជាច្រើននាក់។ គណៈកម្មការរៀបចំការបោះឆ្នោត គ្មានឯករាជ្យ អព្យាក្រិត្យ ត្រឹមត្រូវ ព្រោះគណៈកម្មការនេះស្ថិតនៅក្រោមអំណាច ឥទ្ធិពលគណបក្សប្រជាជន និងហ៊ុន សែន។ សមាជិក ដែលធ្វើការនៅក្នុងគណៈកម្មការរៀបចំការបោះឆ្នោតភាគច្រើន ជាសមាសភាពគណបក្សប្រជាជនកម្ពុជា។ បើទោះជាការបោះឆ្នោតឈ្នះលើអ្នកស្នេហាជាតិ អ្នកប្រជាធិបតេយ្យហើយក៏ដោយ ក៏ពួកកុម្មុយនិស្តទាំងនេះ ដែលមានយួនលូកដៃយ៉ាងជ្រៅកក្កូរស្ថានការណ៍នយោបាយខ្មែរនោះ ធ្វើរដ្ឋប្រហារសម្លាប់ខ្មែរ ដណ្តើមអំណាច ដូច ករណីរដ្ឋប្រហារថ្ងៃ ៥-៦ កក្កដា ១៩៩៧ ទៀតជាក់ជាមិនខានឡើយ។

### ៤-សេរីភាពក្នុងការបញ្ចេញមិតិ (Freedom of Expression)

សេរីភាពក្នុងការបញ្ចេញមិតិសំរាប់ប្រជាពលរដ្ឋខ្មែរ មានតែនៅលើក្រដាស មានតែលើរដ្ឋធម្មនុញ្ញ តែការ អនុវត្តជាក់ស្តែងគ្មាន។ ពួកអាជ្ញាធរ ហ៊ុន សែន បិទសិទ្ធិសេរីភាព គៀបសង្កត់ជិះជាន់ វាយធ្វើបាប ទាំងព្រះសង្ឃ ទាំងប្រជាពលរដ្ឋដោយគ្មានត្រាប្រណីឡើយ។ ប្រជាពលរដ្ឋត្រូវគេហាមឃាត់មិនអោយនិយាយ អំពីរឿងប្រទេស ជាតិ គ្មានសិទ្ធិក្នុងការជួបប្រជុំផ្សេងៗ គ្មានសេរីភាពគ្រប់គ្រាន់ក្នុងការបញ្ចេញមតិនៅទីកន្លែងសាធារណៈ។ នាពេលថ្មីៗនេះ ពេលដែលអាជ្ញាធរអបរ្យរាបានដាប់ថ្មប្រាសាទអង្គរវត្ត ដើម្បីដាក់ភ្លើង ធ្វើអោយប៉ះពាល់

ដល់ប្រាសាទអង្គរវត្ត ជាវត្ថុអច្ឆរិយ ជាអត្តសញ្ញាណរបស់ខ្មែរ ដែលបុព្វបុរសខ្មែរបានកសាងទុកអោយខ្មែរ។ ការធ្វើបែបនេះបុព្វបុរសខ្មែរមានការក្តៅក្រហាយ ធ្វើអោយអ្នកស្នេហាជាតិហ៊ានងើបឡើង ដើម្បីការពារប្រាសាទអង្គរវត្ត ការពារទឹកដី ដោយមិនបណ្តោយអោយអ្នកបំផ្លាញជាតិ អ្នកបំផ្លាញវត្ថុបូរាណ ធ្វើស្រេចតែចិត្តនោះឡើយ។ អ្នកដែលនិយាយពីរឿងប្រទេសជាតិ ត្រូវគេចោទថាជារឿងនយោបាយ ហើយត្រូវបានគេគំរាមកំហែង ត្រូវបានគេចាប់ដាក់គុក ឬតាមសម្លាប់ដើម្បីបំបាក់ស្មារតី ដូចជាប្រើប្រព័ន្ធតុលាការតាមចាប់ លោកមឿងសុន ចោទប្រកាន់ចាប់លោក ហង្ស ចក្រា ដាក់គុក ដកអភ័យឯកសិទ្ធិរបស់អ្នកស្រី មូសុខហួរ និងអ្នកតំណាងរាស្ត្រ ហូ វ៉ាន់ ជាដើម។ អ្នកដែលហ៊ានការពារផលប្រយោជន៍ជាតិត្រូវគេតាមចាប់តាមសម្លាប់ ដូចជាលោក ជា វិជ្ជា ត្រូវគេសម្លាប់ ទូច ស្រីនិច ពិសិដ្ឋ ពាលីការត្រូវគេបាញ់សម្លាប់ និងព្រះតេជគុណ ទឹម សាខនត្រូវបានគេចាប់យកទៅដាក់គុកយួនជាដើម។ ព្រឹត្តិការណ៍ទាំងអស់នេះ ផ្ទុយពីប្រទេសដែលមានសិទ្ធិសេរីភាពពេញលេញ ដែលប្រជាពលរដ្ឋមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ប្រជាពលរដ្ឋជាម្ចាស់អំណាច។

### ៥-ច្បាប់ (The Law)

ច្បាប់នៅក្នុងប្រទេសខ្មែរ ជាច្បាប់សំរាប់ការពារអ្នកមានអំណាច អ្នកប្រព្រឹត្តទុច្ចរិត ប្រព្រឹត្តពុករលួយ មិនមែនជាច្បាប់សំរាប់ការពារផលប្រយោជន៍ជាតិ ការពារផលប្រយោជន៍ប្រជាពលរដ្ឋអ្នកទន់ខ្សោយនោះឡើយ។ យើងឃើញហើយថា ជម្ងឺដ៏ធ្ងន់ធ្ងរនៅក្នុងសង្គមខ្មែរសព្វថ្ងៃ គឺអំពើពុករលួយ។ ច្បាប់មិនត្រូវគេអនុវត្តន៍អោយបានត្រឹមត្រូវឡើយ ព្រោះមានការស៊ីសំណូក សូកប៉ាន់ ពុករលួយ និងនិទណ្ឌភាព។ ពួកគេយកតែច្បាប់បែបកុម្មុយនិស្ត យកមកប្រើសំរាប់កៀបសង្កត់អ្នកទន់ខ្សោយ។ ច្បាប់ស្ថិតនៅក្រោមអ្នកមានអំណាច និងបក្សពួករបស់គណបក្សប្រជាជន។ ច្បាប់ទាំងនេះជា ច្បាប់បែបកុម្មុយនិស្ត ព្រោះថាទាំងប្រទេសកុម្មុយនិស្ត និងប្រទេសសេរីមានច្បាប់ដូចគ្នា តែគ្រាន់តែច្បាប់មួយកើតចេញពីបុគ្គលមួយក្រុមតូចសំរាប់ផលប្រយោជន៍មួយក្រុមតូច ដាក់អោយប្រជាពលរដ្ឋទូទៅអនុវត្តន៍ តែសំរាប់ប្រទេសប្រជាធិបតេយ្យសេរីវិញ ច្បាប់កើតចេញពីប្រជាពលរដ្ឋ ពីតំណាងប្រជាពលរដ្ឋ ដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋ និងផលប្រយោជន៍ជាតិ។ ជាក់ស្តែង យើងមើលអំពើអយុត្តិធម៌ដែលកើតមាននៅក្នុងប្រទេសខ្មែរ ពេលដែល ហ៊ុន តូ ត្រូវជាក្មួយរបស់ ហ៊ុន សែន បាញ់គេស្លាប់នៅតាមដងផ្លូវ តែច្បាប់មិនបានចាប់ឧក្រិដ្ឋជនមកផ្តន្ទាទោសឡើយ ព្រោះ ហ៊ុន តូ ជាក្មួយ ហ៊ុន សែន ដែលមានទាំងលុយ និងអំណាច។ អ្នកស្រី ពិសិដ្ឋ ពលីការ ត្រូវ ប៊ុន រ៉ានី ដែលជាប្រពន្ធរបស់ ហ៊ុន សែន បានបញ្ជាអោយគេបាញ់សម្លាប់ តែគ្មាននរណារកឃាតករមកផ្តន្ទាទោសឡើយ រហូតមកដល់ពេលនេះ។

## XII-តើមេដឹកនាំផ្តាច់ការបច្ចុប្បន្នបានធ្វើអ្វីខ្លះ ដែលប៉ះពាល់ប្រជាពលរដ្ឋ
## (What Does Present Dictator Leader Do to Suffer People)

### ១-ការបណ្តេញប្រជាពលរដ្ឋរឹបអូសយកដី ( People Eviction for Grabbing Land)

ការបណ្តេញប្រជាពលរដ្ឋខ្មែរចេញពីកន្លែងមួយទៅកន្លែងមួយ ដើម្បីរឹបអូសយកដី ជាអំពើឧក្រិដ្ឋមួយយ៉ាងធ្ងន់ធ្ងរនៅក្នុងរបបផ្តាច់ការ ហ៊ុន សែន ។ ការរឹបអូសយកដីតាមរូបភាពក្រុមហ៊ុន និងអភិវឌ្ឍន៍នេះធ្វើអោយប្រជាពលរដ្ឋស្រែកទ្រហោយំស្ទើរតែគ្រប់ខេត្តក្រុងនៅក្នុងប្រទេសខ្មែរ។ តាមពិតទៅយួនយករូបភាព

ក្រុមហ៊ុន ជាការបិទបាំង ចំណែកឯពួកអាយ៉ង យកពាក្យថា អភិវឌ្ឍន៍ មកធ្វើជាលេស ដើម្បីបំពេញមហិច្ឆតារបស់យួន ដែលចង់លេបទឹកដីខ្មែរ ដូចកាលដែលយួនបានធ្វើនៅក្នុងទឹកដីខ្មែរកម្ពុជាក្រោមដែរ។ បញ្ហានេះបាននឹងកំពុងកើតឡើងជាបន្តបន្ទាប់នៅក្នុងប្រទេសខ្មែរ។ ពួកអាជ្ញាធរផ្តាច់ការ ហ៊ុន សែន បានប្រគល់ដីសម្បទានអោយក្រុមហ៊ុន យួនមានរយះពេលយ៉ាងតិច ៩៩ឆ្នាំ។ ពួកនេះរឹបអូសយកដីប្រជាពលរដ្ឋ ដែលការរឹបអូសដីនេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពប្រជាពលរដ្ឋខ្មែរសព្វថ្ងៃ។ ដូចក្នុងករណីថ្មីៗនេះ នៅភូមិសំបុកចាប នៅភូមិដីក្រហម សហគមន៍រីករាយ និងនៅតាមបណ្តាខេត្តផ្សេងៗទៀតជាច្រើន។ ចូរយើងនាំគ្នាពិចារណាមើលទៅការផ្តល់សម្បទានដីដែលមានរយៈពេល ៩៩ឆ្នាំ ទៅអោយយួន តើអនាគតទឹកដីខ្មែរអាចក្លាយជាកម្មសិទ្ធរបស់យួនបានឬទេ បើសិនជាជីវិតមធ្យមរបស់ខ្មែររស់បានត្រឹមតែ ៥០ឆ្នាំនោះ។ ចំណែកការបិទសិទ្ធសេរីភាពខ្មែរការបំភ្លៃលុបបំបាត់ប្រវត្តិសាស្ត្រខ្មែរពិតប្រាកដ គេធ្វើកែប្រែជាបន្តបន្ទាប់។ ជាពិសេស នៅពេលឥឡូវនេះជនអន្តោប្រវេសន៍យួនរស់នៅយ៉ាងច្រើនកុះករនៅ លើកទឹកដីខ្មែរសព្វថ្ងៃនេះទៀត ។



*ការរឹបអូសយកដីធ្លីប្រជាពលរដ្ឋក្រោមរូបភាពក្រុមហ៊ុន និង អភិវឌ្ឍន៍*

### ២-អំពើពុករលួយ (Corruption)

អំពើពុករលួយជាជម្ងឺមួយដ៏ធំនៅក្នុងសង្គមខ្មែរ ដែលរដ្ឋាភិបាលបច្ចុប្បន្នគ្មានឆន្ទៈ និងគ្មានសមត្ថភាពដោះស្រាយអោយបានចប់។ អំពើពុករលួយនេះ ជារូបភាពមួយដែលគេបិទបាំង អំពើទុច្ចរិតផ្សេងៗ ដូចជាការលួចជាតិ លក់ទ្រព្យសម្បត្តិជាតិ យកទៅដាក់ផលប្រយោជន៍ផ្ទាល់ខ្លួន ជាពិសេសបង្ហូរផលប្រយោជន៍ទៅអោយប្រទេសដ៏ទៃទៀតបានងាយស្រួល ដោយអំពើពុករលួយ។ ដូច្នេះហើយ យើងឃើញថា ថវិការជាតិបានខាតបង់អស់ ២៥០-៥០០ លានដុល្លា ក្នុងមួយឆ្នាំៗ នេះបើតាមសំដីរបស់លោកស្រី អគ្គរាជទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាឈ្មោះ ខារ៉ូល រ៉ូដលី។ យើងត្រូវពិចារណាអំពីគណបក្សប្រជាជន តើមានប្រាក់ខែប៉ុន្មានដែលពួកវាមានលុយរាប់លាន ដុល្លាទៅដាក់ធានាគារក្រៅប្រទេស តើលុយទាំងអស់នោះមិនមែនជារបស់ជាតិខ្មែរ ឬលុយបានមកពីពុករលួយ លួចជាតិ? តើទ្រព្យសម្បត្តិទាំងអស់នោះ មិនមែនជាសម្បត្តិរបស់ជាតិខ្មែរ យើងទាំងអស់គ្នាទេឬ? អំពើពុករលួយនេះ រីករាលដាលយ៉ាងខ្លាំងនៅក្នុងសង្គមខ្មែរ នៅក្នុងប្រព័ន្ធអប់រំ នៅក្នុងប្រព័ន្ធតុលាការ និងតុលាការ ខ្មែរក្រហម ផងដែរ។

## ៣-ភាពក្រីក្រ (Poverty)

ប្រជាពលរដ្ឋខ្មែរចំនួន ៤០ ភាគរយ ស្ថិតនៅក្រោមបន្ទាត់ក្រីក្រ។ និស្សិតជាច្រើន ដែលបញ្ចប់ការសិក្សា ហើយគ្មានការងារធ្វើ។ កម្មករប្រាក់ខែតិចមិនគ្រប់គ្រាន់ក្នុងការចំណាយសំរាប់ជីវភាពប្រចាំថ្ងៃ។ ពួកគេធ្វើការគ្រាន់តែបំរើនាយទុនរោងចក្រតែប៉ុណ្ណោះ។ គ្រូបង្រៀនប្រាក់ខែទាបដដែល តែទំនិញនៅលើទីផ្សារ កើនឡើងជាលំដាប់ ជាពិសេស សាំង ដែលធ្វើអោយប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋយ៉ាងខ្លាំង ព្រោះកាលទំនិញឡើងថ្លៃ ប្រាក់ខែដដែលធ្វើអោយចំណាយច្រើនជាងចំណូល ប្រាក់សន្សំទាប (ក្រីក្រ)។ ប្រជាពលរដ្ឋខ្មែរចំនួន ៨៥ ភាគរយ ជាកសិករប្រកបមុខរបរកសិកម្ម។ មុខរបរចិញ្ចឹមជីវិតពួកគាត់អាស្រ័យលើដីស្រែ ដីចំការ ដើម្បីចិញ្ចឹមជីវិត តែឥឡូវនេះ ដីស្រែដីចំការរបស់គាត់មួយចំនួន ត្រូវបានយួនដែលក្លែងភេទជាខ្មែរ និងបក្សពួក ហ៊ុន សែន ប្រើប្រាស់ជារូបភាពក្រុមហ៊ុនដណ្តើមដីស្រែដីចំការរបស់គាត់អស់ តើអនាគតវាសនាកូនចៅគាត់ដែលជាខ្មែរទៅជាយ៉ាងណា? កូនចៅក្រីក្រ មិនបានរៀនសូត្រ ហើយអស់ដីស្រែដីចំការទៀត។ តាមសម្បត្តិធនធានរបស់ខ្មែរ ដែលមានដូចជាចំណូលបានពីទេសចរណ៍ ប្រាសាទអង្គរវត្ត រ៉ែមាស ពេជ្រត្បូង ព្រៃឈើ ជាដើម ធៀបទៅនិង ប្រជាពលរដ្ឋខ្មែរប្រមាណជាង ១០ លាននាក់នោះ ប្រជាពលរដ្ឋខ្មែរមិនគួរក្រីក្រដើរសុំទានគេនោះឡើយ។ តើធនធានទាំងអស់នោះ ធ្លាក់ទៅដល់ដៃអ្នកណា? ទ្រព្យសម្បត្តិរបស់ខ្មែរ ផលប្រយោជន៍ខ្មែរ ត្រូវធ្លាក់លើ ពួកជនពុករលួយគណបក្សប្រជាជនកម្ពុជានេះឯង ដែលគេងប្រវ័ញ្ចយកទៅដាក់ផលប្រយោជន៍ផ្ទាល់ខ្លួន។ យួន រឹបអូសយកទៅបំរើផលប្រយោជន៍ជាតិ និងប្រទេសរបស់គេ។



*តើអនាគតកូនខ្មែរទៅជាយ៉ាងណា?*

## ៤-កាត់ទោសខ្មែរក្រហម (Khmer Rouge Trial)

មេដឹកនាំខ្មែរក្រហមគឺ សីហនុ ដែលបានប្រកាសអោយខ្មែរចូលព្រៃម៉ាគីរួមជាមួយ ហ៊ុន សែន ដែលបានចូលធ្វើជាខ្មែរក្រហមតាំងពី សី ហនុ ធ្វើជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា បង្កើតឡើងនៅក្រុងប៉េកាំង ថ្ងៃ២៣ មីនា ១៩៧០។ សូមសាលាក្តីខ្មែរក្រហមកាត់ទោស សីហនុ និងហ៊ុន សែន ផង។ បើសិនជាមិនបាន កាត់ទោស សី ហនុ ផងទេ វាជាការលាក់បាំងកំហុសមេដឹកនាំខ្មែរក្រហមដ៏សំខាន់ម្នាក់ ព្រោះដោយសារ សី ហនុ នេះហើយដែលធ្វើអោយកម្លាំងខ្មែរក្រហម និងទ័ពយៀកកុងអាចយកជ័យជំនះលើខ្មែរសាធារណៈរដ្ឋ វារឹតតែធ្វើ អោយខ្មែរកាន់តែវង្វេងជ្រៅទៅមិនអាចរកឃាតករពិតប្រាកដឃើញទៀតផង។ ប៉ុន្តែ យើងជាជនរងគ្រោះខ្មែរ

គ្រប់គ្នាដឹងច្បាស់ថាឃាតករពិតប្រាកដ គឺពួកកុម្មុយនិស្តយួន (ឥណ្ឌូចិន) ដែលបានរៀបចំ និងបំពាក់បំប៉នលទ្ធិកុម្មុយនិស្តអោយខ្មែរ (ក្រហម) ដែលរត់ចូលព្រៃម៉ាគីតាមការអំពាវនាវរបស់ សីហនុ និង ខ្មែរ (ក្រហម) ដែលគាំទ្រ ប៉ុល ពត អោយសម្លាប់ខ្មែរ រួចហើយរៀបចំផែន សម្លាប់ជាបន្តបន្ទាប់ ដើម្បីបំបាត់បំបាត់ដាន និងសាក្សី។ ពេលដែលយួនកុម្មុយនិស្តឈ្នះ លើកអំណាចអោយខ្មែរកុម្មុយនិស្ត ធ្វើអោយប្រជាពលរដ្ឋខ្មែរស្លាប់រាប់លាននាក់ ទាំងខ្មែរក្រោម និងខ្មែរបច្ចុប្បន្ន ហើយយួនបញ្ជូនពលរដ្ឋខ្លួនមកជំនួស ធ្វើជាខ្មែរថ្មីលើទឹកដីខ្មែរវិញ។ សី ហនុ និង ហ៊ុន សែន ជាជនកុម្មុយនិស្ត បំរើនយោបាយអោយយួនកុម្មុយនិស្ត ដើម្បីអំណាច និងផលប្រយោជន៏ផ្ទាល់ខ្លួនឯង និងបក្សពួកតែប៉ុណ្ណោះ ដោយជនកុម្មុយនិស្តទាំងនេះ មិនបានបំរើផលប្រយោជន៏អោយជាតិខ្មែរ និងប្រជាពលរដ្ឋខ្មែរទេ។ ប្រជាពលរដ្ឋខ្មែរកំពុងរងចាំយុត្តិធមិពិតប្រាកដពីសាលាក្តីនេះ។ យួនមិនចង់អោយខ្មែរដឹងការពិត ចំណែក ហ៊ុន សែន ក៏មិនចង់រកយុត្តិធមិអោយជនរងគ្រោះខ្មែរពិតប្រាកដទេ ព្រោះខ្លាចបាត់បង់អំណាច។ ជាក់ស្តែងថ្មីៗនេះ ហ៊ុន សែន បាននិយាយថាសុខចិត្តអោយសាលាក្តីនេះបរាជ័យ បើសិនជានាំអ្នកពាក់ព័ន្ធបន្ថែមទៀតមកកាត់ទោស។ ការបង្កើតសាលាក្តីនេះចំណេញទៅកុម្មុយនិស្តយួនភាគច្រើន ( ១-ខ្មែរនៅតែបែកបាក់គ្នាឈឺចាប់និងខ្មែរ (ក្រហម) ប៉ុល ពត ២-ដឹងគុណយួន ៧ មករា ៣-ប្រជាពលរដ្ឋខ្មែរនៅតែមិនដឹងការពិតថានរណាជាឃាតករពិតប្រាកដ ៤-បើកឱកាសអោយយួនកុម្មុយនិស្ត ត្រួតត្រាខ្មែរលេបទឹកដីខ្មែរបន្ត )។

ថ្ងៃ ១៧ មេសា ១៩៧៥ គឺពួកកុម្មុយនិស្ត ដែលយួនលើកអំណាចអោយខ្មែរ (ក្រហម) ដូចគ្នានិង ថ្ងៃ ៧ មករា ១៩៧៩ ដែលពួកកុម្មុយនិស្តយួនឈ្លានពានលើកបន្តុបអំណាចខ្មែរ (ក្រហម) ហ៊ុន សែន ជា ស៊ីម និង ហេង សំរិន ដែរ ចំណែកឯ សី ហនុ ដែលធ្លាប់ធ្វើជាមេខ្មែរក្រហម បង្កើតខ្មែរក្រហម (កុម្មុយនិស្ត) ក៏មិនហ៊ានចេញមកសារភាពទទួលកំហុសទៀត។

អង្គការសហប្រជាជាតិដែលចង់រកយុត្តិធមិអោយប្រជាពលរដ្ឋខ្មែរ និងចង់បំបាត់និទណ្ឌភាពបានចំណាយលុយជាច្រើនមកអោយពួកជនពុករលួយ។ ដើម្បីយុត្តិធមិសំរាប់ជនរងគ្រោះខ្មែរ សូមអោយអង្គការសហប្រជាជាតិ បញ្ចេញអោយអស់សមត្ថភាព ដើម្បីសំរេចនូវកិច្ចការជាប្រវត្តិសាស្ត្រនេះ។



*បើចង់រកយុត្តិធមិអោយខ្មែរ ត្រូវកាត់ទោស ប៉ុល ពត សីហនុ ហ៊ុន សែន និងយួន ដែរ*

## ៥-អាណានិគមន៍បែបថ្មីតាមរូបភាពក្រុមហ៊ុន និងការផ្តល់ដីសម្បទាន

(The Neo-Colonism through the Picture of Company and Land Concession)

យួនបានប្តូរពីរូបភាពអាណានិគមន៍ដោយផ្ទាល់ ដូចកាលពីឆ្នាំ ១៩៧៩ មកប្រើអាណានិគមន៍បែបថ្មីវិញ ដោយយួនបានក្លែងភេទជាខ្មែរ ដើម្បីគ្រប់គ្រងខ្មែរ។ យួនបានប្រើប្រាស់ក្រុមហ៊ុនជាការបំភ័ន្តខ្មែរ បិទបាំងមិនអោយខ្មែរមើលឃើញ ថាខ្មែរនៅក្រោមការត្រួតត្រារបស់កុម្មុយនិស្តយួន។ក្រុមហ៊ុនទាំងនោះ ភាគច្រើនជាក្រុមហ៊ុន វៀតណាម ដែលយកទាហានមកធ្វើជាកម្មករ ត្រួតត្រាមើលសភាពការណ៍នៅក្នុងប្រទេសខ្មែរ។ តាមរយះពាក្យថាអភិវឌ្ឍន៍ និង ច្បាប់សម្បទាន យួនបានដណ្តើមដីប្រជាពលរដ្ឋ ដែលធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ និងជីវភាពប្រជាពលរដ្ឋយ៉ាងខ្លាំង។ ប្រជាពលរដ្ឋរងទុក្ខវេទនា ឥតល្ហែ ឈឺចាប់មិនចេះចប់ អំពីការរឹបអូសដីធ្លី ពីអ្នកកាន់អំណាច ដោយគ្មាននរណាជួយរកយុត្តិធម៌អោយបានសមរម្យឡើយ។ ជាពិសេសពេលថ្មីៗនេះ ក្រុមហ៊ុន ៧ អែនជី ដែលបានដណ្តើមដីប្រជាពលរដ្ឋ និងក្រុមហ៊ុននៅខេត្តកំពង់ស្ពឺ នៅភ្នំស្រួច បានបាញ់គោប្រជាពលរដ្ឋ ហើយរឹបអូសយកដីប្រជាពលរដ្ឋជាដើម។

ការដែលយួនប្រើរូបភាពអាណានិគមន៍បែបថ្មីនេះ ដើម្បីកុំអោយប្រជាពលរដ្ឋខ្មែរមើលឃើញ និងដឹងអំពីមហិច្ឆតារបស់យួន។ បើសិនជាខ្មែរយើងដឹង ខ្មែរយើងមើលឃើញ អាចនាំអោយប្រជាពលរដ្ឋខ្មែរ ងើបឡើងប្រឆាំងជាមួយយួន ដូចកាលសម័យមេទ័ព ឡើង មិញយ៉ាង ចូលមកត្រួតត្រាខ្មែរ។ ហេតុដូចនេះហើយ ការផ្តល់ដីសម្បទានអោយ ក្រុមហ៊ុនយួន ដែលមានរយ:ពេល ៩៩ ឆ្នាំ នេះ បានបង្ហាញអោយឃើញថា ក្នុងពេលអនាគតដ៏ខ្លីខាងមុខ ប្រទេសជាតិខ្មែរអាចនឹងធ្លាក់ក្នុងកណ្តាប់ដៃយួន ដែលក្លែងភេទធ្វើជាខ្មែរទាំងស្រុងមិនខានឡើយ។ ប្រជាពលរដ្ឋខ្មែរពិតប្រាកដ រស់នៅជាជនជាតិភាគតិចរបស់យួន នៅលើទឹកដីខ្លួនឯងដូចចាម និង ខ្មែរកម្ពុជាក្រោម។

## ៦-ធនធានធម្មជាតិ (The Natural Resource)

ធនធានធម្មជាតិរបស់ខ្មែរ មានចាប់តាំងពីព្រៃឈើ ត្រីសាច់ សត្វព្រៃ រ៉ែ ត្រូវបំផ្លាញដោយពួកជនពុករលួយ ឃុបឃិតគ្នាលួចជាតិយកមកដាក់ផលប្រយោជន៍បុគ្គល លក់ជាតិយកមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ហេតុដូច្នេះហើយ បើយើងធៀបធនធានខ្មែរទៅនិងប្រជាពលរដ្ឋខ្មែរដែលមានចំនួនតែប្រមាណជាង ១០លាននោះ ប្រជាពលរដ្ឋខ្មែរ មិនគួរក្រីក្រ ដើរសុំទានគេ រត់ចេញពីប្រទេសខ្មែរទៅធ្វើការនៅប្រទេសគេនោះឡើយ។ ព្រោះគេធ្វើអោយមើលឃើញថា ប្រទេសខ្មែរគ្មានតំលៃអ្វីទាំងអស់ និងពិបាកក្នុងការរស់នៅ ដោយសារជីវភាព និងគ្មានការងារធ្វើជាដើម។ នយោបាយរបស់យួនកុម្មុយនិស្ត ធ្វើការកៀបសង្កត់ខ្មែរគ្រប់បែបយ៉ាង ដោយមិនអោយខ្មែរមើលឃើញអំពីតំលៃនៃជាតិរបស់ខ្លួនឯង ស្វែងរកដើម្បីរស់ប៉ុណ្ណោះ។ យួនបានប្រើក្រុមហ៊ុនអោយដឹកជញ្ជូនឈើ រ៉ែគ្រប់បែបយ៉ាងទៅប្រទេសគេ។ ក្រុមហ៊ុនយួន និងចិន ធ្វើគ្រប់បែបយ៉ាងអោយខ្មែរហិនហោចធនធានសម្បត្តិធម្មជាតិទាំងអស់នោះ។ ជាក់ស្តែង យើងឃើញភ្នំមួយចំនួនត្រូវបានគេឈូសឆាយធ្វើអោយខូចទ្រង់ទ្រាយ ធម្មជាតិអស់ដូចជានៅតំបន់អូក្លរ មណ្ឌលគីរី ដែលមានក្រុមហ៊ុនចិនទៅជីកមាស នៅភ្នំដី

ស្រុករវៀង នៅទីនោះក្នុងមួយខែរាប់តោនមាស តែបើសិនជា ប្រជាពលរដ្ឋខ្មែរវិញពួកវាមិនអនុញ្ញាតអោយជីកទេ ពេលដែលខ្មែររកឃើញកន្លែងមាន មាស ចិន និងយួនវាដណ្តើមខ្មែរ ដោយមិនអនុញ្ញាតអោយខ្មែរជីកឡើយ ។




*ធនធានខ្មែរ ក្នុងទឹក លើដី ក្រោម និងក្នុងដី ត្រូវពួកជនពុករលួយលក់ជាតិទាំងបី បំផ្លាញ*

# ជំពូកទី ២

# បញ្ចប់បញ្ហា (End Problems)

## I.តើប្រជាពលរដ្ឋខ្មែរចង់បានអ្វី? (What Does Cambodian People Want?)

ប្រជាពលរដ្ឋខ្មែរទាំងអស់ដែលរស់នៅក្នុងប្រទេសខ្មែរបច្ចុប្បន្ន គ្មានសិទ្ធិសេរីភាពពេញលេញទេ ភាគច្រើនជួបប្រទះភាពក្រីក្រ អយុត្តិធម៌ និងការរំលោភជិះជាន់ពីអ្នកកាន់អំណាចសព្វថ្ងៃ។ ប្រជាពលរដ្ឋខ្មែរចង់អោយប្រទេសជាតិមាន ឥស្សរភាព ឯករាជ្យ មិនព្រមរស់នៅក្រោមអាណានិគមន៏នៃប្រទេសណាមួយ ជាពិសេសអាណានិគមន៏នៃប្រទេសវៀតណាមសព្វថ្ងៃ។ ប្រជាពលរដ្ឋចង់បានប្រជាធិបតេយ្យ សន្តិភាពពិតប្រាកដ រួចផុតពីភាពក្រីក្រ និងអំពើពុករលួយជាដើម។ ដើម្បីសំរេចនូវគោលដៅនេះ ប្រជាជាតិខ្មែរទាំងអស់ពីគ្រប់ស្រទាប់ក្នុងសង្គម ទោះនៅទីណាក៏ដោយត្រូវរួបរួម សាមគ្គីគ្នា ដោះស្រាយបញ្ហាទាំងអស់នេះអោយចប់។ ប្រជាពលរដ្ឋខ្មែរនឿយណាយ និងឈប់ចង់រស់នៅក្រោមការគៀបសង្កត់ បិទសិទ្ធិរបស់ពួកត្រួតត្រាកុម្មុយនិស្តដដែល១ទៀតហើយ ព្រោះថាអស់រយៈពេលជាង ២ ទសវត្សកន្លងមកនេះ ប្រជាពលរដ្ឋមានការលំបាក ដោយសារការគៀបសង្កត់ជិះជាន់ និងការធ្វើទុក្ខបុកម្នេញ។ ហេតុដូច្នេះហើយ ពេលដែលមានការរៀបចំបោះឆ្នោត ដែលរៀបចំ និងត្រួតពិនិត្យដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ ប្រជាពលរដ្ឋខ្មែរបានធ្វើការសំរេចចិត្ត បោះឆ្នោតជ្រើសរើសមេដឹកនាំថ្មី និងផ្លាស់ប្តូររបបគ្រប់គ្រង។ តែគួរអោយសោកស្តាយ អ្វីដែលប្រជាពលរដ្ឋខ្មែរចង់បានចេញពីឆន្ទៈ ត្រូវបាត់បង់ទៅវិញ ដោយសារស្តេចសីហនុ ប្រគល់អំណាចអោយពួកកុម្មុយនិស្ត ហ៊ុន សែន ដែលជាអាយ៉ងយួនវិញ។ ចំណែកឯអង្គការសហប្រជាជាតិ មិនទាន់បំពេញតួរនាទីចប់ផង សី ហនុ បានដេញអង្គការសហប្រជាជាតិចេញពីស្រុកខ្មែរ ហើយគណបក្សប្រជាជន ហ៊ុន សែន បានធ្វើរដ្ឋប្រហារប្លន់អំណាច សម្លាប់អ្នកស្នេហាជាតិ សម្លាប់អ្នកប្រជាធិបតេយ្យនៅថ្ងៃទី ៥-៦ កក្កដា ១៩៩៧។ ចំណែកឯការបោះឆ្នោតក្រោយ១មកជាបន្តបន្ទាប់ វាជាការរៀបចំឡើងដោយគណបក្សប្រជាជន ដើម្បីបំភ័ន្តភ្នែកប្រជាពលរដ្ឋខ្មែរ និងបំភ័ន្តមតិអន្តរជាតិ តែលទ្ធផលបោះឆ្នោតទាំងអស់នោះ មិនមែនចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរពិតប្រាកដទេ។

## II.តើខ្មែរធ្វើយ៉ាងណាដើម្បីជួយសង្គ្រោះខ្មែរ ?(How can Khmer help Khmer?)

គ្មាននរណាស្រឡាញ់ខ្មែរជាជាងជាតិខ្មែរខ្លួនឯងនោះទេ ហើយក៏គ្មាននរណាអាចជួយខ្មែរ ក្រៅពីខ្មែរខ្លួនឯងដែរ នេះបើតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធដែលជាព្រះបរមគ្រូបានទូន្មានប្រៀនប្រដៅមកថា *ខ្លួនទីពឹងខ្លួន* ។ នៅពេលដែលជាតិយើងកំពុងតែមានបញ្ហា យើងជាខ្មែរម្នាក់១ មិនត្រូវបណ្តែតបណ្តោយទុកអោយជាតិយើងនៅតែមានបញ្ហាបែបនេះឡើយ យើងទាំងអស់គ្នាត្រូវរួបរួមគ្នាដោះស្រាយបញ្ហាទាំងអស់នេះអោយចប់។ តែយើងមិនត្រូវនាំគ្នាដោះស្រាយចុងបញ្ហានោះឡើយ យើងត្រូវដោះស្រាយឫសគល់បញ្ហា ទើបបញ្ហាទាំងអស់នោះចប់។ យើងម្នាក់១ ក៏មិនត្រូវមានមោទភាពថា មានតែអត្មាអញខ្លាំងអាចធ្វើអ្វីកើត ឬអួតខ្លួនយកមុខមាត់ កេរ្តិ៍ឈ្មោះបុណ្យស័ក្តនោះក៏ទេ កត្តាសំខាន់គឺថា គំនិតច្រើន ប្រសើរជាងគំនិតមួយ យើងជាខ្មែរទាំងអស់ត្រូវអោនលំទោនអោយតំលៃគ្នាទៅវិញទៅមក រួបរួមគ្នា គិត និយាយ ធ្វើ ដើម្បីអោយសំរេចគោលដៅរួមតែមួយ គឺដើម្បី ជាតិ សាសនា និង ប្រជាជាតិខ្មែរពិត១។ កាលណាយើងធ្វើអ្វីមួយព្រមគ្នា ស្រុះគ្នា ក្នុងយុទ្ធសាស្ត្ររួម តែមួយនោះ

ប្រៀបបានដូចជាទឹកដែលហូរចូលក្នុងសមុទ្រតែមួយយ៉ាងដូច្នោះដែរ តើនណាមួយមិនខ្លាច ទឹកសមុទ្រ។ យើងត្រូវរួបរួមគ្នាដោះស្រាយដើមបញ្ហាក្រោមយុទ្ធសាស្រ្តរួមតែមួយ ទើបបញ្ហានោះចប់ ។ ហេតុដូច្នេះហើយ ខ្មែរគ្រប់រូបត្រូវភ្ញាក់រលឹកពីគ្រប់ទីសទីគ្រប់មជ្ឈដ្ឋាន រួបរួមសាមគ្គីជាធ្លុងមួយ ប្តេជ្ញាចិត្ត ទាំងអស់គ្នា ដើម្បីរំដោះ ការពារ ជាតិ សាសនា ប្រជាជាតិខ្មែរ អោយរួចផុតពីទុក្ខវេទនា ដែលរស់នៅគ្មានសិទ្ធិសេរីភាព ក្រោមរបបកុម្មុយនិស្តផ្តាច់ការ ហ៊ុន សែន ដែលមានយួនត្រួតត្រាធ្វើអាណានិគមនីបែបថ្មីនេះ ដោយយើងឈប់ប្រើវិធីបោះឆ្នោត ដែលគ្មានសេរី និងយុត្តិធម៌។

## III. តើប្រជាពលរដ្ឋក្នុងតំបន់ដែលរងគ្រោះ ឡាវ ម៉ុង ចាម ខ្មែរត្រូវធ្វើដូចម្តេច?
(What do the People in the Region Lao, Hmong, Cham and Khmer do?)

យើងជាប្រជាពលរដ្ឋរងគ្រោះ ដោយសារយួនកុម្មុយនិស្តទាំងអស់នៅក្នុងតំបន់ឥណ្ឌូចិន មានដូចជា ប្រជាពលរដ្ឋ ឡាវ ម៉ុង ចាម ខ្មែរ ត្រូវតែដឹងថា សិទ្ធិសេរីភាព ប្រជាធិបតេយ្យ ឯករាជ្យ អធិបតេយ្យភាព សំរាប់យើងទាំងអស់គ្នាជាកត្តាសំខាន់ ក្នុងនាមជាមនុស្ស។ យើងមិនព្រមសុខចិត្តរស់នៅដោយគ្មានសិទ្ធិសេរីភាព ក្រោមការត្រួតត្រារបស់ប្រទេសណាមួយឡើយ។ ***យើងរស់នៅជាប្រជាពលរដ្ឋសាមញ្ញ ដែលមានសិទ្ធិសេរីភាព ឯករាជ្យ ប្រជាធិបតេយ្យ ពេញលេញពិតប្រាកដ ប្រសើរជាងការរស់នៅធ្វើជាស្តេចមន្ត្រីក្រោមអាណានិគមន៍បរទេស។*** ប្រជាពលរដ្ឋទាំងអស់ដូចជា ឡាវ ម៉ុង ចាម ខ្មែរ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់យួនកុម្មុយនិស្ត ត្រូវតែមានការភ្ញាក់រលឹក នាំគ្នារួបរួមគ្នាក្រោកឡើង ដើម្បីសិទ្ធិសេរីភាព ឥស្សរភាព ឯករាជ្យរបស់ជាតិខ្លួនទីមួយៗ។ យើងមិនបណ្តោយអោយប្រទេសរបស់យើងទីមួយៗស្ថិតនៅក្រោមការត្រួតត្រារបស់យួនកុម្មុយនិស្ត បិទសិទ្ធិសេរីភាពជារៀងរហូត ដល់យើងបាត់ឈ្មោះនៅក្នុងពិភពលោកនោះឡើយ។ នៅពេលដែលអស់លោកអ្នកមានសៀវភៅនេះអាននៅក្នុងដៃហើយ ត្រូវតែមានការភ្ញាក់រលឹក នាំគ្នាក្រោកឡើងតាមយុទ្ធសាស្រ្តរបស់មេដឹកនាំ និងអនុវត្តន៏ភាពជាមេដឹកនាំ ដើម្បីឈានទៅរកជោគជ័យ ដោយមិនព្រមសុខចិត្តរស់នៅដោយគ្មានសិទ្ធិសេរីភាព បាត់បង់អត្តសញ្ញាណជាជាតិមួយ ដែលរស់នៅស្មើមុខគេនៅលើពិភពលោកឡើយ។ យើងទាំងអស់គ្នាត្រូវតែនាំគ្នាងើបឡើង ដើម្បីឯករាជ្យជាតិ ឥស្សរភាពរបស់យើង។

## IV. តើសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ជួយអ្វីខ្លះដល់ប្រជាជាតិរងគ្រោះ?
(What Does EU and US help Cambodian Victims?)

សហគមន៍អន្តរជាតិ និងសហរដ្ឋអាមេរិក ដែលជាប្រទេសមហាអំណាច តែងតែស្វែងរកយុត្តិធម៌អោយប្រជាជាតិដែលរងគ្រោះ ក្រោមការគៀបសង្កត់បិទសិទ្ធិសេរីភាព។ តែកត្តាសំខាន់ប្រជាជាតិនីមួយៗត្រូវមានការខិតខំប្រឹងប្រែងខ្លួនឯងជាមុន ដោយមិនបណ្តែតបណ្តោយតាមព្រេងវាសនា ឬក៏ថាចាំតែពឹងលើអ្នកដទៃនោះឡើយ។ កត្តាដែលនាំអោយយើងជោគជ័យនោះ គឺអាស្រ័យលើខ្លួនយើងជាកត្តាចំបង ហើយចំណែកប្រទេសប្រជាធិបតេយ្យគេមើលឃើញអំពើអយុត្តិធម៌ គ្មានសិទ្ធិសេរីភាព គេនឹងជួយលើកទឹកចិត្ត និងជួយរកវិធីដោះស្រាយបន្ថែមលើការខិតខំប្រឹងប្រែងរបស់យើង។ ដើម្បីស្វែងរកយុត្តិធម៌ជូនដល់ប្រជាជាតិនៅក្នុងតំបន់ទាំងនេះ

អោយរួចផុតពីការបិទសិទ្ធិសេរីភាព ទទួលបាននូវសិទ្ធិសេរីភាពពេញលេញ និងប្រជាធិបតេយ្យតាមអ្វីដែលប្រជាជាតិនៅក្នុងតំបន់នេះចង់បាន ។

## V. ប្រទេសខ្មែរត្រូវដឹកនាំតាមគោលការណ៍ប្រជាធិបតេយ្យពិតប្រាកដ
(Cambodia Must Lead Country Through the Real Principle of Democracy)

ប្រទេសខ្មែរត្រូវមាននយោបាយមួយដែលមាន ឥស្សរភាព ឯករាជ្យ និងប្រជាធិបតេយ្យពិតប្រាកដតាមប្រជាជាតិខ្មែរចង់បាន ដោយមិនស្ថិតនៅក្រោមឥទ្ធិពលរបស់ប្រទេសណាមួយឡើយ ។ ប្រទេសទាំងអស់ដែលនៅជិតខាង ត្រូវគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក ដោយស្មើភាពចំពោះមុខច្បាប់អន្តរជាតិ ។ ហេតុនេះដើម្បីអោយស្របទៅនិងដំណើរការដឹកនាំរបស់ពិភពលោក ដែលផ្តល់សិទ្ធិសេរីភាពពេញលេញចំពោះប្រជាពលរដ្ឋ ប្រទេសខ្មែរត្រូវដឹកនាំតាមរបៀបប្រជាធិបតេយ្យពិតប្រាកដ ។ ការពារថែរក្សាផលប្រយោជន៍ជាតិ និងអភិវឌ្ឍន៍ជាតិអោយរីកចំរើនទៅមុខ ដោយការចូលរួមពីប្រជាពលរដ្ឋជាការចាំបាច់ សំរាប់មេដឹកនាំ និងអ្នកស្នេហាជាតិខ្មែរ ។ យើងត្រូវលើកតំកើងព្រះពុទ្ធសាសនា អោយតំលៃលើព្រះសង្ឃ និងគម្ពីរក្បួនខ្នាតរបស់ព្រះសម្មាសម្ពុទ្ធ ហើយ បើកសេរីភាពដល់សាសនាផ្សេងៗទៀត ។ ការរៀបចំសន្តិសុខសង្គម ជាកត្តាចាំបាច់សំរាប់ការរស់នៅរបស់ប្រជាពលរដ្ឋ និងទំនុកទុកចិត្តពីបរទេស អ្នកវិនិយោគទុនផ្សេងៗ ដែលជាជំហានឈានទៅរកការបង្កើនការងារសំរាប់ប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ច ។ ការលុបបំបាត់អំពើពុករលួយ អយុត្តិធម៌នៅក្នុងសង្គម ដោយការបង្កើតច្បាប់ និងអនុវត្តអោយម៉ឺងម៉ាត់បំផុត ជាកត្តាសំខាន់បំផុតសំរាប់សង្គមខ្មែរ ដើម្បីអោយមានសេចក្តីថ្លៃថ្នូរស្អាតស្អំ ដោយគិតផលប្រយោជន៍ជាតិជាធំ ។ ការលើកតំលៃបុគ្គលដែលធ្វើប្រយោជន៍អោយជាតិ បុគ្គលដែលធ្វើល្អក្នុងសង្គម អ្នកស្នេហាជាតិ រៀបចំប្រព័ន្ធអប់រំអោយមានគុណភាព និងគោលដៅច្បាស់លាស់ បែងចែកប្រាក់ចំណូលអោយមានលក្ខណ:ប្រហាក់ប្រហែលគ្នា ដើម្បីចៀសវៀងអ្នកមានកាន់តែមាន ចំណែកអ្នកក្រកាន់តែក្រ ដោយការផ្តល់ប្រាក់បៀវត្ស អោយសមតាមជីវភាពរស់នៅ ពោលគឺរកទីផ្សារជូនប្រជាពលរដ្ឋ ។ ក៏រិតប្រាក់ចំណូលអោយបានច្រើនជាងប្រាក់ចំណាយ ទើបប្រជាពលរដ្ឋមានជីវភាពធូរធារ ជាពិសេស គឺលើកទឹកចិត្តខ្លាំងចំពោះអ្នកដែលក្រីក្រ អ្នកទន់ខ្សោយ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវបានលើកទឹកចិត្តអោយមានការអប់រំខ្ពស់មានគុណភាពដូចគ្នា និងសិទ្ធិសេរីភាពស្មើគ្នាចំពោះមុខច្បាប់ ។

ជាបឋមយើងត្រូវពង្រឹងកងកម្លាំងប្រដាប់អាវុធ នគរបាលអោយមានសមត្ថភាព មានសីលធម៌ល្អដើម្បីធានាសន្តិសុខ ការពារផលប្រយោជន៍ប្រទេសជាតិ ចៀសវាងការរំលោភឈ្លានពានពីសំណាក់ ប្រទេសជិតខាង ។ កងកម្លាំងប្រដាប់អាវុធនៅជាកម្លាំងអព្យាក្រិត្យ ដោយមិនស្ថិតនៅក្រោមគណបក្សនយោបាយណាមួយ ឬប្រកាន់និន្នាការនយោបាយគណបក្សជាដើម ។ កងកម្លាំងប្រដាប់អាវុធធ្វើតាមតួរនាទីជាអ្នកការពារ បំរើជាតិ សាសនា ប្រជាជាតិខ្មែរ ដោយស្មោះអស់ពីដួងចិត្ត ។

ចំណែកឯមន្ត្រីរាជការត្រូវគោរពច្បាប់ជាមូលដ្ឋាន ។ ច្បាប់អនុវត្តន៍ចំពោះជនទូទៅមិនរើសមុខ ប្រជាជាតិខ្មែរទាំងអស់ត្រូវស្មើភាពគ្នាចំពោះមុខច្បាប់ ពង្រឹងការអនុវត្តច្បាប់ ។ គ្មាននរណាម្នាក់នៅលើច្បាប់បានឡើយ បំបាត់អំពើពុករលួយនៅគ្រប់មជ្ឈដ្ឋានទាំងអស់នៅក្នុងគ្រប់មជ្ឈដ្ឋានទាំងអស់ ។ កម្លាំងទាំងអស់ត្រូវមានសីលធមិ

សមរម្យ មានយុត្តិធម៌ មិនប្រព្រឹត្តអំពើពុករលួយ ហើយត្រូវលើកទឹកចិត្តជានិច្ច ដើម្បីការពារផលប្រយោជន៍ជាតិ ។

**១-និតិបញ្ញត្តិ** (Legislative)

អង្គនិតិបញ្ញត្តិជាអ្នកតំណាងអោយប្រជាជាតិខ្មែរ តំណាងអោយប្រជាពលរដ្ឋ មិនស្ថិតនៅក្រោមអំណាចបុគ្គលណាម្នាក់ ឬគណបក្សនយោបាយណាមួយ ។ អង្គនិតិបញ្ញត្តិជាអង្គការកំពូលរបស់ជាតិ ។ តំណាងរាស្ត្រត្រូវយកចិត្តទុកដាក់អំពីសុខទុក្ខរបស់ប្រជាពលរដ្ឋជាទូទៅ ដោយតាំងខ្លួនជាតំណាងអោយផលប្រយោជន៍របស់ប្រជាពលរដ្ឋ តំណាងអោយផលប្រយោជន៍ជាតិ ហើយនៅក្នុងស្ថាប័ននេះត្រូវនៅជាឯករាជ្យ ដាច់ដោយឡែកពីអំណាចនិតិប្រតិបត្តិ សំរាប់ត្រួតពិនិត្យមើលការអនុវត្តរបស់និតិប្រតិបត្តិ ។

**២-តុលាការ** (The Court)

តុលាការមានតួនាទីសំខាន់ សំរាប់ស្វែងរកយុត្តិធម៌អោយប្រជាពលរដ្ឋរងគ្រោះនៅក្នុងសង្គម តុលាការត្រូវតែឯករាជ្យ ដោយមិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយ ឬស្ថិតនៅក្រោមគណបក្សនយោបាយណាមួយជាពិសេស អំណាចតុលាការនេះត្រូវស្ថិតនៅដាច់ដោយឡែកពីអំណាចនិតិបញ្ញត្តិ និងអំណាចនិតិប្រតិបត្តិ ។ ដើម្បីអោយមានយុត្តិធម៌នោះ ការពង្រឹងផ្នែកអនុវត្តន៍ច្បាប់ជាកត្តាសំខាន់ និងសីលធម៌សង្គម ធ្វើយ៉ាងណាត្រូវបំបាត់អំពើពុករលួយ ។ តុលាការត្រូវមានសុឆន្ទៈឯករាជ្យ ក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជាតិខ្មែរទូទៅ ។

**៣-អំណាចនិតិប្រតិបត្តិ** (The Executive)

អំណាចនិតិប្រតិបត្តិមានតួនាទីសំខាន់ណាស់ សំរាប់ធ្វើអោយប្រទេសជាតិមួយរីកចំរើនរុងរឿង ។ រដ្ឋាភិបាលត្រូវតែមានឆន្ទៈនយោបាយពិតប្រាកដ គោលនយោបាយច្បាស់លាស់ ។ អំណាចនិតិប្រតិបត្តិមិនត្រូវជ្រៀតជ្រែកអំណាចនិតិបញ្ញត្តិ និងអំណាចតុលាការ ដែលនាំអោយបាត់បង់អព្យាក្រឹត្យភាព និងបាត់បង់ឯករាជ្យនោះឡើយ ។ ការជ្រៀតជ្រែកនោះ ជាការខុសពីគោលការណ៍ប្រជាធិបតេយ្យ ។ អំណាចនិតិប្រតិបត្តិ ជាអ្នកអនុវត្តន៍គោលការណ៍ប្រជាធិបតេយ្យ ដោយបើកសិទ្ធិសេរីភាពពេញលេញ និងការគោរពច្បាប់ ។ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពពេញលេញក្នុងការនិយាយស្តីបញ្ចេញមតិ ការជួបប្រជុំ និងការតវ៉ាដោយសន្តិវិធីជាដើម ។ ការបោះឆ្នោតដោយសេរីនឹងយុត្តិធម៌ ដោយប្រព័ន្ធឃោសនា ឯករាជ្យមិនលាក់បាំង លំអៀងទៅរកបុគ្គល ឬគណបក្សណាមួយ ។ អំណាចនិតិប្រតិបត្តិ មានតួនាទីសំខាន់ជាអ្នកកាច់ចង្កូតប្រទេសជាតិអោយរីកចំរើន ការពារផលប្រយោជន៍ជាតិ និងបំរើប្រជាពលរដ្ឋអោយមានសេចក្តីសុខសាន្ត ។

**៤-ព័ត៌មាន** (The Information)

បណ្តាញសារព័ត៌មានត្រូវធ្វើតាមវិជ្ជាជីវៈសារព័ត៌មានត្រឹមត្រូវ ដោយស្ថិតនៅជាអព្យាក្រឹត្យ ឯករាជ្យ និងមានសិទ្ធិសេរីភាពពេញលេញ ។ ការនិពន្ធ និងសរសេរព័ត៌មាន មិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយរបស់គណបក្ស ឬបុគ្គលណាមួយឡើយ ។ ប្រព័ន្ធព័ត៌មានត្រូវបើកចំហរយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅ ដើម្បីអោយគាត់យល់ដឹងអំពីស្ថានការណ៍ទូទៅនៅក្នុងប្រទេស ។ បណ្តាញសារព័ត៌មានត្រូវគោរពក្រមសីលធម៌របស់

ខ្លួន ។ សារព័ត៌មានជាកញ្ចក់ឆ្លុះបញ្ចាំងសង្គមពិត ដោយនិយាយអំពីការពិត ដែលកើតមាននៅក្នុងសង្គម ។ បណ្ដាញសារព័ត៌មាន ដែលគាំទ្រគណបក្សប្រជាជនកម្ពុជា ពុករលួយលំអៀង មិនចេញមុខ និងមិនហ៊ាននិយាយការពិត ដោយសារការភ័យខ្លាចពីសុវត្ថិភាព ការបាត់បង់អាជីពនិងការគំរាមកំហែងផ្សេងៗពីអ្នកមានអំណាច និងសម្ពាធនយោបាយជាដើម ។

### ៥-បំបាត់អំពើពុករលួយ (Corruption Elimination)

ការលុបបំបាត់អំពើពុករលួយ ជាកត្តាមួយសំខាន់ ហើយជាអទិភាពទី ១ ដែលយើងត្រូវតែដោះស្រាយនៅក្នុងសង្គមខ្មែរ អោយមានភាពថ្លៃថ្នូរ ស្អាតស្អំ ។ ការលប់បំបាត់អំពើពុករលួយនេះ ធ្វើអោយមនុស្សមានសេចក្ដីស្មោះត្រង់ ធ្វើប្រយោជន៍ជូនជាតិ ដោយមិនគិតពីអត្តានិយម និងប្រព្រឹត្តអំពើអាក្រក់ផ្សេងៗទៀត ។ បង្កើតច្បាប់ប្រឆាំងអំពើពុករលួយ និងការអនុវត្តន៍ច្បាប់ដោយម៉ឺងម៉ាត់ មានប្រព័ន្ធបច្ចេកវិទ្យាសំរាប់ត្រួតពិនិត្យជាកត្តាចំបងនាំអោយបំបាត់អំពើពុករលួយ ។ ជំហានបន្តត្រូវអប់រំកែលម្អអោយមនុស្សមានគំនិតល្អ ។

### ៦-បង្កើនជីវភាពប្រជាពលរដ្ឋ (Increase the Standard Living of People)

***ទុក្ខរបស់ប្រជាពលរដ្ឋ ជាទុក្ខរបស់មេដឹកនាំជាតិខ្មែរ សុភមង្គលរបស់ប្រជាពលរដ្ឋ ជាសុភមង្គលរបស់មេដឹកនាំជាតិខ្មែរ***។ យើងត្រូវបង្កើនជីវភាពប្រជាពលរដ្ឋអោយបានល្អតាមរយៈ ការផ្ដល់នូវចំណេះដឹងវិជ្ជាជីវៈមួយពិតប្រាកដ ការស្វែងរកទីផ្សារសំរាប់លក់ផលិតផល ការបង្កើតការងារ និង ប្រាក់បៀវត្សសមរម្យទៀតទាត់ ។ យើងសង្កេតឃើញបច្ចុប្បន្ននេះ ជីវភាពប្រជាពលរដ្ឋធ្លាក់ក្នុងភាពក្រីក្រ ដោយសារការមិនយកចិត្តទុកដាក់ពីមេដឹកនាំ ។ ជាពិសេស គឺ យួនមាននយោបាយចង់លេបទឹកដី រំលាយពូជសាសន៍ខ្មែរ អោយខ្មែរក្លាយជាជនជាតិភាគតិច ក្លាយជានរទេសជនចោលស្រុកទឹកដីកំណើត ។ ទាំងអស់នេះជានយោបាយរបស់ពួកយួនកុម្មុយនិស្ត ដើម្បីលេបទឹកដីខ្មែរ ។

### ៧-គណបក្សនយោបាយ (The Political Parties)

គណបក្សនយោបាយទាំងអស់ត្រូវតំកល់ផលប្រយោជន៍ជាតិទាំងមូលជាធំ ដោយមិនអោយមានការបែកបាក់គ្នា ដោយសារតែផលប្រយោជន៍បុគ្គល ឬអំណាច ធ្វើអោយផលប្រយោជន៍ជាតិបាត់បង់នោះឡើយ ។ គណបក្សនយោបាយទាំងអស់ត្រូវគោរពច្បាប់ជាធំ គោរពរដ្ឋធម្មនុញ្ញ ដោយឈរលើគោលការណ៍ស្រឡាញ់ជាតិ សាសនា ប្រជាជាតិខ្មែរពិតប្រាកដ ។ គណបក្សនយោបាយនីមួយៗ មិនត្រូវបំរើនយោបាយបរទេសឡើយ គណបក្សនយោបាយនីមួយៗ ត្រូវធ្វើការប្រកួតប្រជែងដើម្បីផលប្រយោជន៍ជាតិខ្មែរពិតៗ ។

### ៨-គណៈកម្មការជាតិរៀបចំបោះឆ្នោត ( National Election Committee)

សភាជាតិត្រូវបង្កើតច្បាប់រៀបចំគណៈកម្មការជាតិបោះឆ្នោតមួយ ដែលជំហរឯករាជ្យ អព្យាក្រិត សេរីភាព យុត្តិធម៌ ដែលគួរជាទីទុកចិត្តបានពីសំណាក់ប្រជាពលរដ្ឋ ។ ច្បាប់រៀបចំការបោះឆ្នោត ត្រូវមានប្រសិទ្ធភាពដោយការអនុវត្តអោយមានយុត្តិធម៌ ក្នុងការចាត់ចែងរៀបចំការបោះឆ្នោត ។ បេក្ខជនដែលជ្រើសរើសសំរាប់ធ្វើគណៈកម្មការជាតិរៀបចំការបោះឆ្នោត ត្រូវតែជាគណៈកម្មការដែលមានភាពស្អាតស្អំ ឯករាជ្យ អព្យាក្រិត្យ

ហើយមានការបោះឆ្នោតទុកចិត្តពីសភាជាតិ។ ពួកគេត្រូវតែមានឆន្ទះរៀបចំការបោះឆ្នោត មួយប្រកបដោយភាពយុត្តិធម៌ត្រឹមត្រូវ។

**៩-ជនអន្តោប្រវេសន៍ និងចារកម្មយួន** (Immigrants and Vietnamese spies)

ជនអន្តោប្រវេសន៍ទាំងអស់ត្រូវគោរពតាមច្បាប់អន្តោប្រវេសន៍ និងគោរពច្បាប់របស់ប្រទេសខ្មែរ។ ចំពោះជនអន្តោប្រវេសន៍ដែលមិនគោរពច្បាប់របស់ខ្មែរ ត្រូវបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ។ ចំពោះជនអន្តោប្រវេសន៍ដែលមានសញ្ជាតិខ្មែរ ដែលមានលក្ខណៈពេញលេញជាជនជាតិខ្មែរ មានសិទ្ធិស្មើគ្នានិងពលរដ្ឋខ្មែរទូទៅដែរ។ គ្រប់ភ្នាក់ងារទាំងអស់របស់យួនទាំងស៊ីវិល និង យោធា ត្រូវបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ។



ចារកម្មយួន ក្លែងភេទជាខ្មែរ

## VI.**សេចក្តីសន្និដ្ឋាន** (Conclusion)

តាមការសិក្សាស្រាវជ្រាវ បានបញ្ជាក់ប្រជាជាតិខ្មែរអោយមើលឃើញកាន់តែច្បាស់ អំពីដើមហេតុឫសគល់នៃបញ្ហា ដែលបាននឹងកំពុងកើតមាននៅក្នុងប្រទេសខ្មែរ។ ក្រោមការដឹកនាំផ្តេតផ្តាសរបស់ពួកជនផ្តាច់ការ ហ៊ុន សែន កំពុងនាំប្រទេសខ្មែរឈានទៅរកគ្រោះថ្នាក់មហន្តរាយមិនខានឡើយ។ បើយើងមិននាំគ្នាដោះស្រាយបញ្ហានេះអោយចប់ សេចក្តីទុក្ខវេទនារបស់ពលរដ្ឋខ្មែរ មិនត្រឹមតែធ្លាក់មកលើយើងនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ទុក្ខវេទនាទាំងអស់នេះ និងធ្លាក់ដល់កូនចៅខ្មែរជំនាន់ក្រោយទៀតនាពេលអនាគត។ ការបង្ហាញលាតត្រដាងពីការពិត ដូចបានរៀបរាប់ខាងលើនេះ ធ្វើអោយយើងទាំងអស់គ្នាជាខ្មែរ ឈប់វង្វេងជាមួយការបំភ័ន្តផ្សេងៗរបស់ពួកយួនកុម្មុយនិស្ត និងខ្មែរកុម្មុយនិស្តមួយចំនួន ដែលកំពុងតែកែក្រឡៃប្រវត្តិសាស្ត្រ ប្រើប្រាស់មនោគមន៍បោកប្រាស់ ដើម្បីអំណាច មុខមាត់ បុណ្យស័ក្ត សុខចិត្តអោនក្បាលបំរើផលប្រយោជន៍អោយពួកយួនកុម្មុយនិស្ត។ ហេតុដូច្នេះហើយ យើងឃើញថាឫសគល់ ៧ មករា គឺ កុម្មុយនិស្តយួន។យួន (សហព័ន្ធឥណ្ឌូចិន)នេះហើយជាអ្នករៀបចំផែនការមកលេបទឹកដីខ្មែរ កាន់កាប់ទឹកដីខ្មែរ ចាម ឡាវ ខ្មែរក្រោមរហូតមកដល់បច្ចុប្បន្ន។

# ឯកសារយោង (Reference)


១-កម្ពុជាឆ្នាំសូន្យ និពន្ធនិងប្រែសំរួលដោយលោក Francois Ponchaud

២-ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យនិពន្ធដោយ លោក ខៀវ សំផន

៣-កម្ពុជា និងសហព័ន្ធឥណ្ឌូចិន

៤-គេហទំព័រ របស់ បណ្ឌិត ណារញ្ញគីរីទីត្យ http://mysite.verizon.net/vzeof03b/

៥-រូបភាពដកស្រង់ចេញពី គេហទំព័រ ស្រឡាញ់ខ្មែរ ឬ ខេអាយមេឌ៉ា និង ឌីហ្វែស ប្រវត្តិសាស្រ្ត

៦- ឯកសារប្រវត្តិសាស្រ្ត កម្ពុជាក្រោម (អំណាចគ្មានខ្មែរក្រោម) ដោយ លោកត្រាំងឆាត ប៊ុត

៧-និតិរដ្ឋបាលទូទៅ ដោយបណ្ឌិត សាយ បូរី ឆ្នាំ ២០០៦

៨-ការបង្រៀនរបស់ព្រះពុទ្ធ ឆ្នាំ ១៩៦៦ ដោយលោក BUKKYO DENDO KYOKAI

9-Institute of Southeast Asian Studies, Singapore: 1981

10- Peter Schier, "Kampuchea in 1985," in *Southeast Asian Affairs 1986.*

11-Nayan Chanda, *Brother Enemy*.

*12- The War After the War* (1986).

13-"Origins of Khmer Communism," in Southeast Asian Affairs 1981.

14-World Politics,by Johnh T.Rourke ,Ph.D and Mark A Boyer, Ph.D University of Connecticut.

15-The International Politics of the Asia Pacific, Second edition and revised edition, by Michael Yahuda,Ph.D

16-Vietnamese Communist ( 1925-1945) by Huy nh Kim Khanh.

17-The Voice of America and Radio Free Asia.

18- Pictures quoted from KI Media.